# រាជរដ្ឋាភិបាលកម្ពុជា

## យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១

## ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព :
## កសាងមូលដ្ឋាន ឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០

## របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា

រាជធានីភ្នំពេញ ឆ្នាំ ២០២៣

# មាតិកា

**សេចក្តីផ្តើម**

**ផ្នែកទី ១**

១.១. សារៈតានៃយុទ្ធសាស្ត្រត្រីកោណ និង ចតុកោណ

១.២. សមិទ្ធផលធំៗនៃការអនុវត្តយុទ្ធសាស្ត្រត្រីកោណ និង ចតុកោណទាំង ៤ ដំណាក់កាល សម្រាប់រយៈវេលា ២៥ ឆ្នាំ កន្លងមក

១.៣. និន្នាការសកលធំៗដែលមានឥទ្ធិពលមកលើកម្ពុជា

១.៤. បញ្ហាប្រឈម

១.៥. កាលានុវត្តភាព

១.៦. ការសម្លឹងទៅមុខ ២៥ ឆ្នាំ នៃយុទ្ធសាស្ត្របញ្ចកោណ ដើម្បីឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០

១.៧. ភាពចាំបាច់ក្នុងការរៀបចំយុទ្ធសាស្ត្របញ្ចកោណ

**ផ្នែកទី ២**

២.១. រចនាសម្ព័ន្ធនៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១

២.២. ស្នូលនៃយុទ្ធសាស្ត្រ

២.៣. បរិស្ថានគ្របដណ្តប់នៃយុទ្ធសាស្ត្រ

២.៣. បញ្ចកោណយុទ្ធសាស្ត្រទាំង ៥

២.៤. កម្មវិធីនយោបាយអាទិភាពសម្រាប់អនុវត្តពីឆ្នាំ ២០២៣

**ផ្នែកទី ៣: យន្តការជំរុញការអនុវត្ត និង ក្របខណ្ឌត្រួតពិនិត្យ និង វាយតម្លៃ**

**ផ្នែកទី ៤: សន្និដ្ឋាន**

# ផ្នែកទី ១

## ១.១. សាវតានៃយុទ្ធសាស្ត្រត្រីកោណ និង ចតុកោណ

កម្ពុជាបានធ្វើដំណើរវែងឆ្ងាយ និង សម្រេចសមិទ្ធផលជាច្រើន ក្នុងការអភិវឌ្ឍប្រទេស តាមរយៈការអនុវត្តយុទ្ធសាស្ត្រត្រីកោណ និង ចតុកោណ ជាពិសេស ក្រោយការអនុវត្តដោយជោគជ័យនូវគោលនយោបាយឈ្នះឈ្នះរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានបិទបញ្ចប់ទំព័រនៃសង្គ្រាមស៊ីវិលរ៉ាំរ៉ៃរាប់ទសវត្សរ៍នៅកម្ពុជា នាថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៨ និង បើកនូវទំព័រសករាជថ្មីសម្រាប់កសាងជាតិឡើងវិញ ។

ក្នុងរយៈពេល ២៥ ឆ្នាំនេះ, កម្ពុជាបានឆ្លងកាត់នូវបរិវត្តកម្មធំមួយ ដោយបានប្រែក្លាយប្រទេសពីការហែកហួរដោយសង្គ្រាម និង អំពើប្រល័យពូជសាសន៍ មិនធ្លាប់មាន ក្នុងរយៈពេលជាង ៥០០ ឆ្នាំ, ទៅជាប្រទេសមានសុខសន្តិភាព, មានស្ថិរភាពនយោបាយ, សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម, សាមគ្គីភាពផ្ទៃក្នុងជាតិ, ការគោរពសិទ្ធិមនុស្ស និង ជាប្រទេសមានការអភិវឌ្ឍឆាប់រហ័ស ជាមួយកំណើនខ្ពស់ និង ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ពីប្រទេសខ្វះស្បៀងអាហារ, មកជាប្រទេសផលិតស្បៀងអាហារលើស និង មានការនាំចេញជាច្រើន ទៅកាន់ទីផ្សារពិភពលោក, ពីប្រទេសពោរពេញដោយគ្រាប់មីន និង យុទ្ធភណ្ឌមិនទាន់ផ្ទុះ ទៅជាប្រទេសផ្តល់កម្លាំងរក្សាសន្តិភាព និងដោះមីន ក្រោមឆ័ត្រអង្គការសហប្រជាជាតិ ជាពិសេស ពីប្រទេសពោរពេញដោយភាពក្រីក្រតោកយ៉ាក ទៅជាប្រទេសចំណូលមធ្យមកម្រិតទាប និង កំពុងត្រៀមខ្លួនចាកចេញពីប្រទេសមានការអភិវឌ្ឍតិចតួច ។ កម្ពុជាបច្ចុប្បន្នបានក្លាយជាប្រទេសឯករាជ្យ, អធិបតេយ្យ និង មានបូរណភាពទឹកដីពេញលេញ, មានសុខសន្តិភាព, សុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម, មានការអភិវឌ្ឍរីកចម្រើន និង មូលដ្ឋានសេដ្ឋកិច្ចរឹងមាំ ជាប្រទេសមានការគោរពលទ្ធិប្រជាធិបតេយ្យ, គោរពសិទ្ធ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងមានកិច្ចសហប្រតិបត្តិការរឹងមាំ ក្នុងនិម្មាបនកម្ម និង រចនាសម្ព័ន្ធសណ្តាប់ធ្នាប់អន្តរជាតិ ។

សមិទ្ធផលទាំងអស់នេះ គឺជាសក្ខីកម្មដ៏រឹងមាំ ដែលសបញ្ជាក់នូវភាពត្រឹមត្រូវ និង ចក្ខុវិស័យវែងឆ្ងាយនៃការដាក់ចេញ "**យុទ្ធសាស្ត្រត្រីកោណ**" និង "**យុទ្ធសាស្ត្រចតុកោណ**" ដែលត្រូវបានដឹកនាំអនុវត្ត ប្រកបដោយភាពឈ្លៀសវៃដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលធានាបាននូវជ័យជំនះជាប់ៗគ្នា និង ឥតឈប់ឈរពីដំណាក់កាលអភិវឌ្ឍមួយ ទៅដំណាក់កាលអភិវឌ្ឍបន្តបន្ទាប់ ទោះស្ថិតក្នុងស្ថានភាព និង កាលៈទេសៈដ៏លំបាកបំផុតក្តី ។ "**យុទ្ធសាស្ត្រត្រីកោណ**" ជាយុទ្ធសាស្ត្រដំបូង និង ជាការចាប់ផ្តើមស្តារ និង កសាងប្រទេសឡើងវិញ ដែលផ្តោតលើការធ្វើសន្តិភាវូបនីយកម្មប្រទេសឡើងវិញ, ការធ្វើសមាហរណកម្មកម្ពុជា ឱ្យឆាប់បំផុត ជាមួយសហគមន៍អន្តរជាតិ, និង ការជំរុញកសាង និង អភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដែលផ្តោតសំខាន់លើការកាត់បន្ថយភាពក្រីក្រ ។"**យុទ្ធសាស្ត្រចតុកោណ**" ជាយុទ្ធសាស្ត្ររយៈពេលវែង និង ជាការបន្តពី "**យុទ្ធសាស្ត្រត្រីកោណ**" ដែលមានគោលដៅបន្តពង្រឹងសន្តិភាព, សន្តិសុខ, ស្ថិរភាព និង សណ្តាប់ធ្នាប់សង្គម, ធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពរយៈពេលវែង ក្នុងអត្រាខ្ពស់ពី ៦ ទៅ ៧% ក្នុងមួយឆ្នាំ, បែងចែក

ផ្លែផ្កានៃកំណើនប្រកបដោយសមធម៌ រវាងអ្នកមាន និង អ្នកក្រ, រវាងទីក្រុងនិងជនបទ និង រវាងស្ត្រី និង បុរស, និង ធានាការគ្រប់គ្រង និង ប្រើប្រាស់ធនធានបរិស្ថាន និង ធនធានធម្មជាតិ ប្រកបដោយចីរភាព។ ក្នុងការអនុវត្ត "**យុទ្ធសាស្ត្រចតុកោណ**" ទាំង ៤ ដំណាក់កាលនេះ, រាជរដ្ឋាភិបាលបានខិតខំថែរក្សាយ៉ាងខ្ជាប់ខ្ជួននូវសន្តិភាព, ជំរុញការកែទម្រង់ដ៏ស៊ីជម្រៅទាំងឡាយ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ, បង្កើនការវិនិយោគលើ "**មូលធនមនុស្ស**" និង ជំរុញពិពិធកម្មសេដ្ឋកិច្ច និង ការអភិវឌ្ឍប្រកបដោយចីរភាព, កសាងខឿនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន, បើកចំហ, សមាហរណកម្មជាមួយសេដ្ឋកិច្ចតំបន់ និង សកលលោក ដោយឆ្លើយតបយ៉ាងរស់រវើកទៅនឹងនិន្នាការប្រែប្រួល, ទាំងក្នុង និង ក្រៅប្រទេស ។

ក្នុងបរិការណ៍ក្រោយការយកឈ្នះលើការរីករាលដាលនៃជំងឺកូវីដ-១៩ និង ការប្រែប្រួលថ្មីនៃភូមិសាស្ត្រនយោបាយសកល និង ដោយសំឡឹងឆ្ពោះទៅ "**ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០**", កម្ពុជាចាប់ផ្តើមដំណើរវែងឆ្ងាយ ២៥ ឆ្នាំទៅមុខ ក្នុងបេសកកម្មអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដើម្បីកសាងប្រទេសមួយរុងរឿង និង រីកចម្រើន ដោយដាក់ចេញនូវ "**យុទ្ធសាស្ត្របញ្ចកោណ**" ដែលនឹងបន្តបេសកកម្មនៃ "**យុទ្ធសាស្ត្រចតុកោណ**" ដែលនឹងត្រូវអនុវត្តជា ៥ ដំណាក់កាល ស្របតាមការប្រែប្រួលនៃបរិការណ៍ជាតិ-អន្តរជាតិ និង ស្ថានភាពជាក់ស្តែងនៃដំណាក់កាលនីមួយៗ ។ "**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**" នឹងចាប់ផ្តើមផ្តោតសំខាន់លើគោលដៅនៃការអភិវឌ្ឍដោយចីរភាព និង បរិយាប័ន្ន ដូចជា ការគិតគូរលើប្រព័ន្ធសន្តិសុខសង្គម, ការការពារបរិស្ថាន និង ប្រយុទ្ធប្រឆាំងការប្រែប្រួលអាកាសធាតុ និង ការជំរុញកំណើនផ្នែកសេដ្ឋកិច្ច និង សង្គមឌីជីថល ។

### ១.២. សមិទ្ធផលធំៗនៃការអនុវត្តយុទ្ធសាស្ត្រត្រីកោណ និង ចតុកោណ ទាំង ៤ ដំណាក់កាល សម្រាប់រយៈពេល ២៥ ឆ្នាំកន្លងមក

ជាមួយនឹងការថែរក្សាបានសុខសន្តិភាពពេញលេញ, រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានសមិទ្ធផលសំខាន់ថ្មីៗជាច្រើនបន្ថែមទៀត ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា, ទាំងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និង ការលើកកម្ពស់កិត្យានុភាពកម្ពុជានៅលើឆាកអន្តរជាតិ ទោះបីកម្ពុជាជាប្រទេសតូច និង ប្រឈមនឹងភាពមិនប្រាកដប្រជាជាច្រើនពីខាងក្រៅ ដូចជា ភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចសកល, ភាពតានតឹងនៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ, ការកើនឡើងនៃការគាំពារនិយម និង ជាតិនិយមជាសកល, ការប្រែប្រួលអាកាសធាតុ, ការរីករាលដាលនៃជំងឺកូវីដ-១៩, និង ផលប៉ះពាល់ពីខាងក្រៅដទៃទៀតក៏ដោយ ។ ដោយមានការតាំងចិត្តខ្ពស់ក្នុងស្មារតីនៃអភិក្រមរដ្ឋាភិបាលទាំងមូល (Whole-Government Approach) ក្នុងការអនុវត្តយុទ្ធសាស្ត្រត្រីកោណ និង យុទ្ធសាស្ត្រចតុកោណទាំង ៤ ដំណាក់កាល ដែលមានរយៈពេលសរុប ២៥ ឆ្នាំ កន្លងមកនេះ, រាជរដ្ឋាភិបាលសម្រេចបានលទ្ធផលធំៗជាច្រើន ដូចខាងក្រោម ÷

**១.** ការរក្សាបាននូវចីរភាពនៃសុខសន្តិភាពពេញលេញនៅទូទាំងប្រទេស ដែលកម្ពុជាមិនធ្លាប់សម្រេចបានក្នុងរយៈពេលជាង ៥០០ ឆ្នាំ, អធិបតេយ្យ, សណ្តាប់ធ្នាប់សង្គម, សន្តិសុខ និង សុវត្ថិភាពសង្គម, និង ស្ថិរភាពនយោបាយ ដោយប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍នីតិរដ្ឋ និង លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស, ការពង្រឹង

សាមគ្គីភាពផ្ទៃក្នុង, ការទប់ស្កាត់ដោយជោគជ័យប្រឆាំងនឹងឧបាយកលនានា ដើម្បីផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់, ការការពារប្រទេសជាតិមិនឱ្យធ្លាក់ចូលក្នុងកលិយុគនានា, ការប្រយុទ្ធប្រឆាំងនឹងវិបត្តិខាងក្រៅ និង ការរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។ កត្តាទាំងនេះ គឺជាបុរេលក្ខខណ្ឌដែលមិនអាចខ្វះបាន និង ជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍប្រទេសជាតិ, ក៏ដូចជាការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាទាំងមូល ។

**២.** ការសម្រេចបានវឌ្ឍនភាពការកែទម្រង់ស្ថាប័ន និង ការលើកកម្ពស់អភិបាលកិច្ចល្អ ដូចជាការកែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ តាមរយៈការដាក់ចេញយុទ្ធសាស្ត្រនានា ដូចជាការកសាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជាដើម, ការកែទម្រង់មុតស្រួចលើកិច្ចសម្រួលពាណិជ្ជកម្ម និង ធុរកិច្ច, ការកែទម្រង់តាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ, វឌ្ឍនភាពគួរឱ្យកត់សម្គាល់នៃការលើកកម្ពស់ភាពស្អាតស្អំក្នុងវិស័យសាធារណៈ, ការកែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌, និង ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ ជាដើម ។ ជាក់ស្តែង, រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយសំខាន់ៗ ដូចជា ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា និង គោលនយោបាយរដ្ឋាភិបាលឌីជីថល សំដៅជំរុញបន្ថែមនូវការកែទម្រង់លើវិស័យខាងលើ ដើម្បីប្រសិទ្ធភាព, ភាពស្អាតស្អំ និង ភាពប្រកួតប្រជែងឈ្នះរបស់កម្ពុជា ។

**៣.** ការកែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈវិមជ្ឈការ និង វិសហមជ្ឈការ គឺជាផ្នែកមួយដ៏មានសារៈសំខាន់ ក្នុងការជំរុញការផ្តល់សេវាសាធារណៈ ឱ្យកាន់តែប្រសើរ និង មានប្រសិទ្ធភាព ជូនប្រជាជននៅមូលដ្ឋាន ។ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី ១ និង ទី ២ បានផ្តល់ជាក្របខណ្ឌយុទ្ធសាស្ត្រ ក្នុងគោលដៅប្រែក្លាយរដ្ឋបាលថ្នាក់ក្រោមជាតិទៅជា **រដ្ឋបាលឯកភាព** មួយ ដើម្បីធានាឱ្យមានការឆ្លើយតបទាន់ពេល និង មានប្រសិទ្ធភាព ស្របនឹងសំណូមពរ និង តម្រូវការនៃការអភិវឌ្ឍនៅមូលដ្ឋាន ។ រាជរដ្ឋាភិបាល បានធ្វើវិមជ្ឈការហិរញ្ញវត្ថុ តាមរយៈការបង្កើនចំណាយកាន់តែច្រើន ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់ទៅនឹងការកសាងសមត្ថភាព ដើម្បីធានាតម្លាភាព និង គណនេយ្យភាពច្បាស់លាស់ និង ភាពបត់បែនតាមស្ថានភាពជាក់ស្តែង ។ ជាក់ស្តែង, ការធ្វើវិភាជន៍ថវិកា សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ បានបន្តកើនឡើងជាលំដាប់ពីប្រមាណ ១,០៨% នៃ ផ.ស.ស ក្នុងឆ្នាំ ២០១៣ ដល់ ៣,៨៥% នៃ ផ.ស.ស ។

**៤.** ដោយបន្តអនុវត្តគោលនយោបាយសេដ្ឋកិច្ចបើកចំហ, ការធ្វើវិសោធនកម្មច្បាប់វិនិយោគជាបន្តបន្ទាប់ និង ច្បាប់វិនិយោគថ្មីត្រូវបានរៀបចំឡើង, រំហូរការវិនិយោគពីបរទេសបានកើនឡើងគួរឱ្យកត់សម្គាល់ទៅក្នុងវិស័យជាច្រើននៃសេដ្ឋកិច្ចជាតិ ។ ការវិនិយោគផ្ទាល់ពីបរទេសមានចំនួនតិចតួចប្រមាណ ៦៩ លានដុល្លារប៉ុណ្ណោះ ក្នុងដំណាក់កាលដំបូងនៃការបើកចំហសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ១៩៩៤ ។ ចំនួននៃរំហូរការវិនិយាគប្រចាំឆ្នាំបានកើនឡើងដល់ប្រមាណ១៤៩ លានដុល្លារ នៅឆ្នាំ ២០០០, ១ ៤០៤ លានដុល្លារ នៅឆ្នាំ ២០១០ និង ៣ ៦២៥ លានដុល្លារ នៅឆ្នាំ ២០២០, ប៉ុន្តែ បានធ្លាក់មកត្រឹម ៣ ៤៨៣ លានដុល្លារ នៅឆ្នាំ ២០២១ ដោយសារវិបត្តិនៃជំងឺកូវីដ-១៩ និង សេដ្ឋកិច្ចសកល ។ កម្ពុជាដែលពីមុនមិនមានអ្នកហ៊ានវិនិយោគ សូម្បីប្រជាជនកម្ពុជាផ្ទាល់, នៅពេលនេះ បាន

ក្លាយជាទីតាំងវិនិយោគដ៏សំខាន់មួយក្នុងតំបន់ ។ ការវិនិយោគផ្ទាល់ពីបរទេសសរុបនៅកម្ពុជាមានចំនួនរហូតដល់ប្រមាណ ៤៣ ៦០១ លានដុល្លារ គិតត្រឹមត្រីមាសទី ៣ នៃ ឆ្នាំ ២០២២ ។ តំបន់សេដ្ឋកិច្ចពិសេសចំនួន ២៤ កំពុងដំណើរការ ដែលមានរោងចក្រចំនួន ៦១៨ និង ទុនវិនិយោគសរុបប្រមាណ ៧,៥ ពាន់លានដុល្លារអាមេរិក និង ផ្តល់ការងារជាង ១៧ ម៉ឺនកន្លែង ។

**៥.** ចីរភាពនៃកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងអត្រាជាមធ្យមប្រមាណជាង ៧% ក្នុងមួយឆ្នាំ រហូតដល់មុនការរាតត្បាតនៃជំងឺកូវីដ-១៩, ការសម្រេចបានឋានៈកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតទាប, ការពង្រឹង និង ពង្រីកពិពិធកម្មសេដ្ឋកិច្ចកម្ពុជា, ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, និង ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយវិត្តារកម្មថវិកាដោយប្រយ័ត្នប្រយែង សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច, សមធម៌, ប្រសិទ្ធភាពសេវាសាធារណៈ និង ការធានាបានចីរភាពថវិកាជាតិ ។ ដោយសារកំណើនខ្ពស់នេះ, កម្រិតជីវភាពប្រជាជនកម្ពុជាកាន់តែមានភាពល្អប្រសើរដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃប្រាក់ចំណូលក្នុងប្រជាជនម្នាក់ពី ១ ៥៦៣ ដុល្លារ ក្នុងឆ្នាំ ២០១៨ ដល់ប្រមាណ ១ ៧៨៥ ដុល្លារអាមេរិក ក្នុងឆ្នាំ ២០២២ ។

**៦.** រាជរដ្ឋាភិបាលបានកំណត់យកការចាក់វ៉ាក់សាំង ជាវិធានការយុទ្ធសាស្ត្រគន្លឹះ ដោយបានគ្រប់គ្រងចំណាយថវិកា, ការកៀរគរ និង ការប្រើប្រាស់ជំនួយ ប្រកបដោយប្រសិទ្ធភាព និង សម្រេចបានជោគជ័យខ្ពស់នៅក្នុងយុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ និង ការគ្រប់គ្រងស្ថានភាពជំងឺកូវីដ-១៩ បានល្អប្រសើរ ដោយធ្វើការចាក់វ៉ាក់សាំងដោយប្រើប្រាស់ "**យុទ្ធសាស្ត្រផ្ការីក**" ជូនប្រជាជនកម្ពុជាគ្រប់រូប ដោយឥតគិតថ្លៃ, ទាំងដូសមូលដ្ឋាន និង ដូសជំរុញជាបន្តបន្ទាប់ ដែលធ្វើឱ្យកម្ពុជាក្លាយជាប្រទេស ដែលមានអត្រាចាក់វ៉ាក់សាំងខ្ពស់ ពុំសូវមានអ្នកឆ្លង និង មានអ្នកស្លាប់តិចតួចបំផុតដោយសារជំងឺកូវីដ-១៩ ព្រមទាំងបង្កើតបានភាពស៊ាំសហគមន៍ពេញលេញ និង ជួយធានាសុវត្ថិភាពសុខភាពសាធារណៈកម្ពុជា ។ ភាពជោគជ័យនៃការគ្រប់គ្រងស្ថានភាពជំងឺកូវីដ-១៩ បង្កើនប្រសិទ្ធភាពនៃការឆ្លើយតបរបស់រាជរដ្ឋាភិបាលទៅនឹងវិបត្តិ ដែលតាមរយៈនេះ រុញសេដ្ឋកិច្ចកម្ពុជាឱ្យចាកចេញពីកំណើនអវិជ្ជមាន -៣% ក្នុងពេលដ៏ខ្លី និង ធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាងើបឡើងវិញយ៉ាងឆាប់រហ័សក្នុងទម្រង់ជាអក្សរ V ជាមួយនឹងកំណើន ៣% នៅឆ្នាំ ២០២១ និង ៥,២% នៅឆ្នាំ ២០២២ ។

**៧.** ជោគជ័យនៃការកាត់បន្ថយភាពក្រីក្រ និងវិសមភាពសេដ្ឋកិច្ចជូនប្រជាជន តាមរយៈគោលនយោបាយបែងចែកផលសេដ្ឋកិច្ច ជាពិសេស តាមរយៈការអនុវត្តគោលនយោបាយដំឡើងបៀវត្សមន្ត្រីរាជការ និង ប្រាក់ឈ្នួលអប្បបរមា ព្រមទាំងការគិតគូរពីសុខុមាលភាពរបស់កម្មករ តាមរយៈការពង្រីកវិសាលភាពបេឡាជាតិរបបសន្តិសុខសង្គម និង មូលនិធិសមធម៌, ការពង្រីកការផ្តល់សេវាសាធារណៈសំខាន់ៗ ដូចជា បណ្តាញអគ្គិសនី និង ទឹកស្អាតក្នុងតម្លៃទាប, ការផ្តល់សេវាដឹកជញ្ជូនសាធារណៈ និង ការជំរុញអនុវត្តយន្តការដោះស្រាយវិវាទការងារ, ការអនុវត្តកម្មវិធីផ្ទេរសាច់ប្រាក់ដល់អ្នករងផលប៉ះពាល់ដោយជំងឺកូវីដ-១៩ ដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាជន ។

**៨.** ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់ ដោយចំណូលចរន្តថវិការដ្ឋ

បានកើនឡើងជាបន្តបន្ទាប់ ។ ជាក់ស្តែង, ការប្រមូលចំណូលចរន្តបានកើនឡើងប្រហែល ៣,១៨ ពិន្ទុភាគរយ នៅឆ្នាំ ២០១៨-២០១៩ និង បានបន្តកើនឡើងប្រមាណ ៤,០៨ ពិន្ទុភាគរយ នៅឆ្នាំ២០២០ តាមរយៈយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ ២០១៩-២០២៣ ទោះបីកម្ពុជាកំពុងរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ ក៏ដោយ ។ ភាពជោគជ័យខាងលើនេះ សម្រេចបានតាមរយៈ (i). ការធ្វើទំនើបភាវូបនីយកម្មនៃរដ្ឋបាលពន្ធដារ រដ្ឋបាលគយ និង រដ្ឋាករកម្ពុជា, (ii). សេវាបង់ពន្ធត្រូវបានធ្វើឱ្យប្រសើរឡើង និង កាន់តែងាយស្រួល និង ឆាប់រហ័សជូនអ្នកជាប់ពន្ធ, (iii). ការបង្កើនការយល់ដឹង និង លើកកម្ពស់វប្បធម៌បង់ពន្ធ, (iv). ការពង្រឹងអនុលោមភាពសារពើពន្ធ តាមរយៈការសម្រួលនីតិវិធីធ្វើសវនកម្ម និង ពង្រឹងការធ្វើសវនកម្មពន្ធដារ, និង យន្តការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់តាមប្រព័ន្ធព័ត៌មានវិទ្យា, (v). ការប្រយុទ្ធប្រឆាំងនឹងការរត់ពន្ធ និង ការគេចវេសពន្ធ, (vi). ការកែសម្រួលតម្លៃគិតពន្ធគយ និង អត្រាអាករពិសេសនៃទំនិញមួយចំនួន, និង (vii). ការពង្រឹងរដ្ឋបាល និង គោលនយោបាយចំណូលមិនមែនសារពើពន្ធ តាមរយៈការរៀបចំ និង ការដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រង, ការប្រើប្រាស់, និង ការចាត់-ចែងលើទ្រព្យសម្បត្តិរដ្ឋ, និង ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ។

**៩.** បំណុលសាធារណៈត្រូវបានគ្រប់គ្រងឱ្យស្ថិតក្នុងកម្រិតហានិភ័យទាប និង មានចីរភាព ដោយប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះទាំង ៤ រួមមាន (i). ខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និង សេដ្ឋកិច្ចអាចទ្រាំទ្របានល្អ, (ii). ខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬ លក្ខខណ្ឌអនុគ្រោះខ្ពស់, (iii). ខ្ចីសម្រាប់តែវិស័យអាទិភាព សម្រាប់ទ្រទ្រង់ចីរភាពនៃកំណើន និង វិស័យបង្កើនផលិតភាពសេដ្ឋកិច្ច, និង (iv). ប្រើប្រាស់ឥណទាន ប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធផល និង ប្រសិទ្ធភាពខ្ពស់បំផុត ។ ការណ៍នេះ ធ្វើឱ្យគ្រប់សូចនាករបំណុលគន្លឹះៗ ស្ថិតក្រោមអនុបាតគោល ។ ជាក់ស្តែង, អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹង ផ.ស.ស ត្រូវបាន ប៉ាន់ស្មានថាមានកម្រិតត្រឹម ២៤,៩% នៅឆ្នាំ ២០២២ ធៀបនឹងអនុបាតគោល (Threshold) ៤០% ។ បំណុលសាធារណៈនេះត្រូវបានប្រើប្រាស់សម្រាប់វិស័យអាទិភាព ដូចជា អប់រំ និង សុខាភិបាល ជាដើម ដើម្បីទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ចកម្ពុជារយៈពេលមធ្យម និង វែង ។

**១០.** សុខភាពសាធារណៈត្រូវបានកែលម្អ និង ពង្រឹង គួរឱ្យកត់សម្គាល់ជាបន្តបន្ទាប់ ដែលធ្វើឱ្យកម្ពុជាប្រយុទ្ធទប់ស្កាត់ និង បង្ការជំងឺកូវីដ-១៩ ដោយជោគជ័យខ្ពស់ និង កាត់បន្ថយផលប៉ះពាល់នៃវិបត្តិនេះ មកលើសុខភាពប្រជាជនកម្ពុជា ឱ្យស្ថិតនៅកម្រិតទាប ហើយអត្រាមរណភាពមាតា ទារក និង កុមារ, អត្រាប្រេវ៉ាឡង់នៃអ្នកផ្ទុកមេរោគអេដស៍ និង អត្រាស្លាប់ដោយជំងឺឆ្លងផ្សេងៗ ត្រូវបានកាត់បន្ថយគួរឱ្យកត់សម្គាល់ ។ ជាក់ស្តែង, អត្រាមរណភាពទារកក្នុង ១០០០ នាក់ បានធ្លាក់ចុះពីចំនួន ១១៨ នាក់ ក្នុងឆ្នាំ ១៩៧៩ មកត្រឹម អត្រា ១៨,៦ នាក់ នៅឆ្នាំ ២០២១ ហើយអត្រាមរណភាពកុមារអាយុក្រោម ៥ ឆ្នាំ ក្នុង ១០០០ នាក់ បានធ្លាក់ចុះពីចំនួន ២០៦ នាក់ នៅឆ្នាំ ១៩៧៩ មកត្រឹម ២៤,៨ នាក់ នៅ ឆ្នាំ ២០២១ ។

**១១.** វិស័យអប់រំត្រូវបានកែទម្រង់ជាប្រចាំ ដើម្បីបង្កើតបរិយាកាសល្អសម្រាប់ការអប់រំប្រកបដោយបរិយាប័ន្ន សំដៅជំរុញការអភិវឌ្ឍធនធានមនុស្សឱ្យសម្រេចបានមូលធនមនុស្ស និង ជំនាញខ្ពស់ សម្រាប់បំពេញតម្រូវការ

នៃការអភិវឌ្ឍជាតិ និង ទីផ្សារការងារ តាមរយៈការបង្កើតសាលាជំនាន់ថ្មី, ការពង្រឹងគុណភាពនៃការបង្រៀន និង រៀន, ការលើកកម្ពស់សមត្ថភាព និង អភិបាលកិច្ចល្អនៅតាមគ្រឹះស្ថានសិក្សា, ការធ្វើបច្ចុប្បន្នកម្មនៃកម្មវិធីសិក្សានៅគ្រប់កម្រិតសិក្សា, ការបង្កើនការផ្តល់អាហារូបករណ៍សម្រាប់សិស្ស-និស្សិតក្រីក្រ និង ងាយរងគ្រោះ, និង ការបង្កើតបរិយាកាសល្អសម្រាប់ការសិក្សាពេញមួយជីវិត ដើម្បីធ្វើបច្ចុប្បន្នកម្មចំណេះដឹង និង សម្រួចជំនាញឯកទេសជាប្រចាំ សំដៅលើកកម្ពស់ភាពប្រកួតប្រជែងនៃកម្លាំងពលកម្ម និង កសាងយុវជនបន្តវេនកម្ពុជា ដែលមានសមត្ថភាពដឹកនាំខ្ពស់ ។

**១២.** វិសាលភាពប្រព័ន្ធគាំពារសង្គមត្រូវបានពង្រឹង និង ពង្រីក ដើម្បីរក្សាលំនឹងជីវភាពប្រជាជន តាមរយៈក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម, កសាងប្រព័ន្ធគាំពារសង្គមកម្ពុជា ដែលរួមមានប្រព័ន្ធជំនួយសង្គម និង ប្រព័ន្ធសន្តិសុខសង្គម, ការបង្កើតនូវស្ថាប័ននិយ័តករសន្តិសុខសង្គម និង មូលនិធិជាតិជំនួយសង្គម, ការកែសម្រួលមុខងារ និង ភារកិច្ចរបស់បេឡាជាតិសន្តិសុខសង្គម ឱ្យកាន់តែមានប្រសិទ្ធភាព, និង ការលើកកម្ពស់អភិបាលកិច្ចល្អ ក្នុងវិស័យប្រព័ន្ធគាំពារសង្គម ។ ដើម្បីរក្សាលំនឹងជីវភាពប្រជាជន ជាពិសេស ជនក្រីក្រ និង ងាយរងគ្រោះ, រាជរដ្ឋាភិបាលបានអនុវត្តវិធានការអន្តរាគមន៍ជំនួយ និង សន្តិសុខសង្គមមួយចំនួន ដូចជា កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩, ការអន្តរាគមន៍គាំពារសង្គម ដើម្បីឆ្លើយតបនឹងសម្ពាធអតិផរណា, កម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ស្ត្រីមានផ្ទៃពោះ និង កុមារអាយុក្រោម ២ ឆ្នាំ, កម្មវិធីជំនួយសង្គមសម្រាប់គ្រួសារងាយរងហានិភ័យពីគ្រោះទឹកជំនន់, និង ការផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករ-និយោជិតក្នុងវិស័យកាត់ដេរ និង វិស័យទេសចរណ៍ ជាដើម ។

**១៣.** តួនាទីរបស់កម្ពុជាត្រូវបានលើកកម្ពស់កាន់តែសកម្មក្នុងកិច្ចការតំបន់ និង ពិភពលោក ដោយស្មើមុខ និង ស្មើសិទ្ធិ ។ ក្នុងក្របខណ្ឌអង្គការសហប្រជាជាតិ ចាប់ពីឆ្នាំ ២០០៦ មក, កម្ពុជាបានបញ្ជូនកងកម្លាំងរក្សាសន្តិភាពសរុបចំនួន ៨ ៦៧១ នាក់ ដែលក្នុងនោះកងកម្លាំងជាស្ត្រីមានចំនួន ៦៤៧ នាក់ ទៅបំពេញបេសកកម្មរក្សាសន្តិភាពនៅក្នុងប្រទេសចំនួន ៩ ហើយស្ត្រីកម្ពុជា ១ រូប ត្រូវបានជ្រើសរើសជា "ជាស្ត្រីក្លាហាន" នៅក្នុងយុទ្ធនាការ "ស្ត្រីដើម្បីពហុភាគីនិយម" ក្នុងទីក្រុងហ្សឺណែវនៅឆ្នាំ ២០២២ ។ លើសពីនេះ, កិត្យានុភាពកម្ពុជា បានលេចឡើងកាន់តែខ្ពស់ តាមរយៈតួនាទីកាន់តែសកម្ម និង កាន់តែច្រើននៅលើឆាកអន្តរជាតិ ដូចជា កម្ពុជាបានបំពេញតួនាទីជាប្រធានសម្របសម្រួលនៃប្រទេសដែលមានការអភិវឌ្ឍតិចតួចប្រកបដោយជោគជ័យ ក្នុងឆ្នាំ ២០១៧-២០១៨ ក្នុងក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក, កម្ពុជាត្រូវបានជ្រើសរើសជាអនុប្រធាននៃមហាសន្និបាតអង្គការសហប្រជាជាតិលើកទី ៧៣ និង ត្រូវបានជ្រើសរើសជាសមាជិកនៃក្រុមប្រឹក្សាសង្គម-សេដ្ឋកិច្ច នៃអង្គការសហប្រជាជាតិ, ក្នុងកិច្ចសហប្រតិបត្តិការក្នុងតំបន់ កម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងក្របខណ្ឌអាស៊ាន និង ជាសមាជិកស្ថាបនិកនៃធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី(AIIB) ក្រោមគំនិតផ្តួចផ្តើម "ខ្សែក្រវាត់មួយ ផ្លូវមួយ", ព្រមទាំងកិច្ចសហប្រតិបត្តិការទ្វេភាគី និង ពហុភាគីជាច្រើនទៀត ។

**១៤.** ក្នុងរយៈពេល ២០ ឆ្នាំ ចុងក្រោយនេះ, វិស័យទេសចរណ៍កម្ពុជាមានកំណើនគួរជាទីមោទនៈ រហូតដល់មុនការផ្ទុះឡើងនៃវិបត្តិជំងឺកូវីដ-១៩ ។ ជាមួយនឹងសុខសន្តិភាពពេញលេញ, កម្ពុជាបានក្លាយជាគោលដៅទេសចរណ៍វប្បធម៌ និង ធម្មជាតិ ដ៏ពេញនិយម ដោយបានទាក់ទាញទេសចរអន្តរជាតិសរុបចំនួន ៦,៦ លាននាក់ និង ទទួលបានប្រាក់ចំណូលជាង ៤ ៣៧៥ លានដុល្លារអាម៉េរិក ដែលស្មើនឹង ១២,៧% នៃ ផ.ស.ស សរុប នៅឆ្នាំ ២០១៩ ។ ជោគជ័យនេះ គឺជាលទ្ធផលនៃការសម្រេចបានការធ្វើសមាហរណកម្ម និង ការតភ្ជាប់ផ្នែកហេដ្ឋារចនាសម្ព័ន្ធទូទាំងផ្ទៃប្រទេស, ការធានានូវសុវត្ថិភាពសម្រាប់ទេសចរ, ការផ្សព្វផ្សាយកម្ពុជាជាគោលដៅទេសចរណ៍សុវត្ថិភាព, ការធ្វើពិពិធកម្មតំបន់ទេសចរណ៍ និង ផលិតផលទេសចរណ៍របស់កម្ពុជាបានកាន់តែសម្បូរបែប ។

**១៥.** វិស័យពាណិជ្ជកម្ម បាន និង កំពុងដើរតួនាទីសំខាន់ និង ជាចន្ទល់សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និង ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ដោយបានរួមចំណែកយ៉ាងច្រើនដល់ការកាត់បន្ថយភាពក្រីក្រប្រជាជន, បង្រួមវិសមភាពសេដ្ឋកិច្ច និង លើកកម្ពស់ការផ្ទេរបច្ចេកវិទ្យាថ្មីៗ ព្រមទាំងបានជំរុញការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជា ចូលកាន់តែជ្រៅក្នុងសេដ្ឋកិច្ចតំបន់ និង អន្តរជាតិ តាមរយៈការធ្វើពិពិធកម្ម, ទាំងទីផ្សារ សម្រាប់នាំចេញ និង ផលិតផលនាំចេញ និង ការពង្រឹងការតភ្ជាប់សេដ្ឋកិច្ចកម្ពុជាទៅនឹងខ្សែច្រវាក់ផ្គត់ផ្គង់ និង ខ្សែច្រវាក់តម្លៃតំបន់ និង សកល ។ ជាក់ស្តែង, នៅឆ្នាំ ២០២២ កម្ពុជាបាននាំចេញទំនិញ ក្នុងទំហំប្រមាណ ៧៩,៣% នៃ ផ.ស.ស និង នាំចូលទំនិញក្នុងទំហំ ១០៥,៦% នៃ ផ.ស.ស ដែលធ្វើឱ្យកម្ពុជាក្លាយជាប្រទេសមួយមានសេដ្ឋកិច្ចបើកចំហយ៉ាងខ្លាំង ។

**១៦.** វិស័យហិរញ្ញវត្ថុ ទាំងធនាគារ និង មិនមែនធនាគារ មានការរីកចម្រើនយ៉ាងខ្លាំង ។ វិស័យធនាគារ ដែលពេលមុនប្រជាជនមិនទុកចិត្ត, ពេលនេះ ជាប្រព័ន្ធធនាគាររឹងមាំ និង មានស្ថិរភាព ដោយមានសន្ទនីយភាពគ្រប់គ្រាន់ និង កំណើនឥណទានល្អ ព្រមទាំងបានក្លាយជាដៃគូយ៉ាងសំខាន់ ក្នុងការជំរុញវិស័យពិតនៃសកម្មភាពសេដ្ឋកិច្ច និង កំណើនសេដ្ឋកិច្ចជាតិ ។ គិតត្រឹមឆ្នាំ ២០២២, ទ្រព្យសកម្មសរុបមានទំហំប្រមាណ ៨០ ប៊ីលានដុល្លារ, ឥណទាន ៥៦ ប៊ីលានដុល្លារ និង ប្រាក់បញ្ញើ ៤៥ ប៊ីលានដុល្លារ ។ ទំហំទុននៃធនាគារ និង ស្ថាប័នហិរញ្ញវត្ថុមានគ្រប់គ្រាន់ ឆ្លុះបញ្ចាំងតាមរយៈអនុបាតសោធនភាពមធ្យមសម្រាប់ធនាគារស្មើនឹង ២២,៣% និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ២០,៦% ដែលជាអត្រាខ្ពស់ជាងលក្ខខណ្ឌកំណត់ដោយបទប្បញ្ញត្តិស្មើនឹង ១៥% ប៉ុណ្ណោះ ។ អនុបាតនៃសាច់ប្រាក់ងាយស្រួលនៃធនាគារពាណិជ្ជជាមធ្យមស្មើនឹង ១៤៣,៨% និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលប្រាក់បញ្ញើស្មើនឹង ១៥៦,៧% ធៀបនឹងលក្ខខណ្ឌកំណត់ដោយបទប្បញ្ញត្តិក្នុងអត្រា ១០០% ។ អនុបាតឥណទានមិនដំណើរការមានទំហំតូចស្មើនឹង ៣,១% សម្រាប់ធនាគារពាណិជ្ជ និង ២,៥% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ បន្ថែមលើនេះ, វិស័យធានារ៉ាប់រង និង ទីផ្សារមូលបត្រក៏កំពុងដំណើរការ និង បន្តការរីកចម្រើន ។

**១៧.** រចនាសម្ព័ន្ធរឹងសំខាន់ៗ ដូចជា ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន, ប្រព័ន្ធឡូជីស្ទីក, ប្រព័ន្ធថាមពល, ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធឌីជីថល, ប្រព័ន្ធធារាសាស្ត្រ, និង ប្រព័ន្ធបង្ហូរទឹក និង ទឹកស្អាត ត្រូវបានកែលម្អគួរឱ្យកត់សម្គាល់ ។ វិស័យគមនាគមន៍ និងដឹកជញ្ជូនកម្ពុជាដែលធ្លាប់ត្រូវបានកាត់ផ្តាច់ និង រងការបំផ្លាញស្ទើរទាំងស្រុង

ដោយសារសង្គ្រាមស៊ីវិលរ៉ាំរ៉ៃជាច្រើនទសវត្សរ៍ ត្រូវបានស្ដារ និង ស្ថាបនាឡើងវិញ ដើម្បីតភ្ជាប់ផ្ទៃក្នុងប្រទេស និង ជាមួយប្រទេសជិតខាង ដែលធានាដល់ការធ្វើដំណើរបានគ្រប់ពេលវេលា និង គ្រប់ទីកន្លែង ជាពិសេសបាន និង កំពុងតែបន្តកសាង និង កែលម្អជាបន្តបន្ទាប់ ដើម្បីប្រែក្លាយទៅជាប្រព័ន្ធដឹកជញ្ជូនអន្តរមធ្យោបាយ សម្រាប់បម្រើឱ្យការតភ្ជាប់ផ្ទៃក្នុងប្រទេសផង និង ពង្រីកសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចតំបន់ និង ពិភពលោកឱ្យកាន់តែជ្រៅផង ។ បច្ចុប្បន្ន, កម្ពុជាសម្រេចបានការសាងសង់ផ្លូវជាតិ និង ផ្លូវតាមខេត្តដោយក្រាលកៅស៊ូ និង បេតុងគ្រប់ប្រភេទមានប្រវែងសរុប ១១ ០៤២ គីឡូម៉ែត្រ, ផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ ប្រវែង ១៨៧,៥ គីឡូម៉ែត្រ, ស្ពានតូចធំគ្រប់ប្រភេទចំនួន ២ ៥៣០ ស្ពាន មានប្រវែងសរុប ៨៦,២ គីឡូម៉ែត្រ, បណ្ដាញផ្លូវនាវាចរណ៍តាមដងទន្លេមេគង្គ ទន្លេសាប និង ទន្លេបាសាក់ មានប្រវែងសរុប ១ ៧៥០ គីឡូម៉ែត្រ ព្រមទាំងកំពុងបន្តអភិវឌ្ឍ ពង្រីក និង ធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធកំពង់ផែនានា ជាពិសេស គម្រោងផ្លូវនាវាចរណ៍ និង ប្រព័ន្ធភ័ស្តុភារកម្ម សម្រាប់ការដឹកជញ្ជូនតភ្ជាប់ពីទន្លេបាសាក់ទៅសមុទ្រខេត្តកែប ។ អត្រាគ្របដណ្ដប់ដោយអគ្គិសនីរហូតពេលនេះ មានរហូតដល់ទៅ ៩០% នៅឆ្នាំ ២០២២ ធៀបនឹងឆ្នាំ ២០១៨ មានតិចជាង ២០% ប៉ុណ្ណោះ ។

**១៨.** ភាពប្រកួតប្រជែងកម្ពុជាមានការកើនឡើងជាបន្តបន្ទាប់ តាមរយៈការកើនឡើងនៃផលិតភាពពលកម្ម ។ ផ្អែកតាមវេទិកាសេដ្ឋកិច្ចពិភពលោក ឆ្នាំ ២០១៨-២០១៩, ភាពប្រកួតប្រជែងរបស់កម្ពុជាបានកើនឡើងពីពិន្ទុ ៥០ ក្នុងឆ្នាំ ២០១៨ ដល់ ៥២ ពិន្ទុ ក្នុងឆ្នាំ២០១៩ ដោយទទួលបានចំណាត់ថ្នាក់ទី ១១០ ក្នុងចំណោម ១៤០ ប្រទេស ក្នុងឆ្នាំ ២០១៨ និង ចំណាត់ថ្នាក់ទី ១០៦ ក្នុងចំណោម ១៤១ ប្រទេស ក្នុងឆ្នាំ ២០១៩ ។ ភាពប្រសើរឡើងនេះ ត្រូវបានជំរុញដោយការការពង្រឹងគុណភាពសសរស្ដម្ភនៃភាពប្រកួតប្រជែងកម្ពុជា ដូចជា ហេដ្ឋារចនាសម្ព័ន្ធ, ស្ថាប័ន, ជំនាញ, ទីផ្សារការងារ និង ជវភាពធុរកិច្ច ។ បន្ថែមលើនេះ ផ្អែកតាមទិន្នន័យពី UNCTAD, សន្ទស្សន៍សមត្ថភាពផលិតភាពរបស់កម្ពុជាបានកើនឡើង គួរឱ្យកត់សម្គាល់, ពោល គឺកើនឡើងពី ១៩,៦ នៅ ឆ្នាំ២០០០ ដល់ ២៦,៥ នៅឆ្នាំ ២០១៨ ។

**១៩.** ដោយមានកិច្ចខិតខំប្រឹងប្រែងជាប្រចាំរបស់រាជរដ្ឋាភិបាល, កម្ពុជាបានបំពេញលក្ខខណ្ឌតម្រូវរបស់អង្គការសហប្រជាជាតិលើគ្រប់លក្ខខណ្ឌវិនិច្ឆ័យទាំងអស់ សម្រាប់ចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច នៅឆ្នាំ ២០២១ [1]។ ផ្អែកតាមលក្ខខណ្ឌទាំង ៣ នេះ, នៅឆ្នាំ ២០២១ កម្ពុជាបានបំពេញលើសលក្ខខណ្ឌកំណត់

---

[1] *អង្គការសហប្រជាជាតិនៅឆ្នាំ ២០២១ បានកំណត់លក្ខខណ្ឌអប្បបរមាចំនួន ៣ សម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួចអាចចាកចេញពីក្រុមប្រទេសទាំងនេះ ដោយត្រូវមានប្រាក់ចំណូលក្នុងម្នាក់(Gross National Income per capita) ស្មើនឹង ១ ២២២ ដុល្លារអាម៉េរិក, សន្ទស្សន៍ទ្រព្យធនមនុស្ស (Human Assets Index) ស្មើនឹង ៦៦ ឬ ខ្ពស់ជាងនេះ, និង សន្ទស្សន៍គ្រោះថ្នាក់ដោយវិបត្តិសេដ្ឋកិច្ច និង បរិស្ថាន(Economic and Evironmental Vulnerability Index) ស្មើនឹង ៣១ ឬ ទាបជាងនេះ ។ ដើម្បីចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច, ប្រទេសនោះ ត្រូវបំពេញលក្ខខណ្ឌ ២ ក្នុងចំណោមលក្ខខណ្ឌតម្រូវទាំង ៣ ខាងលើនេះ ឬ ត្រូវមានប្រាក់ចំណូលក្នុងម្នាក់យ៉ាងតិចស្មើនឹង ២ ដង នៃប្រាក់ចំណូលក្នុងម្នាក់ ដែលកំណត់ដោយអង្គការសហប្រជាជាតិនៅក្នុងការវាយតម្លៃចំនួន ២ ដង រៀងរាល់ ៣ ឆ្នាំ ម្ដង ។ ផ្អែកលើនេះ, កម្ពុជានឹងត្រូវវាយតម្លៃម្ដងទៀតនៅឆ្នាំ ២០២៤ ហើយនឹងអាចចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួចនៅឆ្នាំ ២០២៧ ។*

ពោល គឺប្រាក់ចំណូលក្នុងម្នាក់របស់កម្ពុជា ស្មើនឹង ១ ៣៧៧ ដុល្លារ, សន្ទស្សន៍ទ្រព្យធនមនុស្សស្មើ ៧៤,៣ និង សន្ទស្សន៍ គ្រោះថ្នាក់ដោយវិបត្តិសេដ្ឋកិច្ច និង បរិស្ថាន ស្មើនឹង ៣០,៦ ។ យោងតាមទិន្នន័យនៅឆ្នាំ ២០២២ របស់អង្គការសហប្រជាជាតិ, កម្ពុជាសម្រេចបានភាពប្រសើរឡើងកាន់តែខ្ពស់ ដោយប្រាក់ចំណូលក្នុងមួយម្នាក់ កើនដល់ ១ ៤៥៩ ដុល្លារអាម៉េរិក, សន្ទស្សន៍ទ្រព្យធនមនុស្ស ៧៤,៤៣ និង សន្ទស្សន៍គ្រោះថ្នាក់ដោយវិបត្តិ សេដ្ឋកិច្ច និង បរិស្ថាន ៣០ ។ ការណ៍នេះ បង្ហាញថា កម្ពុជានឹងចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច ដោយជោគជ័យ ត្រឹមឆ្នាំ ២០២៧ ។

## ១.៣. និន្នាការសកលធំៗដែលមានឥទ្ធិពលមកលើកម្ពុជា

ក្នុងបរិការណ៍បច្ចុប្បន្ន និង រយៈពេលមធ្យម និង វែង, ពិភពលោកនឹងប្រឈមនឹងនិន្នាការថ្មីធំៗ ដែលមាន ផលប៉ះពាល់លើគ្រប់ទិដ្ឋភាពធុរកិច្ច, សង្គម-សេដ្ឋកិច្ច, និង នយោបាយ ។ និន្នាការធំៗជាច្រើនមានលក្ខណៈ សកល និង ជះឥទ្ធិពលទៅលើប្រទេសជាច្រើន រួមទាំងកម្ពុជាផង តាមយន្តការផ្សេងៗគ្នា ។ នៅចំពោះមុខនៃការ ប្រែប្រួលចម្បងៗដែលបង្កឱ្យមានការព្រួយបារម្ភ, និន្នាការទាំងនោះ ក៏អាចផ្តល់ជាកាលានុវត្តភាពសម្រាប់ធ្វើបរិវត្ត កម្ម និង កែទម្រង់ចាំបាច់នានា តាមរយៈការបង្កើតបរិយាកាសល្អ ប្រកបដោយភាពច្បាស់លាស់ សម្រាប់ទាក់ទាញ ការវិនិយោគដែលមានគុណភាពខ្ពស់ ដែលមានចរិតជាការវិនិយោគរយៈពេលវែង សំដៅប្រែក្លាយកម្ពុជា ជាទីតាំង ផលិតកម្ម, និង ជាប្រទេសផ្គត់ផ្គង់ផលិតផលដល់ទីផ្សារតំបន់ និង សកល ។ និន្នាការធំៗ និង ឥទ្ធិពលនៃនិន្នាការ ទាំងនេះ មានដូចខាងក្រោម ÷

### ១.៣.១. និន្នាការផ្នែកនយោបាយ

ការកើនឡើងនៃភាពតានតឹងភូមិសាស្ត្រនយោបាយមានឥទ្ធិពលដោយផ្ទាល់លើសេដ្ឋកិច្ច និង ពាណិជ្ជកម្ម អន្តរជាតិ ជាពិសេស ប្រទេសដែលមានសេដ្ឋកិច្ចតូច, បើកចំហ និង ដែលពឹងអាស្រ័យជាចម្បងលើការនាំចេញ ។ ការកើនឡើងនៃកម្តៅភូមិសាស្ត្រនយោបាយនេះ បានប្រែក្លាយទៅជាសង្គ្រាមពាណិជ្ជកម្ម, ការគាំពារនិយម និង ជាតិនិយមជាសកល, ព្រមទាំងបង្កឱ្យមានសង្គ្រាម ដែលរុញច្រានស្ថានភាពសេដ្ឋកិច្ចឱ្យធ្លាក់ក្នុងស្ថានភាពកាន់តែ ធ្ងន់ធ្ងរ ។ ភាពតានតឹងភូមិសាស្ត្រនយោបាយនេះ មានផលប៉ះពាល់ជាអវិជ្ជមានលើលំហូរពាណិជ្ជកម្មអន្តរជាតិ និង ការវិនិយោគផ្ទាល់ពីបរទេស, ការឡើងថ្លៃថាមពលដែលជាធាតុចូលដ៏សំខាន់មិនអាចខ្វះបានសម្រាប់គ្រប់សកម្មភាព សេដ្ឋកិច្ច និង សង្គម, ការកើនឡើងថ្លៃដឹកជញ្ជូន និង ឡូជីស្ទីក, ការបង្អាក់ការផ្គត់ផ្គង់ធាតុចូល សម្រាប់ដំណើរការ ផលិតកម្ម, ការកើនឡើងនៃអតិផរណា, និង ការកើនឡើងនៃអសន្តិសុខស្បៀង ជាដើម ។

### ១.៣.២. និន្នាការផ្នែកសង្គម-សេដ្ឋកិច្ច

ប៉ូលសេដ្ឋកិច្ចបានលេចឡើងកាន់តែច្បាស់ បន្ទាប់ពីការនាំមុខផ្នែកសេដ្ឋកិច្ចរបស់ប្រទេសលោកខាងលិច មានការថមថយជាបន្តបន្ទាប់ ។ តំបន់ដែលមានសេដ្ឋកិច្ចកំពុងលូតលាស់ឆាប់រហ័ស ដែលភាគច្រើនត្រូវបានចាត់ ទុកជារោងចក្ររបស់ពិភពលោកកំពុងវិនិយោគយ៉ាងច្រើនទៅលើការអភិវឌ្ឍវិស័យឧស្សាហកម្មរបស់ខ្លួន ហើយ តំបន់ទាំងនេះ ត្រូវបានរំពឹងថា នឹងដើរតួជាដៃគូប្រកួតប្រជែង និង អ្នកផ្គត់ផ្គង់ដ៏សំខាន់ក្នុងសេដ្ឋកិច្ចសកល ។

ជាមួយនេះ, ប្រទេសចិន និង ឥណ្ឌា ត្រូវបានរំពឹងថា នឹងដណ្តើមយកតំណែងជាសេដ្ឋកិច្ចធំជាងគេរបស់ពិភពលោកពីសហរដ្ឋអាមេរិកនៅឆ្នាំ ២០៥០ ។ ចំពោះផ្នែកសង្គម, ប្រជាសាស្ត្រមានការប្រែប្រួលយ៉ាងឆាប់រហ័ស ដោយសារប្រជាជននៅក្នុងពិភពលោកត្រូវបានព្យាករថា នឹងមានចំនួនចន្លោះពី ៩ ទៅ ១១ ពាន់លាននាក់ ហើយប្រជាជនដែលមានអាយុលើសពី ៦៥ ឆ្នាំ នឹងកើនឡើងពី ៧០៣ លាននាក់ នៅឆ្នាំ ២០១៩ ដល់ ១,៥៥ ពាន់លាននាក់ ក្នុងឆ្នាំ ២០៥០ ។ ប្រទេសអភិវឌ្ឍ និង កំពុងអភិវឌ្ឍ មាននិន្នាការប្រជាសាស្ត្រខុសគ្នា ។ ជាក់ស្តែង, នៅចន្លោះឆ្នាំ ២០១៥ និង ឆ្នាំ ២០៥០, នៅប្រទេសកំពុងអភិវឌ្ឍ មានចំនួនប្រជាជនចំណូលទាបកើនឡើង, ចំណែកឯប្រទេសអភិវឌ្ឍ ប្រឈមទៅនឹងការធ្លាក់ចុះនៃចំនួនប្រជាជន, ហើយ នៅឆ្នាំ ២០៥០ ប្រជាជននៅប្រទេសកំពុងអភិវឌ្ឍមានអាយុជាមធ្យមប្រមាណជាង ២០ ឆ្នាំ ខណៈដែលប្រទេសអភិវឌ្ឍមានប្រជាជនអាយុជាមធ្យមជាង ៥០ ឆ្នាំ ។ ការកើនឡើងនៃប្រជាជនវ័យចំណាស់មានឥទ្ធិពលអវិជ្ជមានទៅលើសេដ្ឋកិច្ចនៃប្រទេសទាំងនោះ តាមរយៈការថយចុះនៃការផ្គត់ផ្គង់កម្លាំងពលកម្ម, ការកើនឡើងនៃគម្លាតជំនាញ, ការកើនឡើងនៃបន្ទុកចំណាយលើប្រព័ន្ធសុខាភិបាល និង គាំពារសង្គម, និង ការធ្លាក់ចុះនៃមូលដ្ឋានប្រមូលពន្ធ ជាដើម ។ ទាំងនេះនឹងនាំមកនូវការផ្លាស់ប្តូរទាំងតម្រូវការនៃប្រភេទទំនិញ និង សេវាកម្ម ព្រមទាំងទីផ្សារសំខាន់ៗ ។

### ១.៣.៣. និន្នាការផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង ឌីជីថល

ប្រព័ន្ធស្វ័យប្រវត្តិកម្ម, រ៉ូបូត, និង បរិវត្តកម្មឌីជីថល គឺជាប្រភពកំណើនសេដ្ឋកិច្ច និង ជាកត្តាផលិតកម្មថ្មីក្នុងការលើកកម្ពស់សកម្មភាពសេដ្ឋកិច្ចប្រកបដោយជវភាព ។ បច្ចេកវិទ្យាថ្មីទាំងនេះ កំពុងដើរតួនាទីសំខាន់ក្នុងដំណើរការផលិតកម្ម និង មានសក្តានុពលក្នុងការជំនួសកម្លាំងពលកម្ម ដែលមានថ្លៃកើនឡើងជាបន្តបន្ទាប់ ។ ថ្លៃបច្ចេកវិទ្យាទាំងនេះមានការធ្លាក់ចុះលឿន, ខណៈដែលថ្លៃពលកម្មនៅក្នុងប្រទេសកំពុងអភិវឌ្ឍមានការកើនឡើងឆាប់រហ័ស ។ ការណ៍នេះ អាចជំរុញឱ្យប្រទេសដែលជាប្រភពនៃការវិនិយោគអាចដកគម្រោងវិនិយោគរបស់ខ្លួនទៅកាន់ប្រទេសកំណើតវិញ និង បំពាក់ប្រព័ន្ធស្វ័យប្រវត្តិ និង បច្ចេកវិទ្យាថ្មីៗ ក្នុងគ្រប់ដំណើរការផលិតកម្ម ។ និន្នាការនេះបង្កើតឱកាសចាប់យកបច្ចេកវិទ្យាថ្មីៗ ក្នុងការកាត់បន្ថយថ្លៃផលិតកម្ម, បង្កើនផលិតភាព, និង លើកកម្ពស់ភាពប្រកួតប្រជែង ព្រមទាំងទប់ស្កាត់វំហូរចេញនៃការវិនិយោគផង និង ទាក់ទាញការវិនិយោគបន្ថែមផង ។

### ១.៣.៤. និន្នាការផ្នែកបរិស្ថាន

ការប្រែប្រួលអាកាសធាតុមានការកើនឡើងគួរឱ្យព្រួយបារម្ភ ។ ប្រទេសស្ថិតនៅកោះតូចៗ និង ប្រទេសកំពុងអភិវឌ្ឍ ព្រមទាំងប្រទេសដែលមានការអភិវឌ្ឍតិចតួច ងាយរងផលប៉ះពាល់ខ្លាំងជាងគេពីការប្រែប្រួលអាកាសធាតុ ។ ដោយសារមានការកើនឡើងនៃឧស្សាហូបនីយកម្ម, ការបញ្ចេញឧស្ម័នកាបូនឌីអុកស៊ីត ($CO_2$) មានការកើនឡើងគួរឱ្យកត់សម្គាល់ ដែលជំរុញឱ្យមានការកើនឡើងសីតុណ្ហភាពជាសកល ។ ផ្អែកលើទិន្នន័យថ្មីៗ, ការបញ្ចេញឧស្ម័ននេះ មានប្រភពចេញពីឧស្សាហកម្មដែលមានចំនួន ៣២%, អគារសំណង់ ១៧,១%, កសិកម្ម ១៥,៨%, ការដឹកជញ្ជូន ១៥,៥%, ថាមពល ១៤,៩%, និង ផ្សេងៗ ៤,៧% ។ ការប្រែប្រួលអាកាសធាតុបង្កឱ្យមានហានិភ័យដល់មនុស្សជាតិ និង ប្រព័ន្ធអេកូឡូស៊ី ដូចជា ភាពខ្សត់ទឹក, ការបាត់បង់គុណភាពដីដំណាំដុះ, ការ

ធ្លាក់ចុះនៃទិន្នផលដំណាំ, ការកើនឡើងនៃការឆេះព្រៃ, និង ការបង្កឱ្យមានអស្ថិរភាពនៃការផ្គត់ផ្គង់ស្បៀងអាហារ ជាដើម ។ ជាក់ស្តែង, គ្រោះធម្មជាតិអាចបង្កការខូចខាតដល់រោងចក្រ និង ប៉ះពាល់ដល់ខ្សែច្រវាក់ផលិតកម្ម និង ខ្សែច្រវាក់ផ្គត់ផ្គង់ ដែលជះឥទ្ធិពលអវិជ្ជមានមកលើកំណើនសេដ្ឋកិច្ច និង ដាក់សម្ពាធទៅលើអតិផរណាផងដែរ ។

## ១.៤. បញ្ហាប្រឈម

ការប្រែប្រួលនៃរចនាសម្ព័ន្ធ និង និម្នាបនកម្ម សេដ្ឋកិច្ច, សង្គម និង នយោបាយ បាន និង កំពុងជះឥទ្ធិពលទៅលើសកលលោកទាំងមូល ដោយបង្កើតនូវបញ្ហាប្រឈមថ្មីៗជាច្រើន ដូចជា ការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ, សង្គ្រាមពាណិជ្ជកម្ម, ការគាំពារ និង ជាតិនិយម, ការប្រែប្រួលអាកាសធាតុ, និង ការប្រែប្រួលប្រជាសាស្ត្រដែលធ្វើឱ្យមានការកើនឡើងនៃប្រជាជនវ័យចំណាស់ ជាដើម ។ សម្រាប់រយៈពេលមធ្យម និង វែងខាងមុខនេះ, កម្ពុជាត្រូវធ្វើបរិវត្តកម្មសេដ្ឋកិច្ច និង សង្គម ដោយមានភាពប្រាកដប្រជា និង គ្រប់ជ្រុងជ្រោយដើម្បីឈានដល់ការសម្រេចបានចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ ជាប្រទេសចំណូលខ្ពស់ ។ ក្នុងដំណើរដ៏វែងឆ្ងាយនេះ, កម្ពុជានឹងជួបបញ្ហាប្រឈមធំៗមួយចំនួន ដូចខាងក្រោម ÷

**១.** ម៉ូដែលកំណើនសេដ្ឋកិច្ចបច្ចុប្បន្ននៅពឹងផ្អែកយ៉ាងខ្លាំងលើឧស្សាហកម្មអតិពលកម្ម ដែលអាចធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាជាប់អន្ទាក់ជាប្រទេសចំណូលមធ្យម ។ ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល បាន និង កំពុងបន្តកើតឡើង ដោយសារមានការប្រែប្រួលនៃនិម្នាបនកម្មសង្គម-សេដ្ឋកិច្ច ដែលបង្កឡើងដោយវិបត្តិជំងឺកូវីដ-១៩, ការកើនឡើងនៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ និង ភូមិសាស្ត្រសេដ្ឋកិច្ច, សង្គ្រាមពាណិជ្ជកម្ម, ការកើនឡើងនៃថ្លៃថាមពលដែលបង្កឡើងដោយសង្គ្រាមអ៊ុយក្រែន-រុស្ស៊ី, ការកើនឡើងនៃអតិផរណា, ការធ្លាក់ចុះនៃផលិតភាពពលកម្ម និង បញ្ហាសង្គម-សេដ្ឋកិច្ចមួយចំនួនទៀត ។ កត្តាទាំងនេះ បង្កផលប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជាដែលជាប្រទេសតូច, បើកចំហ និង ពឹងអាស្រ័យយ៉ាងខ្លាំងទៅលើសេដ្ឋកិច្ចសកល និង ពាណិជ្ជកម្មអន្តរជាតិ ក្នុងការជំរុញកំណើនសេដ្ឋកិច្ច និង ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ។

**២.** គុណភាពធនធានមនុស្សនៅមានកម្រិតមធ្យមនៅឡើយ នៅក្នុងការកសាងសេដ្ឋកិច្ចផ្អែកលើជំនាញ, បច្ចេកវិទ្យា និង នវានុវត្តន៍ ។ ធនធានមនុស្សប្រកបដោយសមត្ថភាព, ជំនាញបច្ចេកទេសវិជ្ជាជីវៈ និង មូលធនមនុស្សខ្ពស់ គឺជាកត្តាគន្លឹះសម្រាប់ភាពរឹងមាំនៃសេដ្ឋកិច្ចជាតិ, ចីរភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង ភាព-ប្រកួតប្រជែង ជាពិសេស នៅក្នុងបរិការណ៍នៃការកើនឡើងនៃការប្រកួតប្រជែងជាសកល, ឌីជីថលូបនីយកម្ម និង បច្ចេកវិទ្យាឌីជីថល ដែលជំរុញដោយបដិវត្តន៍ឧស្សាហកម្មទី ៤ ដែលក្នុងនោះ ការចាប់យកបច្ចេកវិទ្យា, ការបន្សាំបច្ចេកវិទ្យា និង ការធ្វើនវានុវត្តន៍ គឺមានសារៈសំខាន់ ក្នុងការជំរុញល្បឿននៃការធ្វើទំនើបកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិ សំដៅបង្កើនផលិតភាព, តម្លៃបន្ថែម និង ឧត្តមភាពប្រកួតប្រជែងខ្ពស់ ។ ជាមួយនឹងបរិមាណនៃការអភិវឌ្ឍធនធានមនុស្ស ក្នុងរយៈពេលជាង ៤០ ឆ្នាំ កន្លងមក, កម្ពុជានៅមានបញ្ហាមួយចំនួនពាក់ព័ន្ធនឹងសមត្ថភាព និង គុណភាពនៃការសិក្សា ដែលចាំបាច់ត្រូវពង្រឹងបន្ថែម ដើម្បីទាញយកផលប្រយោជន៍ជាអតិបរមាពីការរីកចម្រើននៃបច្ចេកវិទ្យាថ្មីៗ, លើកកម្ពស់នវានុវត្តន៍ និង អភិវឌ្ឍសេដ្ឋកិច្ចឌីជីថលឱ្យបានដល់កម្រិតខ្ពស់បំផុត ។

៣. ស្ថាប័នសាធារណៈមានការកែលម្អ, ប៉ុន្តែ នៅមិនទាន់មានប្រសិទ្ធភាពខ្ពស់នៅឡើយក្នុងការសម្របសម្រួល និង ការអនុវត្តគោលនយោបាយ ។ គុណភាពស្ថាប័នរឹងមាំ បង្កើនប្រសិទ្ធភាពនៃការអនុវត្តវិធាននៃច្បាប់, ការគោរពច្បាប់, ប្រព័ន្ធយុត្តិធម៌ និង ការផ្តល់សេវាសាធារណៈមានគុណភាពខ្ពស់ ឆាប់រហ័ស និង ឆ្លើយតបទាន់ពេល សម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ប្រកបដោយជោគជ័យ, បរិយាប័ន្ន, ភាពធន់ និង ចីរភាព ។ ជាក់ស្តែង, ការលើកកម្ពស់អភិបាលកិច្ចល្អ និង គុណភាពស្ថាប័នសាធារណៈខ្ពស់, ការកែលម្អបរិយាកាសវិនិយោគ, ការលើកកម្ពស់គុណភាពស្ថាប័នទីផ្សារការងារ, និង ការលើកកម្ពស់រដ្ឋបាលពន្ធ ជាដើម រួមចំណែកយ៉ាងខ្លាំងដល់ការកាត់បន្ថយថ្លៃដើម និង ពេលវេលា ព្រមទាំងបង្កើនប្រសិទ្ធផលសេដ្ឋកិច្ច ។ ទោះបីគុណភាពស្ថាប័ន និង អភិបាលកិច្ច ត្រូវបានលើកកម្ពស់ជាបន្តបន្ទាប់, ការអនុវត្តជាក់ស្តែងនៅមានបញ្ហាប្រឈម ដែលចាំបាច់ត្រូវបន្តពង្រឹងបន្ថែម ដើម្បីបង្កើនប្រសិទ្ធភាព និង ភាពស្អាតស្អំ, ពង្រឹងយុត្តិធម៌សេដ្ឋកិច្ច សង្គម និង លើកកម្ពស់ការអភិវឌ្ឍជាតិជារួម ។

៤. ហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង នៅមិនទាន់គ្រប់គ្រាន់សម្រាប់ទ្រទ្រង់តម្រូវការនៃការអភិវឌ្ឍកម្រិតខ្ពស់ ។ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ដូចជា ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន, ប្រព័ន្ធឡូជីស្ទិក, ប្រព័ន្ធថាមពល និង ប្រព័ន្ធធារាសាស្ត្រ ជាដើម នៅបន្តជួបបញ្ហាប្រឈម ដែលត្រូវដោះស្រាយក្នុងល្បឿនលឿន និង ទំហំថ្មីមួយ ដើម្បីទ្រទ្រង់ដល់ដំណើរការផលិតកម្ម និង ខ្សែច្រវាក់តម្លៃនៃវិស័យឧស្សាហកម្ម, កសិ-ឧស្សាហកម្ម និង ឧស្សាហកម្មគាំទ្រ សំដៅជំរុញពិពិធកម្ម, និង បង្កើនប្រសិទ្ធផល, ប្រសិទ្ធភាព, ផលិតភាព និង ឧត្តមភាពប្រកួតប្រជែងខ្ពស់ ព្រមទាំងទាក់ទាញការវិនិយោគ និង ពង្រីកការតភ្ជាប់នៃហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដើម្បីសម្រួលពាណិជ្ជកម្មផ្ទៃក្នុង និង ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ ការធ្វើពិពិធកម្ម ជាពិសេស វិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម ដើរតួនាទីសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ, ការបង្កើតការងារ និង ប្រាក់ចំណូល, ការបង្រួមវិសមភាពសេដ្ឋកិច្ច, និង ការពង្រឹងសន្តិសុខស្បៀង នៅកម្ពុជា ។

៥. សេវាសុខាភិបាលនៅមានចំណាយខ្ពស់ និង គុណភាពនៅមានកម្រិត ។ ទោះបីមានការកែលម្អមួយកម្រិតធំដែលបង្ហាញច្បាស់ តាមរយៈការឆ្លើយតបដោយប្រសិទ្ធភាពទៅនឹងវិបត្តិជំងឺកូវីដ-១៩ ក៏ដោយ, ប្រព័ន្ធសុខាភិបាលដែលជាវិស័យអាទិភាពខ្ពស់ នៅមានបញ្ហាប្រឈម ដែលចាំបាច់ត្រូវដោះស្រាយក្នុងស្មារតីបុរេសកម្ម បន្ទាន់ និង ជាប្រចាំ ដើម្បីបង្កើនគុណភាពសេវាសុខាភិបាល ឱ្យកាន់តែខ្ពស់ សំដៅលើកកម្ពស់សុខភាពសាធារណៈ សម្រាប់បង្កើនផលិតភាពការងារផង និង កាត់បន្ថយការនាំចូលសេវាសុខាភិបាលផង ។ ជាមួយនេះ, នៅថ្ងៃអនាគតកម្ពុជានឹងប្រឈមនឹងការកើនឡើងនៃតម្រូវការសេវាសុខាភិបាល ដោយសារមានកើនឡើងនៃចំនួនប្រជាជនវ័យចំណាស់ តាមរយៈការប្រែប្រួលនៃប្រជាសាស្ត្រ និង ការលេចឡើងនៃជំងឺឆ្លងនានា ។ ការណ៍នេះ ទាមទារឱ្យគោលនយោបាយសុខាភិបាលកម្ពុជាមានការគិតគូរលើគ្រប់ទិដ្ឋភាព, ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល, អភិបាលកិច្ច, ធនធានមនុស្ស ដែលមានមូលធនមនុស្ស និង ជំនាញវិជ្ជាជីវៈ ប្រកបដោយក្រមសីលធម៌ខ្ពស់, ការពង្រឹងគុណភាព និង ការផ្តល់សេវា, ការបង្កើតមន្ទីរពេទ្យជាតិថ្នាក់តំបន់ ប្រកបដោយសមត្ថភាព និង គុណភាព, និង

ហិរញ្ញវត្ថុ ។

**៦.** ការសន្សំនៅក្នុងស្រុកនៅមានកម្រិតទាប សម្រាប់គាំទ្រដល់ការវិនិយោគក្នុងស្រុកសម្រាប់រយៈពេលវែង និង ពង្រឹងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ។ វិស័យហិរញ្ញវត្ថុ ដើរតួនាទីសំខាន់ក្នុងវិស័យ ពិតនៃសេដ្ឋកិច្ច និង ជាប្រភពហិរញ្ញវត្ថុសម្រាប់ជំរុញការវិនិយោគ, កំណើនសេដ្ឋកិច្ច និង ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ។ ទោះបីវិស័យនេះមានការអភិវឌ្ឍគួរឱ្យកត់សម្គាល់ក៏ដោយ, វិស័យហិរញ្ញវត្ថុកម្ពុជា នៅបន្តមានបញ្ហាប្រឈមមួយចំនួន ដែលត្រូវដោះស្រាយ សំដៅកែលម្អវិស័យនេះ ឱ្យកាន់តែមានការអភិវឌ្ឍមួយកម្រិតថ្មីថែមទៀត ។ បញ្ហាប្រឈមក្នុងវិស័យនេះ មានដូចជា ការផ្គត់ផ្គង់ និង តម្រូវការ ហិរញ្ញប្បទាននៅមានកម្រិតទាប, ដុល្លាររូបនីយកម្មនៅបន្តមានកម្រិតខ្ពស់ ដែលធ្វើកម្ពុជាបាត់បង់នូវប្រសិទ្ធភាពនៃការប្រើប្រាស់គោលនយោបាយរូបិយវត្ថុសម្រាប់ជំរុញសកម្មភាពសេដ្ឋកិច្ច និង ការនាំចេញរបស់កម្ពុជា, អត្រាការប្រាក់មានកម្រិតខ្ពស់ ជាពិសេស ក្នុងបរិការណ៍នៃជំងឺកូវីដ-១៩, ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និង ហិរញ្ញវត្ថុឌីជីថលនៅមានកម្រិតទាប, ផលិតផលហិរញ្ញវត្ថុមានលក្ខណៈប្រមូលផ្តុំ, ការជឿទុកចិត្តរបស់ប្រជជនលើវិស័យធនាគារនៅមានកម្រិត ដែលធ្វើឱ្យការសន្សំក្នុងស្រុក បន្តមានកម្រិតទាប និង បំណុលគេហជននៅមានកម្រិតខ្ពស់ ។

**៧.** ការគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថាន ត្រូវបានកែលម្អគួរឱ្យកត់សម្គាល់ តាមរយៈ ការដាក់ចេញគោលនយោបាយជាតិ សម្រាប់គ្រប់គ្រង និង ធ្វើការកែទម្រង់លើវិស័យទាំងនេះ ។ យ៉ាងណាក៏ដោយ, បញ្ហាប្រឈម ក្នុងវិស័យនេះ មានច្រើន ដោយសារតម្រូវការនៃការអភិវឌ្ឍ និង ការប្រែប្រួលអាកាសធាតុ ជាដើម ដែលទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែម និង គំនិតផ្តួចផ្តើមប្រកបដោយបរិវត្តកម្ម និង នវានុវត្តន៍ ដើម្បីធានាតុល្យភាពនៃការអភិវឌ្ឍ និង ចីរភាព នៃធនធានធម្មជាតិ និង បរិស្ថាន ។ ក្នុងន័យនេះ, គ្រប់គោលនយោបាយអភិវឌ្ឍជាតិ តម្រូវឱ្យមានការគិតគូរអំពីចីរភាព ហើយការជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល មានសក្តានុពលខ្ពស់ក្នុងការបង្កើនប្រសិទ្ធផលនៃការប្រើប្រាស់ធនធានធម្មជាតិ និង ការកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន ។

### ១.៥. កាលានុវត្តភាព

បរិការណ៍សកល និង ក្នុងប្រទេស នាពេលបច្ចុប្បន្ន ផ្តល់ឱ្យកម្ពុជានូវកាលានុវត្តភាពសំខាន់ៗ ដូចតទៅ ÷

**១.** ក្នុងបរិការណ៍នៃការប្រកួតប្រជែងលើផ្នែកភូមិសាស្ត្រនយោបាយ សេដ្ឋកិច្ច និង ពហុប៉ូល, ការបន្តពង្រឹងស្មារតីសន្តិសហវិជ្ជមាន ដោយកសាងទំនាក់ទំនងល្អជាមួយបណ្តាប្រទេសដៃគូ និង ការពង្រីកទំនាក់ទំនងការទូតបន្ថែមប្រកបដោយភាពប៉ិនប្រសប់ ដើរតួនាទីសំខាន់ ក្នុងការជំរុញពាណិជ្ជកម្មអន្តរជាតិ, ការវិនិយោគ, ការធ្វើពិពិធកម្មសេដ្ឋកិច្ច, ការផ្ទេរបច្ចេកវិទ្យា និង ការផ្សារភ្ជាប់កម្ពុជា កាន់តែខ្លាំងទៅនឹងខ្សែច្រវាក់ផ្គត់ផ្គង់ និង តម្លៃជាសកល ដើម្បីទាញយកប្រយោជន៍ឱ្យបានជាអតិបរមា សម្រាប់ជាតិ និង ប្រជាជន ។

**២.** ជាមួយនឹងឧត្តមភាពនៃទីតាំងភូមិសាស្ត្ររបស់កម្ពុជា, ចរន្តនៃការបន្តផ្លាស់ប្តូរទីប្រជុំទម្ងន់នៃកំណើនសេដ្ឋកិច្ចមកទ្វីបអាស៊ី បង្កើតជា **ឱកាសមាស** សម្រាប់កម្ពុជាក្នុងការអភិវឌ្ឍ និង ការធ្វើទំនើបកម្មឧស្សាហកម្មកម្ពុជា, ឧស្សាហូបនីយកម្ម, ពិពិធកម្មសេដ្ឋកិច្ច, ការកើនឡើងផលិតកម្ម និង សេវាកម្ម ព្រមទាំងការបង្កើនការ

តភ្ជាប់សេដ្ឋកិច្ចកម្ពុជាទៅនឹងសេដ្ឋកិច្ចតំបន់ និង សកល កាន់តែខ្លាំងថែមទៀត ប្រកបដោយជវភាព និង សក្តានុពល សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជា ។ ការធ្វើសមាហរណកម្មជាមួយនឹងសេដ្ឋកិច្ចនៃប្រទេសក្នុងតំបន់កំពុងមានជវភាពខ្ពស់ ។

**៣.** ភាគលាភសន្តិភាពនឹងត្រូវប្រើប្រាស់ សម្រាប់វឌ្ឍនភាពផ្នែកសេដ្ឋកិច្ច និង សង្គម ។ ការរក្សាបានសុខសន្តិភាព និង ស្ថិរភាពនយោបាយ បានបង្កើតមូលដ្ឋានគ្រឹះដ៏រឹងមាំ និង បង្កើន បរិយាកាសល្អ សម្រាប់ជំរុញសម្ទុះនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច, ការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ការលើកកម្ពស់វិនិយោគឯកជន និង ធុរកិច្ច ដែលជាចន្ទល់កំណើនសេដ្ឋកិច្ច និង ការបង្កើតការងារ សម្រាប់ប្រជាជនកម្ពុជា ។

**៤.** ការពង្រឹងតួនាទីនៃវិស័យហិរញ្ញវត្ថុ ជាមូលដ្ឋានសម្រាប់ហិរញ្ញប្បទានអភិវឌ្ឍ ។ កម្ពុជាមានសក្តានុពលខ្ពស់ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ រួមមាន ការបន្តបង្កើនភាពស៊ីជម្រៅនៃអន្តរការីយកម្មហិរញ្ញវត្ថុ, ការលើកកម្ពស់វិស័យធានារ៉ាប់រង, ការអភិវឌ្ឍទីផ្សារមូលបត្រ និង បោះផ្សាយលក់មូលបត្រសាធារណៈ ជាដើម ។ ប្រព័ន្ធធនាគារបានបន្តអភិវឌ្ឍជាលំដាប់ ដោយផ្តល់លទ្ធភាពទូលំទូលាយ ក្នុងការបំពេញតម្រូវការសេវាហិរញ្ញវត្ថុនៅក្នុងប្រទេស និង ឆ្លើយតបនឹងតម្រូវការនៃការធ្វើសមាហរណកម្មសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្នុងតំបន់ ។ ការធ្វើបរិវត្តកម្មឌីជីថលនៃសេវាហិរញ្ញវត្ថុ នឹងគាំទ្រការអនុវត្តគោលនយោបាយសេដ្ឋកិច្ចឌីជីថល និង បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច និង បរិយាប័ន្នហិរញ្ញវត្ថុ ។

**៥.** ការអភិវឌ្ឍសមត្ថភាពនៃឧស្សាហកម្មគាំទ្រក្នុងស្រុក ។ ឧស្សាហកម្មប្រភេទនោះ ជួយឱ្យវិស័យឧស្សាហកម្ម បង្កើតជាកាលានុវត្តភាពខ្ពស់ ក្នុងបង្កើនតម្លៃបន្ថែម និង ការលើកកម្ពស់ភាពប្រកួតប្រជែងនៃឧស្សាហកម្មកម្ពុជា តាមរយៈការផ្គត់ផ្គង់ធាតុចូលសម្រាប់ដំណើរការផលិតកម្ម និង ការផ្តល់ផលប្រយោជន៍ជាច្រើនទៀត ដូចជា ការផ្គត់ផ្គង់លឿនមានប្រសិទ្ធផល និង ប្រសិទ្ធភាពខ្ពស់, ការចែករំលែកបច្ចេកវិទ្យា និង ផ្តល់ព័ត៌មានអំពីកត្តាផលិតកម្មជាដើមដល់ឧស្សាហកម្មដទៃទៀត ។ ការណ៍នេះ នឹងកាត់បន្ថយថ្លៃដើម, បង្កើនប្រសិទ្ធ- ផល និង ផលិតភាព, និង បង្កើនភាពប្រកួតប្រជែង ។

**៦.** ការអភិវឌ្ឍវិស័យឌីជីថល ដើម្បីកាលានុវត្តភាព និង វិស័យថ្មី សម្រាប់ទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ចកម្ពុជា ។ ការរីកចម្រើនផ្នែកបច្ចេកវិទ្យា និង ឌីជីថលូបនីយកម្ម ផ្តល់ឱកាសថ្មី ក្នុងការបង្កើតមុខរបរ និង ធុរកិច្ចថ្មីៗជាច្រើន ព្រមទាំងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល នៅកម្ពុជា ដែលការណ៍នេះ នឹងរួមចំណែកដល់ការកសាង **ម៉ូដែលកំណើនថ្មី** ផ្អែកលើជំនាញ បច្ចេកវិទ្យា និង នវានុវត្តន៍ ។ ដើម្បីចាប់យកកាលានុវត្តភាពនេះឱ្យបានជាអតិបរមា, ការពង្រឹងកម្មវិធីបង្កើនជំនាញ (Upskilling) និង ការរៀបចំជំនាញឡើងវិញ (Reskilling) នឹងរួមចំណែកលើកកម្ពស់ផលិតភាពការងារ និង បង្កើនសមត្ថភាពកម្លាំងពលកម្មកម្ពុជា សម្រាប់ឱកាសការងារល្អ និង ធុរកិច្ចថ្មីៗទាំងនេះ ។

**៧.** ភាគលាភប្រជាសាស្ត្រផ្តល់កាលានុវត្តភាពសម្រាប់កម្ពុជា ក្នុងការធ្វើអតិបរមានីយកម្មផលលាភប្រជាសាស្ត្រ, ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល និង សង្គមឌីជីថល, ការផ្ទេរបច្ចេកវិទ្យា, ការបង្កើតផលិតភាពកម្លាំង

ពលកម្ម, និង ការធ្វើឱ្យប្រសើរឡើងនៃការប្រកួតប្រជែងកម្ពុជា សម្រាប់ជំរុញការលើកកម្ពស់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ឱ្យសម្រេចបានការអភិវឌ្ឍខ្ពស់មួយកម្រិតថ្មីជាបន្តបន្ទាប់ ប្រកបដោយបរិយាប័ន្ន, ភាពធន់ និង ចីរភាព ។

## ១.៦. ការសម្លឹងទៅមុខ ២៥ ឆ្នាំ នៃយុទ្ធសាស្ត្របញ្ចកោណ ដើម្បីឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០

ក្នុងរយៈពេល ២៥ ឆ្នាំ ខាងមុខ, យុទ្ធសាស្ត្របញ្ចកោណនឹងត្រូវអនុវត្ត ប្រកបដោយភាពប្រទាក់ក្រឡាគ្នា បុរេសកម្ម និង ច្បាស់លាស់ ដើម្បីកសាងកម្ពុជាទំនើបថ្មីមួយ ដូចខាងក្រោម ÷

**១.** កម្ពុជាជា “**សង្គមជាតិមួយដ៏រស់រវើក**” ដែលមានសុខសន្តិភាព, ស្ថិរភាពនយោបាយ និង សណ្តាប់ធ្នាប់សាធារណៈ, ការគោរពច្បាប់ មាននីតិរដ្ឋ និង យុត្តិធម៌សង្គម, ជារដ្ឋរឹងមាំដែលមានឯករាជ្យ, អធិបតេយ្យ, បូរណភាពទឹកដីពេញលេញ, ភាពជាម្ចាស់រឹងមាំ, អត្តសញ្ញាណជាតិជាក់លាក់, កិត្យានុភាពខ្ពស់ត្រដែត, ស្មើភាពស្មើសិទ្ធិលើឆាកអន្តរជាតិ, និង ជារដ្ឋប្រជាធិបតេយ្យ ដែលមានអភិបាលកិច្ចល្អ និង ស្ថាប័នរឹងមាំ ប្រកបដោយតម្លាភាព គណនេយ្យភាព និង ជវភាពនៃប្រព័ន្ធតួអង្គតែមួយ ។

**២.** កម្ពុជាជា “**ប្រទេសមានចំណូលខ្ពស់ និង មានសេដ្ឋកិច្ចធន់រឹងមាំ**” ប្រកបដោយប្រសិទ្ធភាព ភាពប្រកួតប្រជែង បើកចំហ សមធម៌ បរិយាប័ន្ន និង ចីរភាព ដោយរដ្ឋប្រកាន់យកតួនាទីជាយុទ្ធសាស្ត្រវិទូ ជាអ្នកដឹកនាំ និង ជាអ្នកគ្រប់គ្រងការអភិវឌ្ឍ, ការការពារកម្មសិទ្ធិ និង ទ្រព្យសម្បត្តិឯកជន ព្រមទាំងគាំទ្រ និង លើកកម្ពស់ការអភិវឌ្ឍវិស័យឯកជន, ការបន្តបើកចំហឆ្ពោះទៅខាងក្រៅដោយពង្រឹង និង ពង្រីកក្របខណ្ឌពាណិជ្ជកម្ម ទាំងទ្វេភាគី និង ពហុភាគី, និង ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ពិពិធកម្មសេដ្ឋកិច្ច, ការលើកកម្ពស់សេដ្ឋកិច្ចឌីជីថល និង ភាពរឹងមាំនៃវិស័យហិរញ្ញវត្ថុ ។

**៣.** ប្រជាជនកម្ពុជា “**មានចំណេះដឹងខ្ពស់ និង ជំនាញមួយជីវិត**” ប្រកបដោយអំណត់ធន់, សហគ្រិនភាព នវានុវត្តន៍ និង សីលធម៌ប្រពៃណី ដោយរដ្ឋធានាបាននូវសេវាអប់រំជាមូលដ្ឋាន សម្រាប់ទាំងអស់គ្នាយ៉ាងតិចត្រឹមថ្នាក់ទី ៩, បំពាក់ជំនាញ និង បច្ចេកវិទ្យា ដែលជាតម្រូវការទីផ្សារការងារ និង ធុរកិច្ច, ពង្រឹងការបណ្តុះបណ្តាលជំនាញ និង ការផ្លាស់ប្តូរជំនាញស្របនឹងតម្រូវការទីផ្សារការងារ, ពង្រឹងគុណភាពវិស័យឧត្តមសិក្សាឱ្យក្លាយជាមូលធនបញ្ញាជាតិ និង ឃ្លាំងពុទ្ធិសកល, និង យកចិត្តទុកដាក់លើជីវភាពគ្រូបង្រៀន, បុគ្គលិកសិក្សា និង សាស្ត្រាចារ្យ ។

**៤.** ប្រជាជនកម្ពុជា “**រស់នៅក្នុងសេចក្តីថ្លៃថ្នូរ, សុភមង្គល និង ទទួលបានយុត្តិធម៌សង្គម ប្រកបដោយសមធម៌, ស្មើសិទ្ធិស្មើឱកាស**” ក្នុងសង្គមជាតិ ដោយរដ្ឋផ្តល់សារៈសំខាន់ខ្ពស់ លើការរៀបចំប្រព័ន្ធសន្តិសុខសង្គម និង ជំនួយសង្គមរឹងមាំ, ការលើកកម្ពស់វិស័យធានារ៉ាប់រង, ការពង្រឹង និង ធ្វើទំនើបកម្មប្រព័ន្ធសុខាភិបាល, ការយកចិត្តទុកដាក់លើវិស័យកីឡា និង សុខភាពសាធារណៈ, និង ការលើកកម្ពស់សង្គមឌីជីថល ។

**៥.** កម្ពុជាជាប្រទេសដែលមាន “**បរិស្ថានរូបវន្ត និង ធម្មជាតិ ប្រកបដោយសុខដុមភាព, បរិយាប័ន្ន និង តុល្យភាពរវាងការអភិវឌ្ឍ និង ការអភិរក្ស**” ធនធានធម្មជាតិ សម្រាប់ការរស់នៅ ប្រកបដោយផាសុកភាព ដោយរដ្ឋផ្តល់សារៈសំខាន់ខ្ពស់ចំពោះការរៀបចំប្រព័ន្ធទឹកស្អាត, ប្រព័ន្ធធារាសាស្ត្រតាមបែបទំនើប និង ស្វ័យប្រវត្តិ, ការ

ទប់ទល់ និង ការកសាងប្រព័ន្ធសម្របខ្លួនរឹងមាំទៅនឹងការប្រែប្រួលអាកាសធាតុ, ការប្រើប្រាស់ប្រព័ន្ធអេកូឡូស៊ី ប្រកបដោយចីរភាព, ការបំពាក់បច្ចេកវិទ្យាទាន់សម័យក្នុងវិស័យកសិកម្ម, និង ការគ្រប់គ្រងធនធានធម្មជាតិ ដោយគិតគូរដល់តុល្យភាពបរិស្ថាន ។

ក្នុងបរិការណ៍ក្រោយការរីករាលដាលនៃជំងឺកូវីដ-១៩ និង ការប្រែប្រួលថ្មីនៃភូមិសាស្ត្រនយោបាយសកល, កម្ពុជាកំពុងឈរជើងសាជាថ្មី ក្នុងបេសកកម្មអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ម៉្យាងដើម្បីស្តារឡើងវិញនូវការខាតបង់បណ្តាលមកពីវិបត្តិជំងឺកូវីដ-១៩ និងវិបត្តិសកលផ្សេងៗទៀត និងម៉្យាងទៀត ដើម្បីពូនជ្រំកម្លាំងសាជាថ្មីឡើងវិញ ដើម្បីឈានទៅសម្រេចឱ្យបាននូវ“**ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០**” ខាងលើ ខណៈដែលគោលដៅឆ្នាំ ២០៣០ នឹងត្រូវខិតខំជាអតិបរិមា ដើម្បីសម្រេចតាមការគ្រោងទុក ។ ការដាក់ចេញនូវ“**យុទ្ធសាស្ត្របញ្ចកោណ**” ជាបន្ត ត្រូវបានគិតគូរក្នុងការសម្រេចគោលដៅរយៈពេលវែង និង អនុវត្តជាដំណាក់កាលៗ ដោយពង្រីកវិសាលភាព, សម្រិតសម្រាំង, ធ្វើអាទិភាពម៉ូ, ព្រមទាំងកែលម្អគោលនយោបាយ និង យន្តការអនុវត្ត ទៅតាមការប្រែប្រួលនៃបរិការណ៍ជាតិ អន្តរជាតិ និង ដំណាក់កាលនីមួយៗនៃការអភិវឌ្ឍ ដូចគ្នាទៅនឹងយុទ្ធសាស្ត្រចតុកោណ, ប៉ុន្តែ នឹងរក្សាជានិច្ចនូវរចនាសម្ព័ន្ធប្រទាក់ក្រឡាគ្នា ។ “**យុទ្ធសាស្ត្របញ្ចកោណ**” នឹងបន្ថែមនូវគោលដៅចីរភាព, បង្កើតបរិយាកាសអំណោយផលផ្នែកជីឱថល និង បន្ថែមចតុកោណកំណើនផ្នែកសេដ្ឋកិច្ច និង សង្គមឌីជីថល ដែលដកស្រង់មេរៀនពីការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ផង និង ជាឱកាសសម្រាប់កម្ពុជាក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច និង ការស្វែងរកនូវប្រភពកំណើនថ្មី ។ ក្នុងន័យនេះ“**យុទ្ធសាស្ត្របញ្ចកោណ**” នឹងក្លាយជាឧបករណ៍គោលនយោបាយថ្មីរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចឱ្យបានចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០ ជាប្រទេសមានចំណូលខ្ពស់ ។

### ១.៧. ភាពចាំបាច់ក្នុងការរៀបចំយុទ្ធសាស្ត្របញ្ចកោណ

ផ្អែកតាមជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រត្រីកោណ និង ចតុកោណទាំង ៤ ដំណាក់កាលក្នុងរយៈពេល ២៥ ឆ្នាំ កន្លងមក, រាជរដ្ឋាភិបាលអាចធ្វើការវាយតម្លៃបានពេញលេញ និង ត្រឹមត្រូវ លើភាពខ្លាំង និង បញ្ហាប្រឈម ដែលត្រូវបន្តដោះស្រាយឱ្យបានចប់ជាស្ថាពរ ក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១ ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា ២០១៣-២០២៨ ។ ចំណុចខ្លាំងនៃយុទ្ធសាស្ត្រត្រីកោណ និង ចតុកោណទាំង ៤ ដំណាក់កាល បានផ្តល់ក្របខណ្ឌគោលនយោបាយច្បាស់លាស់, ចំគោលដៅជាក់ស្តែង, ប្រទាក់ក្រឡាគ្នា, គ្រប់ជ្រុងជ្រោយ និង ប្រកបដោយសង្គតិភាព ព្រមទាំងគ្របដណ្តប់លើគ្រប់វិស័យអាទិភាពសំខាន់ៗ និង មានការចូលរួមគាំទ្រអនុវត្តពីគ្រប់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ដើម្បីធ្វើវិភាជន៍ធនធានឆ្ពោះទៅអាទិភាពគោលនយោបាយ និង ជាក្របខណ្ឌថ្នាក់ជាតិ ដែលមានលក្ខណៈបរិយាប័ន្ន សម្រាប់កិច្ចសហប្រតិបត្តិការជាមួយគ្រប់ដៃគូអភិវឌ្ឍ ដែលមានការពាក់ព័ន្ធ,វិស័យឯកជន និង សង្គមស៊ីវិល ។

យ៉ាងណាមិញ, ចំណុចខ្សោយនៅក្នុងនេះ គឺបញ្ហាប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រកន្លងមក ដែលពាក់ព័ន្ធទៅនឹងសមត្ថភាពស្ថាប័ន, គុណភាពស្ថាប័ន និង ប្រសិទ្ធភាពនៃការសម្របសម្រួលរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការដាក់ចេញ និង អនុវត្តវិធានការគោលនយោបាយជាក់ស្តែងក្នុងវិស័យក្រោមសមត្ថកិច្ចរបស់ខ្លួន ។ ម៉្យាង

ទៀត, សកម្មភាពអនុវត្តរបស់ក្រសួង-ស្ថាប័ននៅមានគម្លាត និង មិនបានផ្សារភ្ជាប់ល្អទៅនឹងគោលបំណងនៃយុទ្ធសាស្ត្រគោលនយោបាយ ។ បន្ថែមលើនេះ, ការផ្សព្វផ្សាយ នៅមានកម្រិត ដែលអាចរួមចំណែកដល់បញ្ហាប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រ និង គោលនយោបាយ ដែលបានដាក់ចេញនាពេលកន្លងមក ។

ដើម្បីសម្រេចបានប្រសិទ្ធភាពខ្ពស់, ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១ នេះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងទិដ្ឋភាពសំខាន់ៗមួយចំនួន ដូចខាងក្រោម ÷

**១.** ភាពចាំបាច់ ក្នុងការបន្តពង្រឹង និង ពង្រីកសមិទ្ធផល ដែលរាជរដ្ឋាភិបាលសម្រេចបានក្នុងនីតិកាលកន្លងមក ក៏ដូចជាក្នុងការបញ្ចប់ការងារសេសសល់ទាំងឡាយ នៅក្នុងក្របខណ្ឌយុទ្ធសាស្ត្រត្រីកោណ និង ចតុកោណទាំង ៤ ដំណាក់កាល តាមរយៈការបន្តពង្រឹងសុខសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម, ការគោរពច្បាប់ និង វិធាននៃច្បាប់, ការលើកស្ទួយនីតិរដ្ឋ, សិទ្ធិសេរីភាព និង សេចក្តីថ្លៃថ្នូររបស់មនុស្ស, លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និង ការអនុវត្តវិធានការជាក់ស្តែងនានា សំដៅលើកកម្ពស់កម្រិតជីវភាព និង សុខុមាលភាពរបស់ប្រជាជន ពិសេសការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃអភិបាលកិច្ច, ស្ថាប័ន និង បញ្ហាយុត្តិធម៌សង្គម ព្រមទាំងការពង្រឹងភាពស្អាតស្អំ និង គុណភាពសេវាសាធារណៈ ។

**២.** ភាពចាំបាច់ ក្នុងការបង្កើនការធ្វើពិពិធកម្មសេដ្ឋកិច្ច និង ភាពប្រកួតប្រជែងរបស់កម្ពុជា ដើម្បីពង្រឹងមូលដ្ឋាននៃកំណើនសេដ្ឋកិច្ច ដើម្បីធានាចីរភាពនៃកំណើនខ្ពស់ និង ភាពធន់នឹងការប្រែប្រួលនៃកត្តាខាងក្រៅ, ការលើកកម្ពស់ទំនាក់ទំនងអន្តរជាតិ និង ការទូត នៅក្នុងតំបន់ និង សកល ដើម្បីទាញយកផលប្រយោជន៍សេដ្ឋកិច្ចសង្គម ឱ្យបានជាអតិបរមា, ការធ្វើសមាហរណកម្មស៊ីជម្រៅទៅ ក្នុងតំបន់ និង សកល, ការបង្កើតតម្លៃបន្ថែមក្នុងវិស័យចន្ទល់កំណើនសេដ្ឋកិច្ចដែលមានស្រាប់ និង វិស័យដែលមានសក្តានុពលពាក់ព័ន្ធ, ការជំរុញការវិនិយោគក្នុងវិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម, ការជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម និង ឧស្សាហូបនីយកម្ម, ព្រម-ទាំងការបង្កើនការប្រកួតប្រជែងស្មើភាព និង ការលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជា ។

**៣.** ភាពចាំបាច់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល ឱ្យបានពេញលេញ សំដៅបង្កើតវិស័យចន្ទល់កំណើនសេដ្ឋកិច្ចថ្មីៗ, ការកសាងមូលធនមនុស្សរឹងមាំ, ការបង្កើនផលិតភាពសេដ្ឋកិច្ច, ការលើកកម្ពស់ សុខភាព និង សុខុមាលភាពប្រជាជន, ការពង្រឹងអភិបាលកិច្ចវិស័យឯកជន និង ធុរកិច្ច, ការជំរុញលើកកម្ពស់ហេដ្ឋារចនា-សម្ព័ន្ធរឹង និង ទន់, ដើម្បីឈានដល់ការបង្កើតបាននូវម៉ូដែលកំណើនថ្មី ដែលផ្អែកលើជំនាញ, បច្ចេកវិទ្យា និង នវានុវត្តន៍ ។

**៤.** ភាពចាំបាច់ ក្នុងការបន្តកែទម្រង់ស្ថាប័ន និង អភិបាលកិច្ច ឱ្យសម្រេចបានជវភាពនៃប្រព័ន្ធតួអង្គមួយ សម្រាប់ដឹកនាំ, សម្របសម្រួល និង វាយតម្លៃត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ស្របនឹងបរិការណ៍, ទាំងក្នុង និង ក្រៅប្រទេស ក៏ដូចជាសភាពការណ៍មិនអាចព្យាករជាមុនបាន ។

**៥.** ភាពចាំបាច់ ក្នុងការដាក់ចេញ និង អនុវត្តក្របខណ្ឌគោលនយោបាយ និង យុទ្ធសាស្ត្រសំខាន់ៗ ដើម្បីឈានឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០ ជាប្រទេសមានចំណូលខ្ពស់ ប្រកបដោយអារ្យធមិ

រុងរឿង ។

លើមូលដ្ឋាននេះ, រាជរដ្ឋាភិបាលបានកំណត់យកគោលដៅយុទ្ធសាស្ត្រចំនួន ៥ និងវិស័យអាទិភាពចំនួន ៥ ក្នុងការអនុវត្ត **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** នេះ ។

### គោលដៅយុទ្ធសាស្ត្រ ៥ មាន ដូចខាងក្រោម ÷

**ទី១.** បង្កើតការងារឱ្យបានកាន់តែច្រើន, ទាំងបរិមាណ និង គុណភាព, ជូនដល់ប្រជាជនកម្ពុជា ពិសេសសម្រាប់យុវជន តាមរយៈការពង្រឹងគុណភាពអប់រំទាំងជំនាញរឹង និង ជំនាញទន់ឱ្យស្របនឹង តម្រូវការក្នុងទីផ្សារការងារ, ការផ្តល់ព័ត៌មានឱ្យបានទូលំទូលាយអំពីទីផ្សារការងារ, ការកែលម្អលក្ខខណ្ឌការងារប្រកបដោយផាសុកភាព, ការលើកកម្ពស់ផលិតភាព តាមរយៈការបណ្តុះបណ្តាលជាប្រចាំ និង ការប្រើប្រាស់បច្ចេកវិទ្យាសមស្រប, ការលើកកម្ពស់សកម្មភាពពាណិជ្ជកម្ម ធុរកិច្ច និង ការជំរុញ និង ទាក់ទាញការវិនិយោគ, ទាំងក្នុងស្រុក និង ការវិនិយោគផ្ទាល់ពីបរទេស ។

**ទី២.** ធានាឱ្យបានកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំក្នុងរង្វង់ ៧% ប្រកបដោយភាពធន់នឹងវិបត្តិនានា តាមរយៈការជំរុញសម្ទុះនៃការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ដើម្បីបង្កើតចន្ទល់កំណើនថ្មីៗ, ការលើកកម្ពស់ភាពប្រកួតប្រជែង, ការថែរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការគ្រប់គ្រងអត្រាអតិផរណាឱ្យនៅទាបដើម្បីជំរុញតម្រូវការសរុបក្នុងស្រុក, ការធានាស្ថិរភាពអត្រាប្តូរប្រាក់, ការខិតខំបង្កើនទុនបម្រុងជាប្រចាំ និង ការគ្រប់គ្រងបំណុលសាធារណៈឱ្យមានចីរភាព ។

**ទី៣.** សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រឱ្យត្រឡប់មកអត្រាទាបជាង ១០% ឬ ទាបជាងនេះ ក្នុងកម្រិតជាអប្បបរមា ដើម្បីឈានដល់ការលុបបំបាត់ភាពក្រីក្ររបស់ប្រជាជនទាំងស្រុង, ការពារមិនឱ្យភាពក្រីក្រវិលត្រឡប់មកវិញ ដោយផ្តោតលើការលើកកម្ពស់ប្រសិទ្ធភាពនៃយន្តការទីផ្សារ និង ការប្រកួតប្រជែងស្មើភាព, ការបង្រួមវិសមភាពសេដ្ឋកិច្ច តាមរយៈការអនុវត្តគោលនយោបាយគាំពារសង្គម, ការកាត់បន្ថយបន្ទុកជីវភាព និង ការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព, ប្រសិទ្ធភាព និង បរិយាប័ន្ន ។

**ទី៤.** បន្តពង្រឹងសមត្ថភាព, អភិបាលកិច្ច និង លើកកម្ពស់គុណភាពស្ថាប័នឱ្យបានជាអតិបរមា, ទាំងថ្នាក់ជាតិ និង ក្រោមជាតិ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឱ្យបានកាន់តែប្រសើរដល់កម្រិតថ្មីមួយទៀត ក៏ដូចជាទ្រទ្រង់កំណើនសេដ្ឋកិច្ចសម្រាប់រយៈពេលវែង, ពង្រឹងអភិបាលកិច្ចវិស័យឯកជន និង លើកកម្ពស់បរិយាកាសអំណោយផលសម្រាប់ធុរកិច្ច, ការវិនិយោគ និង ពាណិជ្ជកម្ម ។

**ទី៥.** ធានាចីរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និង ការកសាងភាពធន់ទៅនឹងការផ្លាស់ប្តូរអាកាសធាតុដោយធ្វើអតិបរមានីយកម្មផលលាភប្រជាសាស្ត្រ និង ពង្រឹងភាពធន់នៃប្រជាសាស្ត្រ, គ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព, បង្កើនហិរញ្ញប្បទានចីរភាព និង បៃតង នៅក្នុងបណ្តុំកម្ចីសរុប ដើម្បីបង្កើនលំហូរហិរញ្ញវត្ថុឆ្ពោះទៅរកការវិនិយោគបៃតង និង សេដ្ឋកិច្ចបៃតង, ជំរុញការវិនិយោគសាធារណៈ ដែលមានភាពធន់នឹង

អាកាសធាតុ និង បង្កើនហិរញ្ញប្បទានចីរភាព, ការធានាចីរភាពបរិស្ថាន និង ការត្រៀមខ្លួនជាស្រេច ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងការប្រែប្រួលអាកាសធាតុ ។

### វិស័យអាទិភាព ៥ រួមមាន ដូចខាងក្រោម ÷

ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍសង្គម-សេដ្ឋកិច្ចបានកំណត់យកអាទិភាពចំនួន ៤ រួមមាន **ផ្លូវ ទឹក ភ្លើង** និង **មនុស្ស** ដើម្បីជំរុញការអភិវឌ្ឍប្រទេស ដែលលំដាប់នៃសារៈសំខាន់របស់អាទិភាពទាំងនេះ ត្រូវបានផ្លាស់ប្តូរទៅតាមដំណាក់កាលនីមួយៗនៃការអភិវឌ្ឍប្រទេស ។ នៅក្នុង **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** នេះ កំណត់យកអាទិភាពចំនួន ៥ រួមមាន **ផ្លូវ ទឹក ភ្លើង មនុស្ស** និង **ឌីជីថល**, ដោយមនុស្សនៅបន្តជាអាទិភាពខ្ពស់ទី ១ ហើយ **ផ្លូវ ភ្លើង ទឹក** និង **ឌីជីថល** គឺ ជាអាទិភាពបន្តបន្ទាប់តាមលំដាប់ ។ ក្នុងនីតិកាលទី ៧ នេះ, យុទ្ធសាស្ត្របញ្ចកោណផ្តោតជាចម្បងលើវិស័យអាទិភាពចំនួន ៥ ដោយតម្កល់ **មនុស្ស** ជាអាទិភាពខ្ពស់បំផុត ។ ក្នុងគោលដៅនេះ, បញ្ចកោណយុទ្ធសាស្ត្រទាំង ៥ នៃយុទ្ធសាស្ត្របញ្ចកោណ ត្រូវបានគិតគូរឡើងមានលក្ខណៈគ្រប់ជ្រុងជ្រោយ និង ម៉ត់ចត់ ឱ្យឆ្លុះបញ្ចាំងវិស័យអាទិភាពទាំង ៥ និង កិច្ចការសំខាន់ៗមួយចំនួនទៀត ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងតម្រូវការនៃអភិវឌ្ឍកម្ពុជានៅក្នុងដំណាក់កាលថ្មីនេះ ដូចខាងក្រោម ÷

**បញ្ចកោណទី ១** - ការអភិវឌ្ឍមូលធនមនុស្ស រួមមាន ១). ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា, ២). ការបណ្តុះបណ្តាលជំនាញបច្ចេកទេស, ៣). ការលើកកម្ពស់សុខភាព និង សុខុមាលភាពប្រជាជន, ៤). ការពង្រឹងប្រព័ន្ធគាំពារសង្គម និង ៥). ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសមធម៌ និង បរិយាប័ន្ន ។

**បញ្ចកោណទី ២** - ការធ្វើពិពិធកម្មសេដ្ឋកិច្ច និង ការបង្កើនភាពប្រកួតប្រជែង រួមមាន ១). ការអភិវឌ្ឍវិស័យ និង ប្រភពកំណើនសេដ្ឋកិច្ចគន្លឹះ និង ថ្មីៗ, ២). ការលើកកម្ពស់ការតភ្ជាប់ និង ការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន និង ឡូជីស្ទីក, វិស័យថាមពល, វិស័យទឹកស្អាត និង វិស័យឌីជីថល, ៣). ការកែលម្អបរិយាកាសធុរកិច្ច និង ការវិនិយោគ, ៤). ការពង្រឹងប្រសិទ្ធភាពនៃតំបន់សេដ្ឋកិច្ចពិសេស, សួនឧស្សាហកម្ម, សួនកសិ-ឧស្សាហកម្ម និង តំបន់ពាណិជ្ជកម្មសេរី, និង ៥). ការធ្វើនវានុវត្តន៍យន្តការហិរញ្ញប្បទាន និង ផលិតផលហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ការវិនិយោគ ។

**បញ្ចកោណទី ៣** - ការអភិវឌ្ឍវិស័យឯកជន និង ការងារ រួមមាន ១). ការអភិវឌ្ឍទីផ្សារការងារ, ២). ការលើកស្ទួយសហគ្រាសធុនតូច និង មធ្យម, ធុរកិច្ចថ្មី, សហគ្រិនភាព និង ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ, ៣). ការពង្រឹងភាពជាដៃគូវិស័យសាធារណៈ និង វិស័យឯកជន, ៤). ការពង្រឹងការប្រកួតប្រជែង, និង ៥). ការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុធនាគារ និង មិនមែនធនាគារ ។

**បញ្ចកោណទី ៤** - ការអភិវឌ្ឍប្រកបដោយភាពធន់, ចីរភាព និង បរិយាប័ន្ន រួមមាន ១). ការធ្វើអតិបរមា-នីយកម្មផលលាភប្រជាសាស្ត្រ, ការពង្រឹងភាពធន់ប្រជាសាស្ត្រ, និង ការលើកកម្ពស់សមភាពយេនឌ័រ, ២). ការគ្រប់គ្រងធនធានធម្មជាតិ, បេតិកភណ្ឌវប្បធម៌ និង ទេសចរណ៍ប្រកបដោយចីរភាព, ៣). ការលើកស្ទួយកសិកម្ម

និង ការអភិវឌ្ឍជនបទ, ៤). ការពង្រឹងការគ្រប់គ្រង និង ការធ្វើទំនើបកម្មនគរូបនីយកម្ម, និង ៥). ការធានាចីរភាពបរិស្ថាន និង ការរៀបចំខ្លួនឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង ។

**បញ្ចកោណទី ៥** - ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល រួមមាន **១).** ការកសាងរដ្ឋាភិបាល និង ពលរដ្ឋឌីជីថល, **២).** ការអភិវឌ្ឍធុរកិច្ចឌីជីថល ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង ប្រព័ន្ធនវានុវត្តន៍ឌីជីថល, **៣).** ការកសាង និង អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល, **៤).** ការកសាងភាពជឿជាក់លើប្រព័ន្ធឌីជីថល, និង **៥).** ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ។

## ផ្នែកទី ២

## ២.១. រចនាសម្ព័ន្ធនៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១

### ២.២. ស្នូលនៃយុទ្ធសាស្ត្រ

គោលដៅជាយុទ្ធសាស្ត្រនៃអភិបាលកិច្ច គឺការធ្វើទំនើបកម្មស្ថាប័នរដ្ឋ ដោយប្រែក្លាយរដ្ឋបាលសាធារណៈជារដ្ឋបាលទំនើប, មានសមត្ថភាព, ស្អាតស្អំ ជារដ្ឋបាលរបស់ប្រជាជន និង បម្រើផលប្រយោជន៍របស់ប្រជាជនយ៉ាងពិតប្រាកដ តាមរយៈការអនុវត្តសិទ្ធិអំណាចរដ្ឋខាងផ្នែកនយោបាយ, សេដ្ឋកិច្ច និង រដ្ឋបាល ក្នុងការដឹកនាំគ្រប់គ្រង និង ចាត់ចែងកិច្ចការប្រទេសជាតិ ជាពិសេសការធានាចីរភាពនៃតួនាទី និង ដំណើររដ្ឋបាលសាធារណៈដោយយកចិត្តទុកដាក់លើអត្ថប្រយោជន៍ប្រជាជនជាស្នូល (People-Centric), លើការកសាងជាតិ (Nation-state Building) និង លើការពង្រឹងនីតិរដ្ឋ សំដៅគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមប្រកបដោយបរិយាប័ន្ន សមធម៌ និង យុត្តិធម៌ ។

ក្នុងការអនុវត្តយុទ្ធសាស្ត្រត្រីកោណ និង យុទ្ធសាស្ត្រចតុកោណទាំង ៤ ដំណាក់កាល កន្លងមក, រាជរដ្ឋាភិបាលបានអនុវត្តការកែទម្រង់រដ្ឋដ៏ស៊ីជម្រៅ និង ទូលំទូលាយ តាមអភិក្រម "**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និង វះកាត់**" ដោយទទួលបានលទ្ធផលប្រកបដោយផ្លែផ្កា ។ លទ្ធផលនេះ សម្រេចបាន តាមរយៈ ១). ការកែទម្រង់រដ្ឋបាលសាធារណៈ ដែលរួមមាន ជាអាទិ៍ ការកែទម្រង់រចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ការលើកកម្ពស់ការគ្រប់គ្រង និង ការអភិវឌ្ឍធនធានមនុស្ស នៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ការលើកកម្ពស់គុណភាព, តម្លាភាព និង គណនេយ្យភាព នៃការផ្តល់សេវាសាធារណៈ, និង ការកែទម្រង់បៀវត្សដោយបន្តកែសម្រួល និង ដំឡើងបៀវត្សមន្ត្រីរាជការ និង ប្រាក់សោធនរបស់អតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជនជាបន្តបន្ទាប់, ២). ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយបានកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅកម្ពុជា ជាជំហានៗ ឆ្ពោះទៅរកប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលផ្តោតលើលទ្ធផល និង វិមជ្ឈការស្របតាមស្តង់ដារ និង ឧត្តមានុវត្តន៍អន្តរជាតិ ដែលជាលទ្ធផល ការអនុវត្តថវិកាមានភាពល្អប្រសើរតាម-រយៈការដាក់ចេញយុទ្ធសាស្ត្រនានា និង ការដាក់អនុវត្តនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសបានកសាងមូលដ្ឋានគ្រឹះនៃភាពជឿទុកចិត្តលើថវិកា ដែលជាកត្តាផ្តល់ផលវិជ្ជមានយ៉ាង

ពិតប្រាកដដល់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ការផ្តល់សេវាសាធារណៈ, ៣). ការអនុវត្តកម្មវិធីកែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ដែលរួមមាន ជាអាទិ៍ ការកែសម្រួលរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, ការរៀបចំប្រព័ន្ធគ្រប់គ្រង និង ការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ, ការផ្ទេរមុខងារ និង ការទទួលខុសត្រូវទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និង ការបង្កើនការផ្ទេរថវិកាពីថវិកាជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ, ៤). ការកែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ដែលរួមមាន ជាអាទិ៍ ការបន្តកសាងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាច្រើន, ការដាក់ឱ្យដំណើរការនូវសាលាឧទ្ធរណ៍តំបន់, ការលើកកម្ពស់សមត្ថភាពមន្ត្រីអនុវត្តច្បាប់ និង ស្ថាប័នក្នុងវិស័យយុត្តិធម៌, ការពង្រឹងប្រសិទ្ធភាពនៃយន្តការអធិការកិច្ច, ការលើកកម្ពស់យន្តការផ្តល់សេវាជំនួយផ្នែកច្បាប់ និង ការជំរុញការដោះស្រាយការកកស្ទះសំណុំរឿងព្រហ្មទណ្ឌនៅតាមសាលាដំបូងរាជធានី-ខេត្ត, ៥). ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ តាមរយៈការពង្រឹងសមត្ថភាពវិជ្ជាជីវៈដល់កងកម្លាំងប្រដាប់អាវុធ, ៦). ការប្រយុទ្ធប្រឆាំងអំពើពុករលួយ តាមរយៈវិធានការអប់រំ, ការបង្ការ, ទប់ស្កាត់ និង ការអនុវត្តច្បាប់បង្ក្រាបបទល្មើសពុករលួយ, ៧). ការពង្រឹងអភិបាលកិច្ចវិស័យឯកជន និង ធុរកិច្ច តាមរយៈការធ្វើអធិការកិច្ចវិស័យឯកជន និង ធុរកិច្ច ព្រមទាំងការងារកែទម្រង់តាមវិស័យដទៃទៀត ។

ទន្ទឹមនេះ, រាជរដ្ឋាភិបាលនៅបន្តជួបប្រទះបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងការត្រួតមុខងារ និង ដែនសមត្ថកិច្ច, សមត្ថភាពស្ថាប័ន និង ធនធានមនុស្សរបស់ស្ថាប័នរដ្ឋនៅមានកម្រិត; ការបែងចែកមុខងារ, សិទ្ធិអំណាច និង ការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ និង រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ នៅមិនទាន់មានភាពច្បាស់លាស់ និង សមស្រប; ការសម្របសម្រួលអន្តរស្ថាប័ននៅមិនទាន់មានភាពរហ័ស; ការជ្រើសរើស និង ការលើកទឹកចិត្តមន្ត្រីរាជការ នៅមិនទាន់សមស្របនៅឡើយ; យន្តការតាមដាន និង វាយតម្លៃការផ្តល់សេវាសាធារណៈ នៅមិនទាន់មានភាពជាក់លាក់; ការចែករំលែកព័ត៌មាន និង ទិន្នន័យនៅមានកម្រិតនៅឡើយ; គម្លាតរវាងគោលនយោបាយ និង ការអនុវត្ត; ការពង្រឹងការងារអធិការកិច្ចនៅមិនទាន់អាចអនុវត្តបានពេញលេញនៅឡើយ; ការយល់ដឹងអំពីច្បាប់នៅមានកម្រិត; សមត្ថភាពឆ្លើយតបក្នុងការផ្តល់សេវាជំនួយផ្នែកច្បាប់នៅមានកម្រិត; ក្របខ័ណ្ឌច្បាប់មួយចំនួន លែងឆ្លើយតបទៅនឹងស្ថានភាពវិវត្តជាក់ស្តែងរបស់សង្គម-សេដ្ឋកិច្ច ហើយក្របខ័ណ្ឌច្បាប់ចាំបាច់មួយចំនួនទៀត នៅមិនទាន់បង្កើតឡើង; ការបង្កើនសមត្ថភាព និង ប្រសិទ្ធភាពនៃកងកម្លាំងប្រដាប់អាវុធនៅត្រូវកែលម្អបន្ថែមទៀត, និង កង្វះខាតក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និង គោលការណ៍ណែនាំ ក្នុងការពង្រឹងអភិបាលកិច្ចវិស័យឯកជន ឱ្យបានពេញលេញ ។

ឈរលើមូលដ្ឋាននេះ, រាជរដ្ឋាភិបាល នឹងបន្តធ្វើការកែទម្រង់រដ្ឋឱ្យកាន់តែស៊ីជម្រៅ ទូលំទូលាយ មានភាពស៊ីចង្វាក់ប្រទាក់ក្រឡាគ្នា និង គាំទ្រគ្នាលើការដ្ឋានកំណែទម្រង់ស្នូលផ្នែកអភិបាលកិច្ចនានា ទន្ទឹមនឹងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ព្រមទាំងការពង្រឹងអភិបាលកិច្ចវិស័យឯកជន និង ធុរកិច្ច សំដៅធានាដល់ការលើកកម្ពស់អភិបាលកិច្ចនៃគ្រប់ស្ថាប័នគ្រប់ថ្នាក់, ការផ្តល់សេវាសាធារណៈជូនប្រជាជនប្រកបដោយប្រសិទ្ធភាព និង ការជឿទុកចិត្ត ។ ដូច្នេះ, ក្នុងនីតិកាល ទី ៧ នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងអនុវត្តនូវ ១). ការពង្រឹង និងកែទម្រង់

ស្ថាប័ន, ២). ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និង ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ, ៣). ការលើកកម្ពស់ និង ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ, ៤). ការលើកកម្ពស់ និង ការពង្រឹងប្រសិទ្ធភាពនៃច្បាប់និងប្រព័ន្ធយុត្តិធម៌, និង ៥). ការពង្រឹងអភិបាលកិច្ចវិស័យឯកជន និង ធុរកិច្ច ។

### ទី១. ការពង្រឹង និង ការកែទម្រង់ស្ថាប័ន

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺកសាងឱ្យបាននូវរដ្ឋបាលសាធារណៈ ដែលមានសមត្ថភាពខ្លាំង, ស្អាតស្អំ និង ជារដ្ឋបាលរបស់ប្រជាជន និង បម្រើផលប្រយោជន៍របស់ប្រជាជន ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ÷

**១.** ការធ្វើវិចារណកម្មមុខងារ និង រចនាសម្ព័ន្ធរបស់ស្ថាប័ន តាមរយៈការកំណត់ច្បាស់លាស់នូវមុខងារ និង ភារកិច្ចរបស់ស្ថាប័ន និង អង្គភាពក្រោមឱវាទស្ថាប័ន, ការជំរុញការធ្វើប្រតិភូកម្មអំណាច, ការកំណត់កម្រិតសិទ្ធិអំណាច, ការទទួលខុសត្រូវ និង គណនេយ្យភាពក្នុងក្របខណ្ឌនៃការដឹកនាំ, គ្រប់គ្រង និង ប្រតិបត្តិការ ក្នុងស្ថាប័ន ព្រមទាំងការកែលម្អយន្តការសម្របសម្រួលក្នុងស្ថាប័ន និង អន្តរស្ថាប័ន ។

**២.** ការសិក្សារៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់ឱ្យច្បាស់លាស់នូវសិទ្ធិអំណាច, មុខងារ និង ការទទួលខុសត្រូវរវាងថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ, និង ក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យស្របតាមប្រភេទ និង ចរិតលក្ខណៈនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដូចជារដ្ឋបាលតំបន់ទីក្រុងធំ, រដ្ឋបាលតំបន់ទីប្រជុំជន និង រដ្ឋបាលតំបន់ជនបទ ព្រមទាំងការជំរុញឱ្យមានការរៀបចំ និង ដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន នៅក្នុងប្រព័ន្ធគ្រប់គ្រងការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅលើកកម្ពស់ប្រសិទ្ធភាព នៃការគ្រប់គ្រងការផ្តល់សេវាសាធារណៈ និង ការប្រាស្រ័យទាក់ទងសាធារណៈ ។

**៣.** ការពង្រឹងភាពជាអ្នកដឹកនាំ តាមរយៈការរៀបចំ និង ការដាក់ឱ្យអនុវត្តឯកសារក្របខ័ណ្ឌសមត្ថភាពភាពជាអ្នកដឹកនាំ, ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ, ការវាយតម្លៃ និង ការទទួលស្គាល់អ្នកដឹកនាំគំរូ និង ការរៀបចំបណ្តាញអ្នកដឹកនាំក្នុងរដ្ឋបាលសាធារណៈ សំដៅលើកកម្ពស់ស្មារតីម្ចាស់ការប្រកបដោយការទទួលខុសត្រូវខ្ពស់ និង សាមគ្គីភាពផ្ទៃក្នុងស្ថាប័ន ។

**៤.** ការពង្រឹងសមត្ថភាពគ្រប់គ្រងរដ្ឋបាលសាធារណៈ តាមរយៈការរៀបចំ, ការកែលម្អ និង ការធ្វើវិសោធនកម្មច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងមុខងារសាធារណៈ, ការរៀបចំ និង ការកែលម្អហេដ្ឋារចនាសម្ព័ន្ធការងារ និង ការកំណត់ឱ្យមានសូចនាករសមិទ្ធកម្មគន្លឹះ (key performance indicator) សម្រាប់ស្ថាប័នសាធារណៈ, ព្រមទាំងការជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ការគ្រប់គ្រងព័ត៌មាន និង ទិន្នន័យមន្ត្រីសាធារណៈ ។

**៥.** ការបន្តជំរុញលើកកម្ពស់សមត្ថភាពកងកម្លាំងប្រដាប់អាវុធ តាមរយៈ ការអភិវឌ្ឍស្ថាប័ន និង កសាងធនធានមនុស្ស, យកចិត្តទុកដាក់ខ្ពស់ចំពោះជីវភាព សុខុមាលភាពរបស់កងកម្លាំងប្រដាប់អាវុធ, ព្រមទាំងជំរុញការអនុវត្តគោលនយោបាយចំពោះកងកម្លាំប្រដាប់អាវុធចូលនិវត្តន៍, បាត់បង់សមត្ថភាព ពលី, ពិការ ដោយសារបុព្វហេតុថែរក្សាការពារសន្តិសុខជាតិ ។

## ទី២. ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និង ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺការធ្វើឱ្យស្ថាប័នរដ្ឋ មានធនធានមនុស្ស ប្រកបដោយឆន្ទៈម្ចាស់ការ សមត្ថភាព និងមានជំនាញវិជ្ជាជីវៈ ស្របតាមតួនាទី និង ការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងមានធនធានសមស្រប ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព ។

ក្នុងនីតិកាលទី៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ÷

**១.** ការលើកកម្ពស់គុណាធិបតេយ្យ ក្នុងការជ្រើសរើស, ការតែងតាំង, ការដំឡើងថ្នាក់ និង ឋានន្តរស័ក្តិ ព្រមទាំងការលើកទឹកចិត្ត និង ការផ្តល់អត្ថប្រយោជន៍ផ្សេងទៀត ដល់មន្ត្រីសាធារណៈ និង អង្គភាពសាធារណៈ ជាពិសេស ការរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មក្នុងវិស័យសាធារណៈ ។

**២.** ការបន្តគិតគូរដំឡើងបៀវត្សឱ្យបានជារៀងរាល់ឆ្នាំជូនមន្ត្រីរាជការស៊ីវិល និង កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដោយផ្សារភ្ជាប់នឹងគោលការណ៍សមិទ្ធកម្ម, សមធម៌ និង សង្គតិភាព ព្រមទាំងបន្តកែសម្រួល និងដំឡើងប្រាក់សោធននិវត្តន៍អតីតមន្ត្រីរាជការ និង អតីតយុទ្ធជន ដោយបើកផ្តល់តាមប្រព័ន្ធធនាគារ ក្នុងរយៈពេល ២ សប្តាហ៍ ។

**៣.** ការពង្រឹងប្រសិទ្ធភាព នៃការគ្រប់គ្រង និង ការអភិវឌ្ឍធនធានមនុស្ស នៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការផ្តល់សិទ្ធិអំណាច និង ការទទួលខុសត្រូវឱ្យបានសមស្រប ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការជ្រើស-រើស, ការគ្រប់គ្រង, ការចាត់ចែង និង ការប្រើប្រាស់បុគ្គលិករបស់ខ្លួន ដោយផ្អែកលើទំហំការងារ និង លទ្ធភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ មានបុគ្គលិកប្រកបដោយឆន្ទៈម្ចាស់ការ, ភក្តីភាព និង មនសិការ ជំនាញវិជ្ជាជីវៈស្របតាមតួនាទី និង ការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងទទួលបានការអភិវឌ្ឍសមត្ថភាព និង ជំនាញវិជ្ជាជីវៈជាប្រចាំ ។

**៤.** ការលើកកម្ពស់គុណភាព, សមត្ថភាព និង ការផ្តល់ការគាំទ្រនានា ដល់តួអង្គបង្គោលសំខាន់ៗ នៅមូលដ្ឋាន រួមមាន មេឃុំ ចៅសង្កាត់, ស្មៀនឃុំ សង្កាត់, ប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់, មន្ត្រីសុខាភិបាលបម្រើការនៅតាមប៉ុស្តិ៍សុខភាព, មណ្ឌលសុខភាព, មន្ទីរពេទ្យបង្អែក និង គ្រូបង្រៀនសាលាចំណេះដឹងទូទៅរបស់រដ្ឋនៅគ្រប់កម្រិតនៅមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងសំណូមពរ និង សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព, តម្លាភាព និង គណនេយ្យភាព ។

**៥.** ការជំរុញនវានុវត្តន៍ និង ការច្នៃប្រឌិតក្នុងរដ្ឋបាលសាធារណៈ តាមរយៈការដាក់ឱ្យអនុវត្តយន្តការវាយតម្លៃ និង ការទទួលស្គាល់គម្រោងនវានុវត្តន៍ ក្នុងរដ្ឋបាលសាធារណៈ ដើម្បីបង្កើនប្រសិទ្ធភាព ក្នុងការអនុវត្តការងារ ។

**៦.** ការជំរុញការរៀបចំមូលដ្ឋានទិន្នន័យ និង ការជំរុញការចែករំលែក និង ផ្លាស់ប្តូរព័ត៌មាន នៅក្នុងរដ្ឋបាលសាធារណៈ នៅគ្រប់កម្រិតនៅទូទាំងប្រទេស ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និង ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់សេវាសាធារណៈ នៅក្នុងការវិវត្តដ៏ឆាប់រហ័សនៃសង្គម-សេដ្ឋកិច្ច ។

**៧.** ការបន្តកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ទៅកាន់

ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលផ្តោតលើលទ្ធផល (ឬសមិទ្ធកម្ម) និង វិមជ្ឈការ ស្របតាមស្តង់ដារ និង ឧត្តមានុវត្តន៍អន្តរជាតិ តាមរយៈការបង្កើននូវភាពជឿទុកចិត្តនៃថវិកា, គណនេយ្យភាពហិរញ្ញវត្ថុ, ការផ្សារភ្ជាប់ថវិកាទៅនឹង គោលនយោបាយ និង គណនេយ្យភាពសិទ្ធកម្ម សំដៅធានាប្រសិទ្ធភាពនៃការគ្រប់គ្រង និង ការប្រមូលចំណូល និង ចំណាយសាធារណៈនានា ។

**៨.** ការធ្វើវិមជ្ឈការហិរញ្ញវត្ថុ និង ប្រព័ន្ធផែនការ និង ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានថវិកាអាចព្យាករបាន និង មានទំហំសមស្របទៅនឹងមុខងារ និង អាទិភាពគោលនយោបាយជាតិ ហើយត្រូវបានវិភាជ សម្រាប់ការប្រើប្រាស់ប្រកបដោយភាពបត់បែនក្នុងការឆ្លើយតបទៅនឹងតម្រូវការនានា ដូចមានកំណត់នៅក្នុងផែនការអភិវឌ្ឍ, កម្មវិធីវិនិយោគ និង ផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

## ទី៣. ការលើកកម្ពស់ និង ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺការពង្រឹងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និង ការពង្រឹងជំនឿទុកចិត្តពីសាធារណជនមកលើរដ្ឋបាលសាធារណៈ ដើម្បីលើកកម្ពស់បរិយាកាសល្អប្រសើរ សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព និង បច្ចាប័ន្ន។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ÷

**១.** ការបន្តពង្រឹង និង ការពង្រីកការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ (Public Disclosure) ជាពិសេសតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន នូវព័ត៌មានបច្ចុប្បន្នភាពស្តីពីសេវាសាធារណៈ, បទដ្ឋានគតិយុត្ត និង ឯកសារគោលនយោបាយជាតិពាក់ព័ន្ធសេវាសាធារណៈ, ទន្ទឹមនឹងការពិនិត្យឡើងវិញលក្ខខណ្ឌ និង នីតិវិធី នៃការផ្តល់សេវាសាធារណៈរបស់ក្រសួង ស្ថាប័ន ដើម្បីកាត់បន្ថយរយៈពេលឱ្យកាន់តែខ្លី និង ងាយស្រួល ក្នុងការទទួលយកសេវាសាធារណៈរបស់ប្រជាពលរដ្ឋ ។

**២.** ការរៀបចំឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមាន យន្តការ, នីតិវិធី និង ស្តង់ដារ សម្រាប់ការផ្តល់សេវាសាធារណៈ, ការអភិវឌ្ឍមូលដ្ឋាន និង ការប្រាស្រ័យទាក់ទងសាធារណៈប្រកបដោយប្រសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, បរិយាប័ន្ន និង សមធម៌សង្គម តាមរយៈការអនុវត្តមុខងារជាអាណត្តិទូទៅ ឬ មុខងារជាជម្រើស និង មុខងារជាកាតព្វកិច្ច ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**៣.** ការជំរុញការរៀបចំ និង ការដាក់ឱ្យអនុវត្តក្រមសីលធម៌ការងារ ព្រមទាំងគោលការណ៍វិសមិតភាពមុខងារ និង ទំនាស់ផលប្រយោជន៍នៅក្នុងការបំពេញការងាររបស់មន្ត្រីសាធារណៈ ។

**៤.** ការពង្រឹងប្រសិទ្ធភាពនៃការធ្វើអធិការកិច្ច និង សវនកម្ម; ទន្ទឹមនឹងការរៀបចំក្របខ័ណ្ឌ និង វិធាន នៃប្រព័ន្ធសវនកម្ម និង អធិការកិច្ច ដើម្បីធានាសុខដុមនីយកម្មនៃមុខងារអធិការកិច្ច និង សវនកម្ម នៅក្នុងរដ្ឋបាលសាធារណៈ ។

**៥.** ការពង្រឹងភាពស្អាតស្អំ និង កាតព្វកិច្ចទទួលខុសត្រូវរបស់រដ្ឋបាលគ្រប់ថ្នាក់ តាមរយៈ ១). ការរៀបចំ

និង ពង្រឹងយន្តការគ្រប់គ្រង និង ផ្តល់សេវាសាធារណៈប្រកបដោយលក្ខណៈទំនើប និង តម្លាភាព, ២). ការលើកទឹកចិត្តនានាទាំងផ្នែកហិរញ្ញវត្ថុ និង មិនមែនហិរញ្ញវត្ថុដល់មន្ត្រីសាធារណៈដែលបំពេញការងារបានល្អ និង ៣). ការចាត់វិធានការយ៉ាងម៉ឺងម៉ាត់តាមច្បាប់ក្នុងការដាក់ទណ្ឌកម្មវិន័យ និង វិធានការច្បាប់ចំពោះមន្ត្រីសាធារណៈដែលប្រព្រឹត្តអំពើពុករលួយ, បំពានក្រមសីលធម៌វិជ្ជាជីវៈ ឬ រំលោភបំពានអំណាច ក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន ។

៦. ការបន្តពង្រឹង និង ការពង្រីកការងារអប់រំ, បង្ការទប់ស្កាត់ជាចម្បង និង បន្ថែម ដោយការពង្រឹងការអនុវត្តច្បាប់ ដើម្បីបង្ក្រាបបទល្មើសអំពើពុករលួយ ។ ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងអង្គភាពប្រឆាំងអំពើពុករលួយ និង ស្ថាប័នសាធារណៈ ជាពិសេសតាមរយៈ យន្តការជនបង្គោល, ទាំងលើការងារអប់រំ ទាំងលើការងារបង្ការទប់ស្កាត់ ដើម្បីរៀបចំ, ដាក់ឱ្យអនុវត្ត, តាមដានត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការការងារស្អាតស្អំតាមស្ថាប័នសាធារណៈ ។

## ទី៤. ការលើកកម្ពស់ និងការពង្រឹងប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺការពង្រឹងគោលការណ៍នីតិរដ្ឋ, ការពង្រឹងការប្រយុទ្ធប្រឆាំងនឹងអំពើរំលោភបំពានដោយអយុត្តិធម៌ក្នុងសង្គម និង ការពង្រឹងជំនឿទុកចិត្តពីសាធារណជនមកលើវិស័យយុត្តិធម៌ ដែលជាកត្តារួមចំណែកដ៏សំខាន់ ក្នុងការធានាថែរក្សាស្ថិរភាពសង្គម, សណ្តាប់ធ្នាប់សាធារណៈ និងភាពសុខដុមរមនាក្នុងសង្គមជាតិ ដើម្បីលើកកម្ពស់បរិយាកាសល្អប្រសើរ សម្រាប់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ÷

១. ការលើកកម្ពស់សមត្ថភាពធនធានមនុស្សក្នុងវិស័យយុត្តិធម៌, ទាំងលើបរិមាណ ទាំងលើគុណភាព ដើម្បីឆ្លើយតបបានប្រកបដោយប្រសិទ្ធភាពទៅនឹងតម្រូវការជាក់ស្តែងនៃការងារ សំដៅបង្កើនប្រសិទ្ធភាពការងារ នៅក្នុងវិស័យយុត្តិធម៌ ព្រមទាំងប្រសិទ្ធភាព និង ភាពឆាប់រហ័សនៃការដោះស្រាយវិវាទ, ទាំងក្នុងប្រព័ន្ធតុលាការ ទាំងក្រៅប្រព័ន្ធតុលាការ ។

២. ការលើកកម្ពស់ប្រសិទ្ធភាព, សង្គតិភាព និង អនុលោមភាពគតិយុត្តនៃការរៀបចំច្បាប់ និង លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ សំដៅធានាឆ្លើយតបបានទៅនឹងចក្ខុវិស័យ និង សេចក្តីត្រូវការចាំបាច់នានារបស់សង្គមជាតិ ។

៣. ការលើកកម្ពស់ការគោរពច្បាប់ និង ការផ្តល់សេវាជំនួយផ្នែកច្បាប់ តាមរយៈការបន្តជំរុញការអប់រំ និង ផ្សព្វផ្សាយច្បាប់, ការផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ និង ការផ្តល់ការការពារក្តីនៅចំពោះមុខតុលាការ សំដៅធានាសិទ្ធិទទួលបានយុត្តិធម៌ ជាពិសេស សម្រាប់ប្រជាពលរដ្ឋក្រីក្រ និង ជនងាយរងគ្រោះនៅក្នុងសង្គម ។

៤. ការលើកកម្ពស់ភាពត្រឹមត្រូវ និង ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ពីសំណាក់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីតុលាការ ជាពិសេស ការពង្រឹងប្រសិទ្ធភាពនៃចំណាត់ការលើសំណុំរឿង, ការពង្រឹងភាពស្អាតស្អំ និង ក្រម-

សីលធម៌វិជ្ជាជីវៈរបស់មន្ត្រីអនុវត្តច្បាប់ និង មន្ត្រីតុលាការ ព្រមទាំងការពង្រឹងយន្តការអធិការកិច្ច និង វិន័យការងារ សំដៅពង្រឹងជំនឿទុកចិត្តលើការអនុវត្តច្បាប់ ។

៥. ការលើកកម្ពស់គុណភាព និង ប្រសិទ្ធភាពនៃប្រព័ន្ធតុលាការ តាមរយៈការបន្តធ្វើទំនើបកម្មរដ្ឋបាលតុលាការ សំដៅលើកកម្ពស់គុណភាពនៃការផ្តល់សេវាយុត្តិធម៌ ឱ្យកាន់តែល្អប្រសើរ និង ការពង្រឹងគុណភាពនៃយុត្តិធម៌ សំដៅធានាបាននូវជំនឿទុកចិត្ត, ភាពត្រឹមត្រូវ និង យុត្តិធម៌ក្នុងការដោះស្រាយរឿងក្តីជូនប្រជាពលរដ្ឋ ដែលជាកត្តាដ៏សំខាន់ ក្នុងការរួមចំណែកថែរក្សាស្ថិរភាពសង្គម, សណ្តាប់ធ្នាប់សាធារណៈ និង ការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព ។

ទី៦-ការជំរុញរៀបចំក្របខណ្ឌច្បាប់ និង យន្តការសម្រុះសម្រួល និង ផ្សះផ្សាវិវាទ ទាំងក្នុងប្រព័ន្ធតុលាការ ទាំងក្រៅប្រព័ន្ធតុលាការ សំដៅលើកកម្ពស់ប្រសិទ្ធភាព និង ភាពឆាប់រហ័សនៃការដោះស្រាយវិវាទ, បង្ខិតសេវានៃការដោះស្រាយវិវាទដែលមានលក្ខណៈងាយស្រួល និង សម្បូរបែបឱ្យទៅជិតប្រជាពលរដ្ឋ និងធានាបាននូវបរិយាកាសសន្តិភាពនិយម និង ភាពសុខដុមរមនាក្នុងសង្គមជាតិ ។

### ទី៥. ការពង្រឹងអភិបាលកិច្ចវិស័យឯកជន និង ធុរកិច្ច

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺការពង្រឹងជំនឿទុកចិត្តរបស់តួអង្គពាក់ព័ន្ធមកលើវិស័យឯកជននិងធុរកិច្ច តាមរយៈការជំរុញឱ្យមានអភិបាលកិច្ចល្អ ក្នុងវិស័យឯកជន និង ធុរកិច្ច ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ÷

**១.** ការពង្រឹង និង ការលើកកម្ពស់អភិបាលកិច្ចល្អ នៅក្នុងវិស័យឯកជន និង ធុរកិច្ច តាមរយៈការរៀបចំ, ការអនុម័ត និង ការដាក់ឱ្យអនុវត្តនូវក្របខ័ណ្ឌគោលនយោបាយពាក់ព័ន្ធនឹងអភិបាលកិច្ចល្អសម្រាប់វិស័យឯកជន និង ធុរកិច្ច, ក្រមអភិបាលកិច្ចសាជីវកម្ម, ក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍វិស័យសហគ្រាសធុនតូច និង មធ្យម និង បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសហគ្រាសធុនតូច និង មធ្យម, ក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍វិស័យសំណង់, និង បទដ្ឋានគតិយុត្ត ក៏ដូចជាគោលការណ៍ណែនាំពាក់ព័ន្ធចាំបាច់នានា ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រង និង ការជំរុញការអនុវត្តល្អក្នុងវិស័យឯកជន និង ធុរកិច្ច ។

**២.** ការជំរុញការរៀបចំ, ការអនុម័ត និង ការដាក់ឱ្យអនុវត្តក្របខ័ណ្ឌគោលនយោបាយលើកកម្ពស់ការទទួលខុសត្រូវផ្នែកសង្គម និង បរិស្ថានរបស់វិស័យឯកជន និង ធុរកិច្ច (Corporate Social and Environmental Responsibility) ដើម្បីបង្កើនការចូលរួមដោះស្រាយបញ្ហាសង្គម និង លើកកម្ពស់តម្លៃសីលធម៌សង្គម និង វប្បធម៌ជាតិ និង ការថែរក្សាបរិស្ថាន ដោយផ្តល់នូវយន្តការគាំទ្រ និង លើកទឹកចិត្តសមស្របដល់វិស័យឯកជន និង ធុរកិច្ចទាំងឡាយ ដែលអនុវត្តបាននូវអភិបាលកិច្ចល្អ និង មានការទទួលខុសត្រូវខ្ពស់ផ្នែកសង្គម និង បរិស្ថាន ។

**៣.** ការពិនិត្យឡើងវិញ, ការធ្វើបច្ចុប្បន្នភាព, ការកែលម្អ និង ការធ្វើវិសោធនកម្មច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ព្រមទាំងការពិនិត្យ និង ដាក់ចេញនូវយន្តការពង្រឹងការអនុវត្តច្បាប់ ដើម្បីលើកកម្ពស់

អភិបាលកិច្ចល្អក្នុងវិស័យឯកជន និង ធុរកិច្ច ។

**៤.** ការជំរុញការរៀបចំ និង ការផ្តល់ការគាំទ្រដល់ក្រុមហ៊ុន, សមាគម និង សហគមវិជ្ជាជីវៈនានា ក្នុងការរៀបចំក្រមសីលធម៌ និង ក្រមវិជ្ជាជីវៈ ព្រមទាំងលើកទឹកចិត្តឱ្យមានការរៀបចំនូវស្តង់ដាគុណវុឌ្ឍិ សម្រាប់អភិបាល និង អ្នកគ្រប់គ្រងក្រុមហ៊ុន, សមាគម និង សហគមវិជ្ជាជីវៈ ដើម្បីបង្កើនការទទួលខុសត្រូវផ្ទាល់ខ្លួន នៅក្នុងថ្នាក់គ្រប់គ្រង និង កាត់បន្ថយទំនាស់ផលប្រយោជន៍ផ្ទាល់ខ្លួន និង ផលប្រយោជន៍សាធារណៈ ។

**៥.** ការពង្រឹងការអនុវត្តច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ក៏ដូចជា ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត តាមរយៈការផ្តល់ការគាំទ្រដល់សកម្មភាពសមាគមអ្នកប្រើប្រាស់ដែលមានស្រាប់ ឬ ការបង្កើតសមាគមអ្នកប្រើប្រាស់ថ្មី ដែលនឹងក្លាយជាយន្តការដ៏មានប្រសិទ្ធភាពមួយក្នុងការការពារផលប្រយោជន៍ និង សិទ្ធិអ្នកប្រើប្រាស់ ។ រៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មាន និង ទិន្នន័យ ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីសិទ្ធិអ្នកប្រើប្រាស់ និង ព័ត៌មានដែលមានប្រយោជន៍ដទៃទៀត ដើម្បីផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់អាចការពារសិទ្ធិរបស់ខ្លួន ។

**៦.** ការបង្កើនប្រសិទ្ធភាពនៃយន្តការសន្ទនា និង ភាពជាដៃគូរវាងរដ្ឋ និង វិស័យឯកជន ក្នុងកម្រិតគោលនយោបាយ និង បច្ចេកទេស, ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ដើម្បីជំរុញការពិភាក្សាផ្នែកគោលនយោបាយ និង ស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមនានា ដោយលើកកម្ពស់ការប្រើប្រាស់តួនាទីនៃសភាពាណិជ្ជកម្មទាំងក្នុង និង ក្រៅស្រុក និង តួអង្គដែលមានការពាក់ព័ន្ធផ្សេងទៀត ។

**៧.** ការបង្កើនប្រសិទ្ធភាព និង តម្លាភាពនៃអធិការកិច្ចវិស័យឯកជន និង ធុរកិច្ច តាមរយៈការជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្នុងការធ្វើអធិការកិច្ច, ការពង្រឹងសមត្ថភាព និង សុចរិតភាពរបស់អ្នកធ្វើអធិការកិច្ច, និង ការជំរុញការអនុវត្តវិធានការអធិការកិច្ច សំដៅចូលរួមបង្កើនប្រសិទ្ធភាពនៃអភិបាលកិច្ច និង ការអនុវត្តច្បាប់ ។

### ២.៣. បរិស្ថានគ្របដណ្តប់នៃយុទ្ធសាស្ត្រ

### ទី១. សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

ការបន្តការពារសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈ គឺជាកិច្ចការដ៏មានសារៈសំខាន់ ។ កិច្ចការពារ និង ថែរក្សាសន្តិភាព ទាមទារនូវការផ្តោតការយកចិត្តទុកដាក់លើការចាត់វិធានការម៉ឺងម៉ាត់ សំដៅទប់ស្កាត់ការបង្កើតកងកម្លាំងប្រដាប់អាវុធខុសច្បាប់ ការបង្កើតតំបន់អប្បគមន៍ និង សកម្មភាពប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់នៅក្នុងគ្រប់រូបភាព ។ ការពង្រឹងស្ថិរភាពនយោបាយ តម្រូវឱ្យផ្តោតការយកចិត្តទុកដាក់លើការបន្តធានាប្រក្រតីភាពនៃស្ថាប័នសាធារណៈ, ការពង្រឹងការបំពេញមុខងារនៃស្ថាប័ននយោបាយ, ពង្រឹងប្រសិទ្ធភាពនៃស្ថាប័នសាធារណៈទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ និង ការបន្តអនុវត្តយន្តការប្រជាធិបតេយ្យ នៅក្នុងការជ្រើសរើសអ្នកនយោបាយ សម្រាប់ដឹកនាំប្រទេស តាមរយៈ ការបោះឆ្នោតជាទៀងទាត់តាមការកំណត់ក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់ជាធរមាន ។ ការលើកកម្ពស់សន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈ ទាមទារនូវការយកចិត្តទុកដាក់លើការអនុវត្តច្បាប់យ៉ាងម៉ឺងម៉ាត់ និង ហ្មត់ចត់ ដោយលើកកម្ពស់ប្រសិទ្ធភាព ក្នុងការទប់ស្កាត់សកម្មភាពភេរវកម្មឆ្លងដែនគ្រប់ប្រភេទ ពិសេសបទល្មើសសម្អាតប្រាក់ហិរញ្ញប្បទានភេរវកម្ម, ហិរញ្ញប្បទាន

ដល់ការសាយភាយអាវុធមហាប្រល័យ, អំពើជួញដូរមនុស្សគ្រប់ទម្រង់ និង ប្រយុទ្ធប្រឆាំងការជួញដូរ, ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ព្រមទាំងបទល្មើសនានាក្នុងសង្គម ដើម្បីធានាសុវត្ថិភាពជូនប្រជាជនគ្រប់ៗរូប ។

ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា, រាជរដ្ឋាភិបាលបានសម្រេចជោគជ័យក្នុងការការពារឯករាជ្យ, អធិបតេយ្យជាតិ និង បូរណភាពទឹកដី; ការទប់ស្កាត់ដោយជោគជ័យនូវសកម្មភាពប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ និងបង្កចលាចលវឹកវរក្នុងសង្គម; ការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងផលប៉ះពាល់បណ្តាលមកពីវិបត្តិនានាជាសកល; ការរៀបចំដោយជោគជ័យនូវកិច្ចប្រជុំកំពូលអាស៊ានលើកទី ៤០ និង ទី ៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ; ការពង្រឹងស្ថិរភាពនយោបាយ, នីតិរដ្ឋ និង លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស; ការលើកកម្ពស់ការគោរពសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស; ការសម្រេចបាននូវការបោះឆ្នោតដោយជោគជ័យ, ទាំងសកល និង អសកល, និង ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិយ៉ាងទៀតទាត់ជាបន្តបន្ទាប់ ប្រកបដោយភាពសេរី, ត្រឹមត្រូវ និង យុត្តិធម៌; និង ការពង្រឹងការអនុវត្តច្បាប់ ក៏ដូចជាសន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈ តាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយ **«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»** ព្រមទាំងការទប់ស្កាត់ និងបង្ក្រាប ដោយជោគជ័យនូវបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ រួមបញ្ចូលទាំងការបង្ក្រាបល្បែងស៊ីសងខុសច្បាប់ និង ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស, បទល្មើសសម្អាតប្រាក់, អំពើភេរវកម្ម, សកម្មភាពគ្រឿងញៀនខុសច្បាប់ និង ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ។

ទន្ទឹមនឹងសមិទ្ធផល និង ជោគជ័យខាងលើ, កម្ពុជានៅបន្តជួបប្រទះនូវ បញ្ហាប្រឈមមួយចំនួន ដូចជាការបន្តប៉ុនប៉ងរបស់បរទេសក្នុងការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងកម្ពុជា និង ការចិញ្ចឹមចិត្តរបស់មជ្ឈដ្ឋានអគតិមួយចំនួនប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់; ការបន្តពង្រឹងបរិយាកាសនីតិរដ្ឋ និង ប្រក្រតីភាពក្នុងការបំពេញមុខងារនៃស្ថាប័នសាធារណៈ; ការបន្តកសាងព្រំដែនសន្តិភាព, មិត្តភាព, សហប្រតិបត្តិការ និង ការអភិវឌ្ឍ; ការបន្តទប់ស្កាត់ និង បង្ក្រាបអំពើភេរវកម្ម, ឧក្រិដ្ឋកម្មឆ្លងដែន និង បទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ ជាពិសេសសកម្មភាពជួញដូរ និង ប្រើប្រាស់គ្រឿងញៀនខុសច្បាប់, ការជួញដូរមនុស្ស, ជួញដូរពលកម្ម និង អាជីវកម្មផ្លូវភេទ, បទល្មើសលាងសម្អាតប្រាក់, អន្តោប្រវេសន៍ខុសច្បាប់ និង បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា និង ការទប់ស្កាត់ និង កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ។

រាជរដ្ឋាភិបាលនៃនីតិកាលទី ៧ នៃរដ្ឋសភា នឹងផ្តោតអាទិភាពលើ៖

**១.** ការការពារឯករាជ្យ, អធិបតេយ្យជាតិ និង បូរណភាពទឹកដី មិនឱ្យបរទេសណាលូកដៃជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងកម្ពុជាជាដាច់ខាត, ព្រមទាំងការទប់ស្កាត់ និង ប្រឆាំងដាច់ខាតរាល់សកម្មភាពប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ឬ ការញុះញង់ណាមួយ ដើម្បីធ្វើសកម្មភាពខុសច្បាប់បង្កអស្ថិរភាពនយោបាយ ឬ ចលាចលក្នុងសង្គម ។

**២.** ការបន្តពង្រឹងនីតិរដ្ឋ, លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស, វប្បធម៌សន្តិភាព, សីលធម៌សង្គម, ការគោរពសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស, និង ការបន្តពង្រឹងបរិយាកាស និង ប្រក្រតីភាពក្នុងការបំពេញមុខងារនៃស្ថាប័ន

សាធារណៈ។

៣. ការបន្តដោះស្រាយបញ្ហាព្រំដែនគោក និងទឹកជាមួយប្រទេសជិតខាង ដោយផ្អែកលើមូលដ្ឋានច្បាប់អន្តរជាតិ រួមជាមួយនឹងការបន្តរៀបចំ និង ជំរុញអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍតំបន់ព្រំដែន ជាព្រំដែនសន្តិភាព, មិត្តភាព សហប្រតិបត្តិការ និង ការអភិវឌ្ឍ, ទន្ទឹមនឹងការបន្តប្រកាន់ខ្ជាប់នូវគោលការណ៍មិនអនុញ្ញាតឱ្យប្រើប្រាស់ទឹកដីកម្ពុជា ដើម្បីប្រឆាំងនឹងប្រទេសជិតខាង ។

៤. ការទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ រួមទាំងការប្រយុទ្ធប្រឆាំងភេរវកម្ម, ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ,អំពើជួញដូរមនុស្សគ្រប់ទម្រង់, ការជួញដូរពលកម្ម, អាជីវកម្មផ្លូវភេទ, បទល្មើសលាងសម្អាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម, ហិរញ្ញប្បទានដល់ការសាយភាយអាវុធមហាប្រល័យ,ការប្រយុទ្ធប្រឆាំងសកម្មភាពពាក់ព័ន្ធនឹងការជួញដូរ និង ប្រើប្រាស់គ្រឿងញៀនខុសច្បាប់, ល្បែងស៊ីសងខុសច្បាប់ ព្រមជាមួយនឹងការបន្តជំរុញអនុវត្ត **«គោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព»** ។

៥. ការបន្តពង្រឹងសុវត្ថិភាពចរាចរណ៍ និង សណ្តាប់ធ្នាប់តាមដងផ្លូវ, តាមទីក្រុង, ទីប្រជុំជន ដើម្បីដោះស្រាយការកកស្ទះចរាចរណ៍ និង កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ស្របពេលដែលកម្ពុជាមានផ្លូវល្បឿនលឿន ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និង ការដឹកជញ្ជូនកាន់តែទំនើប ។

៦. ការបង្ការ និងដោះស្រាយបញ្ហាអគ្គិភ័យ និងគ្រោះថ្នាក់នានាក្នុងសង្គម ដើម្បីរក្សាសុវត្ថិភាពជូនប្រជាពលរដ្ឋ ខណៈមានការកើនឡើងនៃទីក្រុង ទីប្រជុំជន និងការអភិវឌ្ឍសំណង់អគារខ្ពស់ៗ។

៧. ការបន្តពង្រឹងការអនុវត្តច្បាប់ស្តីពីសញ្ជាតិ និង ច្បាប់ស្តីពីអន្តោប្រវេសន៍, ការបន្តជំរុញរៀបចំក្របខ័ណ្ឌច្បាប់ និង យន្តការនានា ដើម្បីធានាថា “**មនុស្សម្នាក់មានអត្តសញ្ញាណតែមួយ** ” និង “**មនុស្សទាំងអស់ត្រូវបានកំណត់អត្តសញ្ញាណ**”, ការគ្រប់គ្រងការចេញ-ចូល ព្រះរាជាណាចក្រកម្ពុជា, ការគ្រប់គ្រងការស្នាក់នៅ និង ប្រកបមុខរបររបស់ជនបរទេស, ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យអន្តោប្រវេសន៍ សំដៅបង្ការទប់ស្កាត់ការលបលួចជ្រៀតចូល, ការស្នាក់នៅ និង ការប្រកបមុខរបរដោយខុសច្បាប់ ។

៨. ការពង្រឹងការអនុវត្តច្បាប់ និង កសាងសមត្ថភាព ដើម្បីទប់ស្កាត់បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា ។

៩. ការជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ២០១៧-២០២៦ ដោយបង្កើតឱ្យមានមជ្ឈមណ្ឌលជាតិគ្រប់គ្រងទិន្នន័យប្រជាជន និង រៀបចំឱ្យប្រើប្រាស់លេខសម្គាល់អត្តសញ្ញាណបុគ្គល, ជំរុញការកសាងច្បាប់ស្តីពីអត្រានុកូលដ្ឋាន, ស្ថិតិអត្រានុកូលដ្ឋាន និង អត្តសញ្ញាណកម្ម, និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

### ទី២. គោលនយោបាយការបរទេស ដោយឯករាជ្យ ផ្អែកលើច្បាប់ និង ឈ្លាសវៃ

កិច្ចទំនាក់ទំនងក្នុងតំបន់ និង សកលនាពេលបច្ចុប្បន្នឈានទៅដល់ស្ថានភាពស្មុគស្មាញ និង ប្រែប្រួលលឿន ហើយស្ថានភាពនេះ នឹងបន្តវិវត្តកាន់តែមានភាពផុយស្រួយ, មិនប្រាកដប្រជា និង ពិបាកក្នុងការប៉ាន់ស្មានដែលនេះ តម្រូវឱ្យកម្ពុជាចាំបាច់ប្រកាន់យកគោលនយោបាយបរទេសមួយដែលមានភាពបត់បែន, ម៉ឺងមាត់ និង

ឈ្លាសវៃ ។ គោលនយោបាយការបរទេសរបស់កម្ពុជាត្រូវបន្តផ្តោតលើការពារអធិបតេយ្យភាពជាតិ, ឯករាជ្យជាតិ និង គោរពចំពោះអធិបតេយ្យភាព និង បូរណភាពទឹកដីរបស់ប្រទេសដទៃ ដោយមិនគាំទ្រការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង និង ការប្រើប្រាស់កម្លាំងយោធា ។ ការអនុវត្តកិច្ចការទូតត្រូវបន្តតម្កល់យកផលប្រយោជន៍ជាតិជាស្នូល ដោយប្រកាន់ខ្ជាប់នូវគោលការណ៍អព្យាក្រឹត្យអចិន្ត្រៃយ៍, ផ្អែកលើច្បាប់, ក៏ប៉ុន្តែ អាចសម្របខ្លួនទៅតាមនិន្នាការជាក់ស្តែង ដែលមិនធ្វើឱ្យមានការប្រឈមមុខដាក់គ្នាជាមួយប្រទេសជាមិត្តណាមួយ ដែលអាចបង្កឱ្យបាត់បង់ប្រយោជន៍ស្នូលរបស់ជាតិ ។ ការពង្រឹងទំនាក់ទំនងជាមួយដៃគូយុទ្ធសាស្ត្រ ត្រូវផ្តោតទៅលើពាណិជ្ជកម្ម វិនិយោគ និង ការអភិវឌ្ឍសេដ្ឋកិច្ច ដោយមិនបង្រួមកិច្ចទំនាក់ទំនងល្អជាមួយប្រទេសណាមួយ ។ ការបន្តពង្រីកកិច្ចសហប្រតិបត្តិការថ្មីៗ ជាមួយដៃគូយុទ្ធសាស្ត្រ ក្នុងភូមិសាស្ត្រនយោបាយតំបន់ និង សកលដែលរឹងមាំ, ទាំងក្នុងកម្រិតទ្វេភាគីផង និង ពហុភាគីផង ។

ក្នុងពេលសណ្តាប់ធ្នាប់អន្តរជាតិមានភាពរង្គោះរង្គើរ និង គ្រោះថ្នាក់, រាជរដ្ឋាភិបាលក្នុងនីតិកាលទី ៦ នៃរដ្ឋសភាបានសម្រេចលទ្ធផលចម្បងៗជាច្រើន ក្នុងក្របខ័ណ្ឌតំបន់ និង សកល តួយ៉ាងជោគជ័យក្នុងការសម្របសម្រួលកិច្ចប្រជុំកំពូលអាស៊ានលើកទី ៤០, ៤១ និង កិច្ចប្រជុំពាក់ព័ន្ធក្នុងឋានៈជាប្រធានអាស៊ានលើកទី ៣ ដោយប្រើប្រាស់ភាពឈ្លាសវៃក្នុងការដឹកនាំដែលធ្វើឱ្យបណ្តាភាគី ដែលកំពុងប្រឈមមុខដាក់គ្នា មករួមកិច្ចប្រជុំជាមួយគ្នា; គ្រប់គ្រងស្ថានភាពនៃជំងឺកូវីដ-១៩ បានល្អ ក្នុងការប្រើប្រាស់ការទូតវ៉ាក់សាំង; បន្តពង្រឹង និង ពង្រីកការអនុវត្តការទូតសេដ្ឋកិច្ច និង វប្បធម៌; បន្តរក្សាសន្តិភាព មិត្តភាព និង កិច្ចសហប្រតិបត្តិការដោយបង្រួមអរិភាព និង លុបបំបាត់បាតុភាព ដែលឈានទៅរកភាពតានតឹងជាមួយប្រទេសជិតខាង; ប្រើប្រាស់តួនាទីជាប្រទេសឯករាជ្យ ធ្វើការសម្រេចចិត្តផ្អែកតាមច្បាប់ដោយមិនគាំទ្រការប្រើប្រាស់កម្លាំងយោធារវាងប្រទេសកំពុងមានជម្លោះ, តែមិនបណ្តាលឱ្យបាត់បង់ប្រទេសជាមិត្តណាមួយ និង បន្តការដ្ឋានកែទម្រង់ស្ថាប័នការទូត។

ទន្ទឹមនឹងលទ្ធផល និង ជោគជ័យខាងលើ, កម្ពុជានៅប្រឈមកត្តាមួយចំនួន ដូចជាការប្រើប្រាស់ទណ្ឌកម្មសេដ្ឋកិច្ច និង បច្ចេកវិទ្យាជាឧបករណ៍ ក្នុងការដាក់សម្ពាធពីប្រទេសមហាអំណាច ដែលបង្កឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជា និង ការអភិវឌ្ឍជាសកល; ការទោរបង្អើតសម្ព័ន្ធភាពខ្នាតតូចៗច្រើន ដែលអាចនាំឱ្យប៉ះពាល់ដល់សម្ព័ន្ធភាពខ្នាតធំនិងបែកបាក់ផ្ទៃក្នុង; ការធ្លាក់ចុះនៃសណ្តាប់ធ្នាប់សកលដែលបង្កឱ្យមានការសាមគ្គីជាក្រុមដាក់ទណ្ឌកម្មដោយមិនផ្អែកលើគោលការណ៍ច្បាប់ ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ÷

**១.** បន្តអនុវត្តគោលនយោបាយឯករាជ្យ ដោយផ្អែកលើច្បាប់ដោយលើកតម្កើនការគោរពអធិបតេយ្យ, គោរពនិយាមអន្តរជាតិ, គោរពគោលការណ៍នៃធម្មនុញ្ញរបស់អាស៊ាន និង អង្គការអន្តរជាតិ, គោរពគោលការណ៍មតិភាពច្រើនពិសេសយន្តការកុងសង់ស៊ីស ។

**២.** ការបន្តប្រកាន់គោលការណ៍អព្យាក្រឹត្យអចិន្ត្រៃយ៍ តែបត់បែនដោយមិនធ្វើឱ្យខូចខាតទំនាក់ទំនងជាមួយប្រទេសដៃគូយុទ្ធសាស្ត្រ និង ប្រើប្រាស់គោលការណ៍អព្យាក្រឹត្យ ពង្រីកកិច្ចសហប្រតិបត្តិការជាមួយប្រទេសនិយម

កណ្ដាល ដោយបន្តរក្សាជំហរជាប្រទេសឯករាជ្យតែមិនឯកា ។

៣. ការចូលរួមក្នុងកិច្ចការសម្របសម្រួល, រក្សាសន្តិភាព, ស្ថិរភាពក្នុងតំបន់ និង សកលឱ្យមានកិច្ចសន្ទនាផ្សះផ្សា, ពិគ្រោះយោបល់, សាមគ្គីដោះស្រាយបញ្ហារួម ដើម្បីជៀសវាងការដាក់សម្ពាធ និង មានជម្លោះ ។

៤. ការអនុវត្តការបរទេសដែលតម្កល់ប្រយោជន៍ស្នូលរបស់ជាតិជាចម្បង ដោយមិនធ្វើការចរចាលើការដោះដូរឱ្យខាតប្រយោជន៍ជាតិ, ប៉ះពាល់ឧត្តមភាពជាតិ, កិត្យានុភាពជាតិ និង អធិបតេយ្យជាតិ ។

៥. ការបន្តពង្រឹងទំនាក់ទំនងល្អលើគ្រប់វិស័យជាមួយដៃគូយុទ្ធសាស្ត្រក្នុងតំបន់ និង សកល, ទាំងទម្រង់ទ្វេភាគី និង ពហុភាគី សំដៅលើកកម្ពស់ផលប្រយោជន៍ស្នូលរបស់ជាតិ និង ការពារអធិបតេយ្យភាពជាតិ ។ ពង្រីកទំនាក់ទំនងដោយកំណត់យកទំនាក់ទំនងអាទិភាពលើផ្នែកសេដ្ឋកិច្ច, ពាណិជ្ជកម្ម, ការវិនិយោគ ទេសចរណ៍, វប្បធម៌, បច្ចេកវិទ្យានិងថាមពល ដើម្បីពង្រីកទំនាក់ទំនងផ្សេងទៀត ។

៦. បន្តចូលរួមរក្សាកិច្ចសហប្រតិបត្តិការរក្សាសណ្ដាប់ធ្នាប់សកល, ទំនាក់ទំនងដែលគោរពអធិបតេយ្យគ្នា, បង្កើតប្រយោជន៍ជូនគ្នាទៅវិញទៅមក ដោយផ្ដោតលើការពារយុត្តិធម៌អន្តរជាតិ, រក្សាសន្តិភាពសាសនា, កាត់បន្ថយការប្រែប្រួលអាកាសធាតុ, ការធានាសន្តិសុខស្បៀងពិភពលោក និង ការរក្សាសន្តិភាពពិភពលោកក្រោមការផ្ដួចផ្ដើមរបស់អង្គការអន្តរជាតិ និង អាស៊ាន ។

៧. ការអនុវត្តគោលនយោបាយការបរទេសពហុវិមាត្រ និង ពហុសណ្ឋាន ដែលជាគន្លឹះបង្កើនប្រសិទ្ធភាពក្នុងកិច្ចការពារនិងស្វែងរកផលប្រយោជន៍ជាតិ និង បន្តរក្សាជំហររឹងមាំក្នុងការទប់ទល់ទៅនឹងការដាក់សម្ពាធនានា ។ ភាពប្រទាក់ក្រឡានៃវិស័យពាក់ព័ន្ធ នឹងបង្កើតជាសហថាមពលដល់កម្ពុជាលើការអនុវត្តកិច្ចការបរទេសឈ្លាសវៃ ដោយបង្កើនអំណាចចរចាការពារ និង រើបម្រាស់តាមរយៈការធ្វើសម្បទាន និង ទទួលយក ។

៨. បង្កើតយន្តការថ្នាក់ជាតិ ដើម្បីសម្របសម្រួលក្នុងការដាក់ចេញ និង អនុវត្តគោលនយោបាយការបរទេសដោយផ្អែកតាមការវិភាគ និង ការវិវត្តភូមិសាស្ត្រសេដ្ឋកិច្ច, នយោបាយក្នុងតំបន់ និង សកល ។

៩. បន្តធ្វើការកែទម្រង់ស្ថាប័ន និង បណ្ដុះបណ្ដាលធនធានមនុស្ស ក្នុងកិច្ចការបរទេសឱ្យមានភាពប្រសប់ក្នុងការចរចាស្វែងរក និង ការពារប្រយោជន៍ស្នូលរបស់ជាតិ ។

### ទី៣. ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្នុងកំឡុងពេលជាង ២ ទសវត្សរ៍ចុងក្រោយនេះ, កម្ពុជាមានការវិវឌ្ឍខ្លួនយ៉ាងឆាប់រហ័ស ពីសេដ្ឋកិច្ចផែនការទៅជាសេដ្ឋកិច្ចទីផ្សារ, ពីសេដ្ឋកិច្ចពឹងផ្អែកស្ទើរទាំងស្រុងលើវិស័យកសិកម្ម ទៅជាសេដ្ឋកិច្ចមានពិពិធកម្មទូលាយ និង ពីប្រទេស ដែលមានទំនាក់ទំនងតិចតួចជាមួយបរទេស និង មានការហ៊ុមព័ទ្ធសេដ្ឋកិច្ច ទៅជាប្រទេសដែលមានសមាហរណកម្មពេញលេញក្នុងកិច្ចការតំបន់ និង ពិភពលោក ។ កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់ប្រមាណ ៧% ជាមធ្យមក្នុងមួយឆ្នាំ ព្រមទាំងបានឆ្លងផុតពីឋានៈជាប្រទេសចំណូលទាប ទៅជាប្រទេសចំណូលមធ្យមកម្រិតទាប។ ទន្ទឹមនេះ, ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់បានកើនឡើង ៦ ដង រហូតដល់ប្រមាណជា ១ ៧០០ ដុល្លារអាម៉េរិក ។ អត្រាអតិផរណាស្ថិតក្នុងកម្រិតទាបក្រោម ៣% លើកលែងតែឆ្នាំមានវិបត្តិ

ស្របពេលដែលអត្រាប្តូរប្រាក់រក្សាបាននូវស្ថិរភាពក្នុងរង្វង់ ៤ ០០០ រៀល ក្នុងមួយដុល្លារអាមេរិក ។ ជាមួយនេះ, វិសមភាពសង្គម ក៏ត្រូវបានបង្រួមតូចជាបន្តបន្ទាប់ ស្របនឹងការបែងចែកផ្លែផ្កាពីកំណើនកាន់តែមានសមភាព និង បរិយាប័ន្ន ។ ភាពអំណោយផលនៃស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ធ្វើឱ្យប្រាក់ចំណូលរបស់ប្រជាជនកើន ឡើងជាលំដាប់ ដោយអត្រាភាពក្រីក្រត្រូវបានកាត់បន្ថយជាបន្តបន្ទាប់មកស្ថិតក្នុងរង្វង់ជាង ១០% ។ ទោះបីកម្ពុជា ត្រូវឆ្លងកាត់ព្យុះភ្លៀងនៃវិបត្តិជំងឺកូវីដ-១៩ និង វិបត្តិសង្គ្រាមរុស្ស៊ី-អ៊ុយក្រែនជាបន្តបន្ទាប់យ៉ាងណាក្តី,រាជរដ្ឋាភិបាល បានប្រឹងជំនះរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ស្តារសេដ្ឋកិច្ចឡើងវិញតាមរយៈការដាក់ចេញ វិធានការអន្តរាគមន៍ផ្នែកសង្គម និង សេដ្ឋកិច្ច ដោយប្រើប្រាស់ឧបករណ៍គោលនយោបាយទាំងសារពើពន្ធ និង រូបិយវត្ថុទាន់ពេលវេលា ក្រោមស្មារតីបុរេសកម្មខ្ពស់របស់រដ្ឋាភិបាល និង ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និង ភាពឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។

ជារួម, រាជរដ្ឋាភិបាលបានបង្កើនកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈរលើកិច្ចការអាទិភាព មានជាអាទិ៍: ១). ការបន្តរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង កំណើនរឹងមាំ ប្រកបដោយចីរភាព និង បរិយាបន្ន, ២). ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធភាព និង ឆ្លើយតបបានទៅនឹងតម្រូវការអភិវឌ្ឍ, ៣). ការបន្តរក្សាបាន ស្ថិរភាព និង ភាពធន់នៃវិស័យហិរញ្ញវត្ថុ តាមរយៈការដាក់ចេញនូវវិធានការមីក្រូ និង ម៉ាក្រូប្រុងប្រយ័ត្ន ប្រកប ដោយស្មារតីបុរេសកម្ម, ៤).ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុឱ្យកាន់តែមានពិពិធភាព និង ប្រកបដោយបរិយាប័ន្នតាមរយៈ ការបន្តជំរុញការអនុវត្ត "គោលនយោបាយអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១៦-២០២៥" និង "យុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុ ២០១៩-២០២៥", និង ៥). ការបន្តពង្រឹង និង ពន្លឿនការដ្ឋានកែទម្រង់លើគ្រប់វិស័យ ដើម្បី ជំរុញល្បឿនពិពិធកម្មសេដ្ឋកិច្ច និង ពង្រឹងភាពប្រកួតប្រជែង តាមរយៈការដាក់ចេញនូវវិធានការគាំទ្រ និង ការ បង្កបរិយាកាសកាន់តែអំណោយផលដល់សកម្មភាពសេដ្ឋកិច្ច, ពាណិជ្ជកម្ម និង ការវិនិយោគ ។

ហានិភ័យសំខាន់ៗ ដែលអាចជះឥទ្ធិពលមកលើសេដ្ឋកិច្ចកម្ពុជា រួមមាន: ការថមថយសេដ្ឋកិច្ចសកល, ការកើនឡើងនៃភាពតានតឹងនៃភូមិសាស្ត្រនយោបាយ, ការកើនឡើងសម្ពាធអតិផរណា និង អត្រាការប្រាក់សកល, សង្គ្រាមពាណិជ្ជកម្ម និង បច្ចេកវិទ្យា, ការផ្លាស់ប្តូរច្រវាក់ផ្គត់ផ្គង់ និង ការបែកខ្ញែកប៉ូលសេដ្ឋកិច្ច ។ ជាមួយនេះ, បញ្ហាប្រឈមចម្បងៗ ដែលត្រូវបន្តដោះស្រាយ មានដូចជា មូលដ្ឋានសេដ្ឋកិច្ចនៅតូចចង្អៀត ទោះបីមានការរីកធំ នូវទំហំសេដ្ឋកិច្ចប្រមាណ ៣០% ក្រោយការផ្លាស់ប្តូរឆ្នាំគោលក្នុងការគណនា ផ.ស.ស, ភាពមានកម្រិតនៃសមត្ថ ភាពប្រកួតប្រជែងរបស់កម្ពុជា និង កម្រិតខ្ពស់នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។ ទន្ទឹមនេះ បញ្ហាប្រឈមក្នុងវិស័យហិរញ្ញវត្ថុ រួមមាន កម្រិតដុល្លារូបនីយកម្មខ្ពស់ ដែលប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុ, ភាព មានកម្រិតនៃការតាមដាន, វិភាគ និង យន្តការនៃការគ្រប់គ្រងហានិភ័យវិស័យហិរញ្ញវត្ថុ ជាពិសេសវិស័យហិរញ្ញវត្ថុ មិនមែនធនាគារ និង ទំហំធំនិងការបន្តកើនឡើងនៃបំណុលឯកជន (ទាំងក្នុង និង ក្រៅប្រព័ន្ធធនាគារ) ។

ការរក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺជាបុរេលក្ខខណ្ឌមិនអាចខ្វះបានក្នុងការស្តារ សេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិកូវីដ-១៩ និង រុញច្រានសេដ្ឋកិច្ចឱ្យត្រឡប់ទៅរកវិថីនៃកំណើនប្រកបដោយចីរភាព

និង បរិយាប័ន្ន ដើម្បីឈានទៅបន្តសម្រេចបាននូវចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា ក្នុងការក្លាយជាប្រទេសដែលមានចំណូលខ្ពស់នាឆ្នាំ ២០៥០ ខាងមុខ ។ ដោយឡែក, ការរក្សាឱ្យបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺកាន់តែមានភាពស្មុគស្មាញ ក្នុងបរិការណ៍នៃភាពមិនច្បាស់លាស់នៃទស្សនវិស័យសេដ្ឋកិច្ចសកល និង តំបន់ និង ការកើនឡើងនៃភាពប្រទាក់ក្រឡាគ្នានៅក្នុងវិស័យហិរញ្ញវត្ថុ ។

សម្រាប់នីតិកាលទី ៧ នេះ, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ÷

**១.** បន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចប្រុងប្រយ័ត្ន ដោយការប្រកាន់យកគោលនយោបាយចម្រុះ និង មានលក្ខណៈប្រទាក់ក្រឡា, ពោល គឺគោលនយោបាយហិរញ្ញវត្ថុសាធារណៈ, គោលនយោបាយរូបិយវត្ថុ និង គោលនយោបាយរចនាសម្ព័ន្ធ ដើម្បីធានាឱ្យបាននូវស្ថិរភាពកំណើន, អតិផរណាទាប, ស្ថិរភាពអត្រាប្តូរប្រាក់, កាបង្កើតការងារជូនប្រជាពលរដ្ឋ និង ការបង្កើនសមធិមសង្គម ។

**២.** បន្តធ្វើការកែទម្រង់ឱ្យកាន់តែស៊ីជម្រៅ និង មុតស្រួច ជាពិសេស ចំពោះបញ្ហាប្រឈម ដែលមានចរិតជារចនាសម្ព័ន្ធ និង អន្តរស្ថាប័ន (cross cutting) សំដៅលើកកម្ពស់ពិពិធកម្មសេដ្ឋកិច្ច និង បង្កើនភាពប្រកួតប្រជែង ។

**៣.** រៀបចំ និង ជំរុញអនុវត្តនូវយន្តការសម្រួលដល់ការបង្កើតធុរកិច្ចថ្មី ដោយកាត់បន្ថយពេលវេលា និង ចំណាយនៃការចុះបញ្ជី, ការស្នើសុំអាជ្ញាប័ណ្ណ និង នីតិវិធីពាក់ព័ន្ធផ្សេងៗទៀត ព្រមទាំងរៀបចំកែលម្អនូវសេវាសាធារណៈ ដែលបម្រើធុរជន ឬ ដំណើរការធុរកិច្ច ។

**៤.** រៀបចំ និង ដាក់ចេញនូវវិធានការ និង យន្តការលើកទឹកចិត្តដល់សហគ្រាស និង អាជីវកម្មក្រៅប្រព័ន្ធ ឱ្យចុះបញ្ជីអាជីវកម្មឱ្យបានត្រឹមត្រូវ ។

**៥.** បន្តធ្វើឱ្យប្រសើរឡើងនូវកម្មវិធីជំនួយសង្គម និង របបសន្តិសុខសង្គម តាមរយៈការបន្តអនុវត្តកម្មវិធីជាតិជំនួយសង្គម ដែលមានស្រាប់ ដោយធ្វើការកែលម្អ, ពង្រឹង និង សិក្សាសមិទ្ធិលទ្ធភាពពង្រីកវិសាលភាពកម្មវិធី ។

**៦.** បន្តអភិវឌ្ឍទីផ្សារមូលបត្រ ដោយជំរុញ និង លើកទឹកចិត្តសហគ្រាស និង ក្រុមហ៊ុន ឱ្យបោះផ្សាយមូលបត្រជាសាធារណៈ, ការលើកកម្ពស់យន្តការជួញដូរ និង បន្តពង្រឹងទំនុកចិត្តទីផ្សារ ។

**៧.** បន្តដាក់ចេញ និង អនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០២៤-២០២៨, សំដៅបន្តពង្រីក និង ពង្រឹងមូលដ្ឋាន និង ប្រសិទ្ធភាពនៃការប្រមូលចំណូលទាំងផ្នែកសារពើពន្ធ និង មិនមែនសារពើពន្ធ ។

**៨.** បន្តជំរុញ និង ពង្រឹងប្រសិទ្ធភាពនៃការបោះផ្សាយសញ្ញាបណ្ណរដ្ឋ សំដៅលើកកម្ពស់ពិពិធកម្មប្រភពហិរញ្ញប្បទាន ជាពិសេសប្រភពហិរញ្ញប្បទានក្នុងស្រុក ។

**៩.** បន្តពង្រឹងប្រសិទ្ធភាពចំណាយសាធារណៈ តាមរយៈការធ្វើអាទិភាវូបនីយកម្មចំណាយ ជាពិសេសសម្រាប់វិស័យអាទិភាព និង ផ្តល់តម្លៃបន្ថែមខ្ពស់, និង ការបង្កើនប្រាក់សន្សំរបស់រាជរដ្ឋាភិបាល សំដៅពង្រឹងលំហថវិកាជាតិ (fiscal space) ។

**ទី១០-** ពង្រឹងស្ថិរភាពហិរញ្ញវត្ថុសាធាណៈ (fiscal sustainability) តាមរយៈការរៀបចំយន្តការគ្រប់គ្រងហានិភ័យ និង ដាក់ចេញវិធានការជាក់លាក់ឱ្យទាន់ពេលវេលា ដើម្បីបញ្ចៀសហានិភ័យនានា ជាយថាហេតុ ។

១១. បន្តធានាស្ថិរភាពហិរញ្ញវត្ថុ តាមរយៈការដាក់ឱ្យដំណើរការ និង ពង្រឹងយន្តការ ដែលមានស្រាប់ សម្រាប់ការគ្រប់គ្រងហានិភ័យនៃវិស័យហិរញ្ញវត្ថុ, ទាំងវិស័យហិរញ្ញវត្ថុធនាគារ និង មិនមែនធនាគារ ។

១២. ការបន្តតាមដាន, វិភាគ និង ត្រួតពិនិត្យការកើនឡើងបំណុលឯកជន សំដៅធានាឱ្យបាននូវស្ថិរភាពហិរញ្ញវត្ថុផង និង ការលើកកម្ពស់ ក៏ដូចជាទ្រទ្រង់ដល់វិស័យពិតផង ។

១៣. បន្តលើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុ, ការសន្សំ, ការប្រើប្រាស់កម្ចី ប្រកបដោយប្រសិទ្ធភាព និង ការលើកកម្ពស់ប្រាក់រៀល ។

១៤. លើកកម្ពស់សមាហរណកម្ម និង បណ្ដាញសុវត្ថិភាពហិរញ្ញវត្ថុ, ទាំងក្នុងតំបន់ និង ពិភពលោក តាមរយៈការជំរុញកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុទាំងក្នុងក្របខណ្ឌទ្វេភាគី និង ពហុភាគី សំដៅទាញយកផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច, ការកៀរគរធនធាន, ការអភិវឌ្ឍទីផ្សារ និង បច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ ។

### ទី៤. ភាពជាដៃគូប្រកបដោយបរិយាប័ន្ន និងស័ក្តិសិទ្ធភាព នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍ

ការបន្តពង្រឹងភាពជាដៃគូប្រកបដោយបរិយាប័ន្ន និង ស័ក្តិសិទ្ធិភាព ជាមួយនឹងគ្រប់តួអង្គអភិវឌ្ឍ, ទាំងផ្នែកហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍ និង ផ្នែកជំនួយបច្ចេកទេស នៅតែជាកិច្ចការដ៏សំខាន់ ដើម្បីកៀរគរបន្ថែមនូវធនធានហិរញ្ញវត្ថុ សម្រាប់បំពេញតម្រូវការចាំបាច់ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ក៏ដូចជាការពង្រឹងសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស សម្រាប់កសាងភាពធន់នៃសង្គម-សេដ្ឋកិច្ច និង ចាប់យកឱ្យបាននូវកាលានុវត្តភាពថ្មីៗ ដែលកំពុងលេចឡើង ស្របនឹងនិន្នាការតំបន់ និង សកល សំដៅជំរុញដំណើរការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ឱ្យបន្តឈានឡើងក្នុងជំហានស្វាហាប់ និង ប្រកបដោយចីរភាព ដោយឈរលើគោលការណ៍ភាពជាម្ចាស់ និង ភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល ។ ក្នុងន័យនេះ, កម្ពុជាត្រូវបន្តពង្រឹងភាពជាដៃគូប្រកបដោយបរិយាប័ន្ន និង ស័ក្តិសិទ្ធិភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍជាមួយគ្រប់តួអង្គអភិវឌ្ឍ តាមរយៈកិច្ចសន្ទនាផ្នែកគោលនយោបាយ, ទាំងជាមួយនឹងដៃគូអភិវឌ្ឍផ្លូវការ, វិស័យឯកជន និង អង្គការមិនមែនរដ្ឋាភិបាល, ក្នុងបេសកកម្មជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ក្នុងដំណើរឆ្ពោះទៅមុខប្រកបដោយចីរភាព និង គ្រប់ជ្រុងជ្រោយ ។

ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា កន្លងមកនេះ, រាជរដ្ឋាភិបាលបានអនុវត្ត "**យុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និង ភាពជាដៃគូឆ្នាំ ២០១៩-២០២៣**" ដោយតម្រឹម និង តម្រង់ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍជាមួយនឹងអាទិភាពគោលនយោបាយអភិវឌ្ឍជាតិ ដូចដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ និង បានលើកកម្ពស់ស័ក្តិសិទ្ធិភាពនៃកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិនានា និង ជាមួយនឹងបណ្តាប្រទេសជាមិត្ត, ទាំងក្នុងក្របខណ្ឌអាស៊ាន និង ពិភពលោក ។ សម្រាប់ដៃគូអភិវឌ្ឍ, ទាំងដៃគូអភិវឌ្ឍទ្វេភាគី, ពហុភាគី, អង្គការក្រៅរដ្ឋាភិបាល, អង្គការសង្គមស៊ីវិល និង វិស័យឯកជន បានជួបពិភាក្សាជាមួយរាជរដ្ឋាភិបាលលើគ្រប់ទិដ្ឋភាព, ទាំងផ្នែកគោលនយោបាយ និង ប្រតិបត្តិការ តាមរយៈការបង្កើតយន្តការពិគ្រោះយោបល់ថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ។ លើសពីនេះ, ដើម្បីតម្រង់ទិសកិច្ចសហប្រតិបត្តិការក្នុងការលើកកម្ពស់លទ្ធផលនៃកិច្ចអភិវឌ្ឍ និង ធានាបាននូវគណនេយ្យភាព ព្រមទាំងតាមដាន និង ត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តសូចនាករ

តាមដានរួមគ្នាឆ្នាំ ២០១៩-២០២៣ ត្រូវបានដាក់រៀបចំ និង ដាក់ឱ្យអនុវត្ត ។ ប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ត្រូវបានកែសម្រួល, ធ្វើបច្ចុប្បន្នភាព និង សុពលភាពជាប្រចាំ ឱ្យកាន់តែមានសុក្រឹតភាព ដើម្បីតាមដានរំហូរហិរញ្ញប្បទានសហប្រតិបត្តិការ ។ ផ្អែកលើមូលដ្ឋាននៃភាពជាដៃគូនេះ, ក្នុងអំឡុងឆ្នាំ ២០១៨-២០២៣ រាជរដ្ឋាភិបាលបានកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍជាមធ្យមប្រមាណជាង ២ ប៊ីលានដុល្លារអាម៉េរិកក្នុងមួយឆ្នាំ ហើយបានតម្រង់ទិសគ្រប់គ្រង និង ប្រើប្រាស់ធនធានទាំងនេះ ប្រកបដោយស័ក្តិសិទ្ធភាព ដើម្បីរួមចំណែកដល់កិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ។ ទន្ទឹមនេះ, ក្នុងការប្រយុទ្ធនឹងការរីករាលដាលនៃជំងឺកូវីដ-១៩, ដៃគូអភិវឌ្ឍបានផ្តល់ហិរញ្ញប្បទាន និង បានផ្គត់ផ្គង់វ៉ាក់សាំង, ឧបករណ៍ និង សម្ភារៈ បរិក្ខារ វេជ្ជសាស្ត្រ សរុបប្រមាណ ២០០ លានដុល្លារអាម៉េរិក សម្រាប់ឆ្លើយតបនឹងតម្រូវការបន្ទាន់នៃវិស័យសុខាភិបាល និង ជាង ៨០០ លានដុល្លារអាម៉េរិកផ្សេងទៀត សម្រាប់គាំទ្រដល់ការអនុវត្ត **«ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងថ្មី ឆ្នាំ២០២១-២០២៣»** របស់រាជរដ្ឋាភិបាល។

ទន្ទឹមគ្នានឹងការសម្រេចបាននូវសមិទ្ធផលដែលគួរឱ្យកត់សម្គាល់ខាងលើ កម្ពុជានៅបន្តជួបបញ្ហាប្រឈម, ទាំងក្នុងពេលបច្ចុប្បន្ន និង ក្នុងពេលមធ្យមខាងមុខ រួមមាន ១). លទ្ធភាពថមថយនៃទំហំហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍ ដោយសារការធ្លាក់ចុះសេដ្ឋកិច្ចសកល និង ការកើនឡើងអតិផរណា ដែលអាចនាំឱ្យដៃគូអភិវឌ្ឍឈានទៅអនុវត្តគោលនយោបាយរឹតត្បិតធនធានសម្រាប់ផ្តល់ឱ្យប្រទេសកំពុងអភិវឌ្ឍ, ឬ បង្វែរហិរញ្ញប្បទានទៅឱ្យតំបន់ ឬ ប្រទេសដែលមានតម្រូវការខ្ពស់ជាង ឬ សម្រាប់បម្រើគោលដៅមនុស្សធម៌ផ្សេងៗ, ២). ការផ្លាស់ប្តូរទម្រង់នៃការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ អាចធ្វើឱ្យថមថយទំហំហិរញ្ញប្បទានឥតសំណង ដែលអាចជំនួសដោយឥណទានសម្បទាន ក៏ដូចជាការប្រែប្រួលនៃកម្រិតសម្បទានរបស់ឥណទាន ក្នុងខណៈដែលកម្ពុជាបានក្លាយខ្លួនជាប្រទេសចំណូលមធ្យមកម្រិតទាប និង កំពុងឈានឆ្ពោះទៅសម្រេចឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០, និង ៣). ការចូលរួមនៃតួអង្គអភិវឌ្ឍកាន់តែច្រើនក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍតម្រូវឱ្យកម្ពុជាពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រង និង សម្របសម្រួល ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានទាំងនេះ, ៤). ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩, មានការខកខាន ក្នុងអនុវត្តយន្តការពិគ្រោះយោបល់ សម្រាប់ពិភាក្សា លើប្រធានបទនានាពាក់ព័ន្ធនឹងការអនុវត្តប្រទេសជាតិ ។

រាជរដ្ឋាភិបាលនៃនីតិកាលទី ៧ នៃរដ្ឋសភា នឹងផ្តោតអាទិភាពលើ÷

**១.** ការបន្តពង្រឹងភាពជាដៃគូប្រកបដោយបរិយាប័ន្ន ជាមួយតួអង្គអភិវឌ្ឍ ដើម្បីកៀរគរ, សម្របសម្រួល និង គ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍពីគ្រប់ប្រភព ហើយតម្រង់ធនធានទាំងនេះ ត្រង់ទៅអនុវត្តអាទិភាពគោលនយោបាយជាតិ ឱ្យកាន់តែមានស័ក្តិសិទ្ធិភាព និង ប្រសិទ្ធភាពខ្ពស់ ។

**២.** ការរៀបចំ និង អនុវត្ត“ **យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និង ភាពជាដៃគូ ឆ្នាំ២០២៤-២០២៨**” ដើម្បីបន្តពង្រឹងភាពជាម្ចាស់ និង ភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល ក្នុងការលើកម្ពស់ស័ក្តិសិទ្ធិភាពនៃកិច្ចអភិវឌ្ឍជាតិ ព្រមទាំងបន្តពង្រឹងភាពជាដៃគូប្រកបដោយបរិយាប័ន្នជាមួយតួអង្គអភិវឌ្ឍនានា ។

៣. ការបន្តចូលរួមយ៉ាងសកម្មក្នុងកិច្ចការតំបន់ និង ពិភពលោក ដើម្បីបង្កើនកាលានុវត្តភាពសម្រាប់ការអភិវឌ្ឍប្រទេស ជាពិសេសទាក់ទាញនូវទំនុកចិត្តមកលើសុខសន្តិភាព, សុវត្ថិភាព និង បរិស្ថានវិនិយោគរបស់កម្ពុជា ក៏ដូចជាដើម្បីគោលដៅនៃការលើកកម្ពស់កិត្យានុភាពរបស់កម្ពុជា ។

៤. ការកំណត់ឡើងវិញនូវគោលដៅនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍ ដើម្បីឆ្លើយតបនឹងការប្រែប្រួលនៃបរិការណ៍ និង និម្មាបនកម្មអភិវឌ្ឍន៍សកល និង ក្នុងប្រទេស សម្រាប់គ្រប់គ្រងរំហូរធនធានទាំងនេះ ឱ្យស្របតាមបរិការណ៍ និង ដំណើរអភិវឌ្ឍឈានទៅមុខរបស់កម្ពុជា ។

៥. ការបង្កើនប្រសិទ្ធភាពនៃការអនុវត្តយន្តការ និង ឧបករណ៍សម្របសម្រួលភាពជាដៃគូ ដែលមានស្រាប់ ឬ អាចបង្កើតបន្ថែមថ្មីក្នុងករណីចាំបាច់ សម្រាប់ពិភាក្សាលើប្រធានបទពាក់ព័ន្ធនឹងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ដើម្បីលើកកម្ពស់គណនេយ្យភាពទ្វេទិសជាមួយបណ្ដារតួអង្គអភិវឌ្ឍ និង ភាគីពាក់ព័ន្ធ ។

៦. ការបន្តចូលរួមក្នុងវេទិកាអន្តរជាតិស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍ និង បន្តអនុវត្តរួមគ្នាជាមួយនឹងបណ្ដាតួអង្គអភិវឌ្ឍនូវការប្តេជ្ញានានាដែលបានឯកភាពក្នុងវេទិកាទាំងនេះ ស្របតាមបរិការណ៍ និង ដំណើរអភិវឌ្ឍឈានទៅមុខរបស់កម្ពុជា ។

៧. ការបន្តពង្រឹងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល តាមរយៈការអនុវត្តច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល ដើម្បីបង្កើតបាននូវបរិយាកាសភាពជាដៃគូប្រកបដោយសុខដុមនីយកម្ម និង លើកកម្ពស់ប្រសិទ្ធភាព, តម្លាភាព និង គណនេយ្យភាពនៃកិច្ចសហការនេះ ។

ជាសរុប, រាជរដ្ឋាភិបាលនឹងបន្តលើកកម្ពស់ភាពជាដៃគូប្រកបដោយបរិយាប័ន្ន និង ស័ក្តិសិទ្ធិភាព ជាមួយនឹងតួអង្គអភិវឌ្ឍទាំងអស់ ដោយឈរលើគោលការណ៍ស្មើភាព និង ការគោរពគ្នាទៅវិញទៅមក, ទន្ទឹមនឹងការពង្រឹងភាពជាម្ចាស់ ក្នុងកិច្ចដំណើរការអភិវឌ្ឍជាតិ ដើម្បីបន្តលើកកម្ពស់ស័ក្តិសិទ្ធភាព និង ប្រសិទ្ធភាព ក្នុងការគ្រប់គ្រង និង ប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍ ។

### ទី៥. ការធ្វើសមាហរណកម្មសេដ្ឋកិច្ចស៊ីជម្រៅនៅក្នុងតំបន់ និង សកល

ការធ្វើសមាហរណកម្មសេដ្ឋកិច្ចស៊ីជម្រៅក្នុងតំបន់ និង សកល គឺជាកត្តាដ៏សំខាន់ក្នុងការជំរុញ និង គាំទ្រពាណិជ្ជកម្មទំនិញ និង សេវា ក៏ដូចជា ការវិនិយោគ និង ការតភ្ជាប់ ដែលបានរួមចំណែកដល់កំណើនសេដ្ឋកិច្ច និង ការអភិវឌ្ឍសង្គមប្រកបដោយនិរន្តរភាព ។ កន្លងមក, រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការធ្វើសមាហរណកម្មសេដ្ឋកិច្ច, ទាំងក្នុងក្របខណ្ឌពិភពលោក តំបន់ អនុតំបន់ និង ទ្វេភាគី តាមរយៈតួនាទីជាប្រទេសសម្របសម្រួលនៃក្រុមប្រទេសអភិវឌ្ឍតិចតួច, តួនាទីជាប្រធានអាស៊ានប្តូរវេន និង ការលើកកម្ពស់មជ្ឈភាពអាស៊ាន, ការចូលជាធរមាននៃកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់(RCEP), ការចូលរួមក្នុងគំនិតផ្តួចផ្តើម "ខ្សែក្រវាត់ និង ផ្លូវ" (BRI) និង ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី(AIIB), កិច្ចសហប្រតិបត្តិការអនុតំបន់, និង ការចូលជាធរមាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី ។ ជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងទាំងនេះ កម្ពុជារក្សាឱ្យបានទីផ្សារនាំចេញសម្រាប់ផលិតផលសំខាន់ៗ តាមរយៈការប្រើប្រាស់

ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម(GSP), ទទួលបានប្រភពហិរញ្ញប្បទានថ្មីបន្ថែម សម្រាប់ពង្រឹងហេដ្ឋារចនាសម្ព័ន្ធ និង សេដ្ឋកិច្ចរបស់កម្ពុជា, ជំរុញការអភិវឌ្ឍច្រករបៀងសេដ្ឋកិច្ចតំបន់សហប្រតិបត្តិការសេដ្ឋកិច្ច និង ពាណិជ្ជកម្ម, ឧទ្យានឧស្សាហកម្ម, កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ និង ពាណិជ្ជកម្ម និង ភាពច្នៃប្រឌិត និង បច្ចេកវិទ្យា, លើក កម្ពស់ភាពទាក់ទាញនៃទីផ្សាររបស់ខ្លួន, ទាំងការវិនិយោគ, ការធ្វើពាណិជ្ជកម្មអន្តរជាតិ, ការតភ្ជាប់ និង ការចូលរួម ក្នុងខ្សែច្រវាក់តម្លៃសកលជាមួយនឹងដៃគូសំខាន់ៗ, និង ជាពិសេសពង្រីកវិសាលភាពនៃការទទួលបានទីផ្សារដែល ស្រាប់របស់កម្ពុជា និង ផ្តល់ជម្រើសកាន់តែច្រើន សម្រាប់ធុរជននិងពាណិជ្ជករ ដែលបានបង្កើតឱកាសការងារជូន ប្រជាពលរដ្ឋ និង រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ។

ទន្ទឹមនេះ, កម្ពុជានឹងបន្តជួបប្រទះបញ្ហាប្រឈមចម្បងៗ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ និង ចាត់វិធានការឱ្យបានទាន់ពេលវេលា សម្រាប់រយៈពេលមធ្យមខាងមុខ ។ ការចាកចេញរបស់កម្ពុជាពីឋានៈ ប្រទេសអភិវឌ្ឍតិចតួច (LDC) ក្នុងឆ្នាំ ២០២៧ ជាមួយនឹងរយៈពេលអន្តរកាលចំនួន ៣ ឆ្នាំបន្តទៀត អាចនឹងផ្តល់ ជាបច្ច័យប៉ះពាល់ដល់ភាពប្រកួតប្រជែងនៃការនាំចេញរបស់កម្ពុជាសម្រាប់ផលិតផលមួយចំនួនជាពិសេសសម្រាប់ ទីផ្សារនៅសហភាពអឺរ៉ុប និង អាមេរិកខាងជើង តាមរយៈការប្រើប្រាស់ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម (GSP) ។ បន្ថែមពីនេះ, ការចាកចេញពីឋានៈប្រទេសអភិវឌ្ឍតិចតួច អាចបាត់បង់ផងដែរនូវប្រព្រឹត្តិកម្មពិសេស និង ដោយ ឡែក, ទាំងក្នុងក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និង កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីមួយចំនួន ដែល ទាមទារឱ្យមានការសិក្សា និង ត្រៀមលក្ខណៈឱ្យបានគ្រប់ជ្រុងជ្រោយ ។ ដំណាលគ្នានេះ, កម្ពុជាក៏ដូចជាបណ្តា ប្រទេសក្នុងតំបន់ កំពុងទទួលរងនូវឥទ្ធិពលនៃការប្រទាញប្រទង់គ្នារបស់មហាអំណាច ដើម្បីកំណត់នូវវិធាន ពាណិជ្ជកម្មសេរីទំនើប និង ទាន់សម័យសម្រាប់សតវត្សទី ២១ ដែលបានឆ្លុះបញ្ចាំងរួចមកហើយតាមរយៈការចូល ជាធរមាននៃកិច្ចព្រមព្រៀងអាសិប និង កិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយ និង ប្រកបដោយវឌ្ឍនភាពស្តីពីភាពជា ដៃគូអន្តរប៉ាស៊ីហ្វិក(CP-TPP) ក៏ដូចជាការដាក់ចេញនូវគំនិតផ្តួចផ្តើមថ្មីៗជាបន្តបន្ទាប់, ក្នុងនោះ មានក្របខ័ណ្ឌ សេដ្ឋកិច្ចឥណ្ឌូប៉ាស៊ីហ្វិក (IPEF) ដោយជ្រើសរើសតែប្រទេសមួយចំនួនចូលរួមចរចា និង ជាពិសេសកិច្ចខិតខំ ប្រឹងប្រែងរបស់ប្រទេសមួយចំនួន ក្នុងការធ្វើវិសោធនកម្ម ដើម្បីលើកកម្ពស់ស្តង់ដាររបស់កិច្ចព្រមព្រៀងដទៃទៀត ឱ្យស្របតាមអាសិប ឬ CP-TPP ។ ក្នុងបរិការណ៍នៃភាពមិនច្បាស់លាស់ ដែលកើតចេញពីការប្រកួតប្រជែងរបស់ មហាអំណាចទាំងផ្នែកភូមិសាស្ត្រនយោបាយ និង សេដ្ឋកិច្ច, ការពង្រឹងពហុភាគីនិយម និង ការលើកកម្ពស់ប្រព័ន្ធ ពាណិជ្ជកម្មពហុភាគីដោយផ្អែកលើមូលដ្ឋានច្បាប់ និង យកអង្គការពាណិជ្ជកម្មពិភពលោកជាស្នូល នៅតែមាន សារៈសំខាន់ ក្នុងការដោះស្រាយបញ្ហាប្រឈមរបស់ពិភពលោក ។ ទន្ទឹមនឹងការបន្តស្វះស្វែងរកទីផ្សារនាំចេញថ្មី តាមរយៈការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី, កម្ពុជានៅបន្តជួបបញ្ហាប្រឈមដទៃទៀត ដែលត្រូវដោះស្រាយ ក្នុងនោះ មានដូចជា ការពង្រឹងភាពប្រកួតប្រជែងរបស់ផលិតផលនាំចេញ, ការធ្វើពិពិធកម្មលើមុខទំនិញនាំចេញ, ការប្រើប្រាស់ផលិតផលក្នុងស្រុកបម្រើដល់ការផលិតសម្រាប់ការនាំចេញការកែច្នៃទំនិញ, ការចូលរួមក្នុងខ្សែច្រវាក់ តម្លៃសកលក្នុងតម្លៃបន្ថែមខ្ពស់, កិច្ចសម្រួលពាណិជ្ជកម្ម, យន្តការសម្របសម្រួលផ្នែកគោលនយោបាយ ជាពិសេស

កម្រិតទាបនៃការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី សម្រាប់ការនាំចេញរបស់កម្ពុជាទាំងទំនិញ និង សេវា ព្រមទាំងការវិនិយោគ ។

ក្នុងនីតិកាលទី៧ នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ÷

**១.** ការរៀបចំទាំងក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ការត្រៀមខ្លួន ក្នុងការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍតិចតួចក្នុងរយៈពេលដ៏ខ្លីខាងមុខ ដោយជោគជ័យ និង ប្រកបដោយភាពរឹងមាំ និង ក្របខណ្ឌគោលនយោបាយតម្រង់ទិសសមាហរណកម្មសេដ្ឋកិច្ចប្រកបដោយយុទ្ធសាស្ត្រសម្រាប់រយៈពេលវែង ដោយត្រូវបន្តចរចាក្នុងរយៈពេលអន្តរកាលដែលទទួលបាន ដើម្បីទទួលបានភាពអនុគ្រោះថ្មីតាមរយៈប្រព័ន្ធ GSP Plus និង រក្សាឱ្យបានជាអតិបរមានូវប្រព្រឹត្តិកម្មពិសេស និងដោយឡែក (Special and Differential Treatment) ផងដែរ ទោះបីជាចាកចេញពីប្រទេស LDC សំដៅរក្សាទីផ្សារ និង រក្សាលំនឹងផលិតកម្ម ព្រមទាំងភាពទាក់ទាញសម្រាប់ការមកវិនិយោគនៅកម្ពុជា ។

**២.** ការបន្តចរចាបើកទីផ្សារជាមួយនឹងដៃគូរបស់អាស៊ានដែលមានស្រាប់ និង ថ្មី រួមបញ្ចូលទាំងការចរចាពង្រីកសមាជិកភាពនៃកិច្ចព្រមព្រៀងអាសិប និង ទ្វេភាគីផងដែរ ដោយផ្អែកលើការសិក្សាសមិទ្ធលទ្ធភាព មានការពិនិត្យនិងវាយតម្លៃច្បាស់លាស់ និង គ្រប់ជ្រុងជ្រោយ ជាពិសេស ត្រូវរក្សាបាននូវភាពប្រកួតប្រជែងនៃផលិតផលដែលកំពុងនាំចេញស្រាប់ និង ជំរុញបន្ថែមការនាំចេញទាំងផលិតផលដទៃទៀត សេវា និង ការវិនិយោគ ។

**៣.** ការរៀបចំយុទ្ធសាស្ត្រ និង ផែនការសកម្មភាពសម្រាប់បន្តការចរចាទាញយកអត្ថប្រយោជន៍ជាតិឱ្យបានជាអតិបរមា នៅក្រោមក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក, សហគមន៍សេដ្ឋកិច្ចអាស៊ាន, រវាងអាស៊ានជាមួយដៃគូសេដ្ឋកិច្ចជាទ្វេភាគី និង តំបន់, អនុតំបន់, ទ្វេភាគី សំដៅតភ្ជាប់កម្ពុជាជាមួយខ្សែច្រវាក់តម្លៃ និង ខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងតំបន់ និង សកល តាមរយៈការបន្តជំរុញការកែទម្រង់វិស័យពាណិជ្ជកម្ម ដើម្បីកាត់បន្ថយថ្លៃដើម, បង្កើនគុណភាពផលិតផល និង ការប្រកួតប្រជែងផ្នែកសេវានិងទំនិញ, ការកែលម្អការផ្តល់សេវាសាធារណៈ, ការជំរុញការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ការធ្វើវិសោធនកម្ម និង កសាងច្បាប់ពាណិជ្ជកម្មបន្ថែម សំដៅជួយរក្សាស្ថិរភាពសេដ្ឋកិច្ច, ផ្តល់ផលប្រយោជន៍ និង បង្កើតចំណូលជូនប្រជាពលរដ្ឋ ។

**៤.** ការធ្វើពិពិធកម្មផលិតផលនាំចេញនិងសេវាពីកម្ពុជា ដើម្បីទាញយកកាលានុវត្តភាពកើតចេញពីការបង្កើតពាណិជ្ជកម្ម (trade creation) និង ការបង្វែពាណិជ្ជកម្ម (trade diversion) ក្នុងក្របខ័ណ្ឌអាសិប និង ក្របខ័ណ្ឌពាណិជ្ជកម្មសេរីដទៃទៀត ដោយសង្កត់ធ្ងន់លើការវិនិយោគថ្មី, វិធានការឧបត្ថម្ភគាំទ្របច្ចេកទេស, ការកាត់បន្ថយ និង ការលុបបំបាត់របាំងពាណិជ្ជកម្ម ដែលមិនចាំបាច់, ព្រមទាំងការអភិវឌ្ឍ និង ការលើកកម្ពស់អនុលោមភាពស្តង់ដារ និង បទប្បញ្ញត្តិរបស់សហគ្រាសធុនតូច និង មធ្យម សម្រាប់ជំនួសឱ្យការនាំចូល និង ឈានដល់ការប្រកួតប្រជែងសម្រាប់នាំចេញ, និង ធ្វើបដិវត្តកម្មឌីជីថលសម្រាប់សេវាសាធារណៈ បម្រើដល់ការនាំចេញ និង នាំចូល ។

**៥.** ការគាំទ្រដល់កិច្ចសហប្រតិបត្តិការរវាងស្ថាប័នហិរញ្ញវត្ថុជាតិ និង អន្តរជាតិ ដើម្បីផ្តល់ការគាំទ្រផ្នែក

ហិរញ្ញវត្ថុ ប្រកបដោយចីរភាព និង ពិពិធកម្មសម្រាប់ការអនុវត្តគម្រោងនានា, ការបន្តជំរុញការចូលរួមដោយសកម្មរបស់កម្ពុជា ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការ និង គំនិតផ្តួចផ្តើមអន្តរជាតិសំខាន់ៗ, និង ការលើកកម្ពស់ប្រព័ន្ធពាណិជ្ជកម្មពហុភាគីដែលមានលក្ខណៈសកល ឈរលើគោលការណ៍បើកចំហ, តម្លាភាព, បរិយាប័ន្ន, ការប្រកួតប្រជែងស្មើភាព និង យកប្រជាជនជាស្នូល ។

**៦.** ការពង្រឹងកិច្ចសហការ និង ការសម្របសម្រួលរវាងក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល និង គ្រប់តួអង្គអភិវឌ្ឍផ្សេងទៀត និង ការពង្រឹងសមត្ថភាពរបស់កម្ពុជាលើវិស័យថ្មីៗ ស្របតាមនិន្នាការតំបន់ និង សកល ដូចជា បរិស្ថាន, សេដ្ឋកិច្ចបៃតង, ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, សិទ្ធិពលកម្ម, លទ្ធកម្មសាធារណៈ និង កម្មសិទ្ធិបញ្ញា ជាដើម ក្នុងគោលដៅពង្រឹងសមត្ថភាព និង ប្រព័ន្ធជាតិ និង ពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា ដើម្បីជាការត្រៀមខ្លួនជាមុន ក្នុងការចរចាជាមួយបណ្តាប្រទេសអភិវឌ្ឍ ។

**៧.** ការជំរុញការតភ្ជាប់គ្រប់ជ្រុងជ្រោយ, ទាំងផ្នែកទន់ និង រឹង, ការទទួលបានទីផ្សារ, ការបន្សុីគោលនយោបាយ និង ផែនការអភិវឌ្ឍដែលពាក់ព័ន្ធថ្នាក់ជាតិ, ផ្សារភ្ជាប់ជាមួយបណ្តាប្រទេស ដែលមានបណ្តុំឧស្សាហកម្មសំខាន់ៗនៅអាស៊ី (major industrial hubs in Asia) ដើម្បីលើកកម្ពស់ការចូលរួមរបស់កម្ពុជាទាំងក្នុងខ្សែច្រវាក់តម្លៃ (value chains) និង ខ្សែច្រវាក់ផ្គត់ផ្គង់ (supply chains) ក៏ដូចជាគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ និង ការច្នៃប្រឌិត ។

**៨.** ការតាមដាននិន្នាការសកលឱ្យបានខ្ជាប់ខ្ជួន ដើម្បីអាចកំណត់និងរៀបចំគោលនយោបាយការបរទេសពាណិជ្ជកម្ម និង ការវិនិយោគ ដែលមានភាពបត់បែនបានទាន់ពេលវេលា ដោយត្រូវសិក្សាអំពីទិសដៅអនាគត និង ការត្រូវត្រៀមខ្លួនចំពោះការប្រែប្រួលនៃនិម្មាបនកម្មសេដ្ឋកិច្ចរបស់តំបន់ និង សកល ដែលអាចមានវិបាកមកលើសេដ្ឋកិច្ច និង វិស័យពាណិជ្ជកម្មរបស់កម្ពុជា ដោយធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាមានស្ថិរភាព និង ភាពធន់ សំដៅអាចទាញយកឱកាសវិនិយោគ ជាពិសេសខណៈពេលដែលប្រទេសមហាអំណាចមួយចំនួនបង្វែរការវិនិយោគមកកាន់តំបន់អាស៊ីអាគ្នេយ៍ ។

**៩.** ការបន្តចរចាលើកិច្ចព្រមព្រៀងអន្តរជាតិទាក់ទងនឹងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយឈរលើផលប្រយោជន៍និងសន្តិសុខជាតិ, ធានាឱ្យបាននូវស្ថិរភាពសេដ្ឋកិច្ចកម្ពុជា ព្រមទាំងគាំទ្រដល់ការអនុវត្តក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថល ២០២១-២០៣៥ ផងដែរ ។